**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបហ៊ីប៉ូតែក និង ការបញ្ចាំអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លោក សាន់ សុវណ្ណារ៉ា**

**លោក ហាក់ សុខម៉េង**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ថ្លឹយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបហ៊ីប៉ូតែក និង ការបញ្ចាំអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ មិថុនា ឆ្នាំ ២០២១

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ **លោក សាន់ សុវណ្ណារ៉ា**

**លោក ហាក់ សុខម៉េង**

សាស្ត្រាចារ្យណែនាំ

លោកជំទាវ **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សាន់ សុវណ្ណារ៉ា** និងខ្ញុំបាទឈ្មោះ **ហាក់ សុខម៉េង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត អាហារូបករណ៍ ឆ្នាំទី៤ ជំនាន់ទី២៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-ឆ្នាំ២០២១។ យើងខ្ញុំទាំងពីរបានសរសេរសារណាលើប្រធានបទស្តីអំពី “**ការប្រៀបធៀបហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ**” ។

ជាបឋម យើងខ្ញុំទាំងពីរសូមលំអោនកាយប្រណិប័តន៍ សម្តែងសេចក្តីគោរពដឹងគុណដ៏ខ្ពង់ខ្ពស់បំផុត នូវគុណូបការៈដ៏ធំធេងមិនអាចកាត់ថ្លៃបាន ចំពោះលោកអ្នកមានគុណទាំងទ្វេ មានលោកឪពុក **សាន់ មូរ៉េត** អ្នកម្តាយ **ហេង លីខេង** ព្រមទាំង លោកឪពុក **សុវណ្ណ គឹមហាក់** និងអ្នកម្តាយ **ពៅ គឹមសាន** ដែលបានប្រសូត្របុត្រាទាំងពីរនេះ និងខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនអស់រយៈកាលជាង២០ឆ្នាំកន្លងមកនេះ ព្រមទាំងបានអប់រំ ទូន្មាន និងបញ្ជូនកូនឱ្យទទួលបាននូវការអប់រំ បណ្តុះបណ្តាល ធ្វើឱ្យកូនបានក្លាយជាពលរដ្ឋល្អមួយរូបនៅក្នុងសង្គមជាតិ។

ជាកិច្ចបន្ទាប់យើងខ្ញុំសូមសម្តែងនូវអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះ**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច រួមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ប្តូរផ្តាច់ក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្សផ្នែកនីតិសាស្រ្តនៅកម្ពុជានៃយើង តាមរយៈការបង្ហាត់បង្រៀន ចង្អុលតម្រង់ទិសដល់និស្សិត និងការនិពន្ធចងក្រងនូវស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ ហើយដែលលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះបានចេញជាផ្លែផ្កាជាបន្តបន្ទាប់រៀងមកហើយ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ **លោកជំទាវ សាស្រ្តាចារ្យ ម៉ួយ ធីតា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាសាស្ត្រាចារ្យដឹកនាំយើងខ្ញុំក្នុងការសរសេរនូវប្រធានបទនេះ។ លោកជំទាវសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំ ត្រួសត្រាយផ្លូវដល់យើងខ្ញុំក្នុងការសរសេរនូវសារណាបទនេះ ជាពិសេសនៅពេលដែលយើងខ្ញុំជួបប្រទះនឹងការលំបាកក្នុងការស្រាវជ្រាវ អ្នកគ្រូបានព្យាយាមជួយដោះស្រាយដោយអស់ពីកម្លាំងកាយចិត្ត ដែលធ្វើឱ្យយើងខ្ញុំអាចចងក្រងបាននូវស្នាដៃសារណាបទមួយដែលប្រកបទៅដោយគុណភាព។

# អារម្ភកថា

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សរមែងតែងជួបប្រទះនូវការខ្វះខាត រីឯមធ្យោបាយដើម្បីដោះស្រាយបញ្ហានេះអាចមានច្រើន ប៉ុន្តែវិធីដ៏ត្រង់ និងដ៏ពេញនិយមបំផុតនោះគឺការខ្ចីបំណុល។ ការខ្ចីបំណុលនេះទៀតសោត ប្រសិនបើក្នុងទំហំតិចតួច វាមិនសូវជាបញ្ហាទេ ប៉ុន្តែប្រសិនបើក្នុងទំហំទឹកប្រាក់ធំ ដើម្បីធានានូវលទ្ធភាពនៃការប្រមូលបំណុលរបស់ខ្លួន ម្ចាស់បំណុលតែងតែតម្រូវឱ្យកូនបំណុលដាក់នូវវត្ថុណាមួយដើម្បីជាការធានា។ បច្ចុប្បន្ននេះ កម្ចីប្រាក់ក្នុងទំហំធំ ភាគច្រើនត្រូវបានបង្កើតឡើងក្នុងរូបភាពជា ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ ព្រោះកម្មវត្ថុនៃការដាក់ធានានៃប្រតិបត្តិការទាំងពីរនេះគឺជាអចលនវត្ថុ។ ប៉ុន្តែយើងសង្កេតឃើញថា ទោះជាសិទ្ធិប្រាតិភោគទាំងពីរនេះមានកំណើតនៅក្នុងនីតិខ្មែរយូរទៅហើយ ម្យ៉ាងប្រជាជនខ្មែរក៏អនុវត្តជាញឹកញាប់ផងដែរ ប៉ុន្តែនៅតែមានការយល់ច្រឡំរវាងសិទ្ធិប្រាតិភោគទាំងពីរនេះដដែល អាស្រ័យដោយហេតុថា សិទ្ធិទាំងពីរនេះមានលក្ខណៈស្រដៀងគ្នាខ្លាំងពេក។

មូលហេតុនេះហើយដែលធ្វើឱ្យយើងខ្ញុំទាំងពីរនាក់ ដែលជាអ្នកសិក្សានីតិសាស្ត្រ បានប្តេជ្ញាចិត្តធ្វើការសិក្សាលើប្រធានបទ “**ប្រៀបធៀបហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ**” សម្តៅវែកញែកភាពខុសគ្នានៃសិទ្ធិប្រាតិភោគទាំងពីរនេះឱ្យបានច្បាស់លាស់។ ក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំនេះមានជួបប្រទះនូវបញ្ហាលំបាកជាច្រើន អាស្រ័យដោយសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះមានលក្ខណៈដូចគ្នាច្រើនពេក ដែលពិបាកក្នុងការវែកញែក ម្យ៉ាងវិញទៀត អាស្រ័យដោយបច្ចុប្បន្នមានការរីករាតត្បាតនៃជំងឺដ៏កាចសាហាវគឺកូវីដ-១៩ ក្នុងសហគមន៍ ដូច្នេះធ្វើឱ្យយើងខ្ញុំពិបាកក្នុងការចុះទៅស្ថាប័នអនុវត្តផ្ទាល់លើបញ្ហានេះ ដើម្បីសិក្សាអំពីការអនុវត្តជាក់ស្តែងផ្សារភ្ជាប់ទៅនឹងទ្រឹស្តី និងលទ្ធិ។ ប៉ុន្តែទោះជាយ៉ាងណាក្តី ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់យើងខ្ញុំ និងការណែនាំដ៏យកចិត្តទុកដាក់ពីសំណាក់សាស្ត្រាចារ្យណែនាំ ធ្វើឱ្យសារណាបទនេះបានលេចជារូបរាងឡើង។

យើងខ្ញុំប្រាកដជាក់ក្នុងចិត្តថា ទោះបីជាស្នាដៃនេះត្រូវបានសរសេរឡើងដោយសម្រិតសម្រាំងយ៉ាងណាក្តី ក៏គង់តែនឹងចៀសមិនផុតពីកំហុសឆ្គងដោយអចេតនា ដោយហេតុតែយើងខ្ញុំជានិស្សិតនៅឡើយ ពុំទាន់មានបទពិសោធន៍ក្នុងការប្រមូលផ្តុំនូវឯកសារ ចងក្រងជាឯកសារមួយមានលក្ខណៈជាវិជ្ជាជីវៈ ម្យ៉ាងទៀតអាស្រ័យដោយចំណេះដឹងរបស់យើងខ្ញុំក៏នៅមានកម្រិតផងដែរ។ ដូច្នេះយើងខ្ញុំសូមការអធ្យាស្រ័យទុកជាមុនពីសំណាក់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ ក៏ដូចជាមិត្តអ្នកសិក្សានីតិសាស្ត្រទាំងអស់ ប្រសិនបើមានកំហុសឆ្គងដោយអន្លើណាមួយនោះ សូមមេត្តាខន្តីអភ័យទោស ព្រមទាំងផ្តល់នូវមតិកែលម្អក្នុងន័យស្ថាបនាដល់យើងខ្ញុំផង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១**

**សញ្ញាណទូទៅ**

**១.១.ការវិវត្តន៍នៃបទដ្ឋានគតិយុត្តទាក់ទងនឹងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុនៅកម្ពុជា** ..... ៤

**១.២.អត្ថន័យនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ** ..... ៦

១.២.១.អត្ថន័យនៃហ៊ីប៉ូតែក ..... ៦

១.២.២.អត្ថន័យនៃការបញ្ចាំអចលនវត្ថុ ..... ៧

១.២.៣.ប្រៀបធៀបអត្ថន័យ ..... ៨

**១.៣.លក្ខណៈនៃសិទ្ធិប្រាតិភោគ** ..... ៨

១.៣.១.ទំនាក់ទំនងនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ..... ៩

១.៣.១.១.ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគ ..... ៩

១.៣.១.២.ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគ ..... ៩

១.៣.១.៣.ភាពអវិភាគនៃសិទ្ធិប្រាតិភោគ ..... ១០

១.៣.២.ទំនាក់ទំនងនៃសិទ្ធិប្រាតិភោគ និងអចលវត្ថុជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ..... ១០

១.៣.២.១.អានុភាពតាមនៃសិទ្ធិប្រាតិភោគ ..... ១០

១.៣.២.២.ការអនុវត្តសិទ្ធិប្រាតិភោគ ..... ១១

**១.៤.កម្មវត្ថុ** ..... ១១

១.៤.១.កម្មវត្ថុនៃហ៊ីប៉ូតែក ..... ១១

១.៤.២.កម្មវត្ថុនៃការបញ្ចាំអចលនវត្ថុ ..... ១២

**ជំពូកទី២**

**ការបង្កើត អានុភាព និងការរលត់**

**២.១.ការបង្កើតហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ** ..... ១៣

២.១.១.លក្ខខណ្ឌសុពលភាពគូភាគី ..... ១៣

២.១.១.១.លក្ខខណ្ឌសុពលភាពនៃហ៊ីប៉ូតែក ................................................................ ១៣
២.១.១.២.លក្ខខណ្ឌសុពលភាពនៃការបញ្ចាំអចលនវត្ថុ................................................ ១៤
២.១.២.លក្ខខណ្ឌតតាំង ................................................................................ ១៤
២.១.២.១.លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក.......................................................................... ១៤
២.១.២.២.លក្ខខណ្ឌតតាំងនៃការបញ្ចាំអចលនវត្ថុ.............................................................. ១៦

**២.២.អានុភាពនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ** ........................................................... ១៦
២.២.១.អានុភាពនៃហ៊ីប៉ូតែក ........................................................................ ១៦
២.២.១.១.ទំហំអានុភាពនៃហ៊ីប៉ូតែក ........................................................................ ១៦
២.២.១.២.អានុភាពនៃហ៊ីប៉ូតែកលើដីចំពោះអាគារដែលជាកម្មសិទ្ធិរបស់តតិយជន ...................... ១៧
២.២.១.៣.អានុភាពនៃហ៊ីប៉ូតែកចំពោះផល ........................................................................ ១៨
២.២.១.៤.ឧបាទេសកម្មលើវត្ថុ................................................................................ ១៩
២.២.១.៥.សិទ្ធិទាមទារសំណងរបស់អ្នកធានាដោយវត្ថុ........................................................ ១៩
២.២.១.៦.ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា........................................................ ២០
២.២.១.៧.លំដាប់នៃហ៊ីប៉ូតែក ................................................................................ ២១
២.២.១.៨.ហ៊ីប៉ូតែករួម................................................................................ ២៣
២.២.១.៩.ការចាត់ចែងហ៊ីប៉ូតែក ................................................................................ ២៤
២.២.២.អានុភាពនៃការបញ្ចាំអចលនវត្ថុ................................................................ ៣០
២.២.២.១.សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលលើអចលនវត្ថុនៃការបញ្ចាំ.................................. ៣០
២.២.២.២.បញ្ញត្តិពិសេសសម្រាប់ដីកសិកម្ម................................................................ ៣០
២.២.២.៣.បន្ទុកសោហ៊ុយសម្រាប់ការគ្រប់គ្រងវត្ថុបញ្ចាំ........................................................ ៣១
២.២.២.៤.ការប្រាក់នៃសិទ្ធិលើបំណុល................................................................ ៣១
២.២.២.៥.ការសន្យាពិសេសក្នុងកិច្ចសន្យាបញ្ចាំ ................................................................ ៣១
២.២.២.៦.អំឡុងពេលនៃសិទ្ធិលើការបញ្ចាំមានអត្ថិភាព................................................ ៣២
២.២.២.៧.ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក................................................ ៣២

**២.៣.ការរលត់នៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ** ........................................................ ៣៣
២.៣.១.ការរលត់ដោយការទាមទារ ........................................................................ ៣៣

២.៣.២.ការរលត់ដោយអាជ្ញាយុកាល ............................................................ ៣៣
២.៣.២.១.ការរលត់ដោយអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ............................ ៣៣
២.៣.២.២.ការរលត់ដោយលទ្ធកម្មនូវអចលនវត្ថុដោយអាជ្ញាយុកាល ............................ ៣៤

## ជំពូកទី៣

## នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

**៣.១.ការដាក់ពាក្យសុំ និងការពិនិត្យពាក្យសុំ** ............................................ ៣៥
៣.១.១.ការរៀបចំដាក់ពាក្យ ............................................................ ៣៥
៣.១.១.១.ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ............................................ ៣៦
៣.១.១.២.រូបមន្តនៃការអនុវត្ត ............................................................ ៣៧
៣.១.១.៣.លិខិតបញ្ជាក់អំពីការបញ្ជូន ............................................................ ៣៨
៣.១.១.៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ ............ ៣៨
៣.១.២.ការសរសេរពាក្យសុំ ............................................................ ៣៩
៣.១.២.១.ខ្លឹមសារនៃពាក្យសុំឱ្យអនុវត្តដោយបង្ខំ ............................................ ៣៩
៣.១.២.២.ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដោយបង្ខំ ............................ ៣៩
៣.១.៣.ការដាក់ពាក្យសុំ ............................................................ ៤០
៣.១.៣.១.តុលាការដែលមានសមត្ថកិច្ច ............................................................ ៤០
៣.១.៣.២.ការបង់ពន្ធ និងសោហ៊ុយចំណាយផ្សេងៗ ............................................ ៤០
៣.១.៤.ការពិនិត្យពាក្យសុំ ............................................................ ៤១
៣.១.៤.១.ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ ............................................ ៤១
៣.១.៤.២.ដីកាសម្រេចលើកចោលពាក្យសុំឱ្យលក់ដោយបង្ខំ ............................................ ៤២
**៣.២.ការរឹបអូស** ............................................................ ៤៣
៣.២.១.ការផ្ទុកផ្តាក់ឱ្យចុះបញ្ជីរឹបអូស ............................................................ ៤៣
៣.២.១.១.ខ្លឹមសារនៃលិខិតផ្ទុកផ្តាក់ ............................................................ ៤៣
៣.២.១.២.ឯកសារដែលត្រូវភ្ជាប់ជាមួយលិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជី ............................ ៤៤
៣.២.២.ការចុះបញ្ជីអំពីការរឹបអូស ............................................................ ៤៤
៣.២.៣.ការបញ្ជូនឯកសារ និងដីកាសម្រេច ............................................................ ៤៥

៣.២.៣.១.ការបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ ............ ៤៥
៣.២.៣.២.ការបញ្ជូនដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត ................ ៤៥
៣.២.៤.អានុភាពនៃការរឹបអូស ................................................................ ៤៦
**៣.៣.ការលក់ដោយបង្ខំ** ................................................................ ៤៧
៣.៣.១.ការវាយតម្លៃអចលនវត្ថុ ................................................................ ៤៧
៣.៣.២.ឯកសារលំអិតអំពីវត្ថុ ................................................................ ៤៨
៣.៣.៣.ដីកាស្រេចកំណត់តម្លៃលក់អប្បបរមា ................................................................ ៤៩
៣.៣.៤.ប្រភេទនៃការលក់ដោយបង្ខំចំពោះការលក់អចលនវត្ថុ ................................................................ ៤៩
៣.៣.៤.១.ការលក់ឡាយឡុងដោយស្រោមសំបុត្រ ................................................................ ៤៩
៣.៣.៤.២.ការលក់ឡាយឡុងដោយផ្ទាល់មាត់ ................................................................ ៥០
៣.៣.៥.ការបង្គាប់ឱ្យអនុវត្តការលក់ ................................................................ ៥០
៣.៣.៦.ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ដោយបង្ខំ ................................................................ ៥០
៣.៣.៧.នីតិវិធីនៃការលក់ ................................................................ ៥០
៣.៣.៨.អ្នកដែលគ្មានសិទ្ធិចូលរួមទិញអចលនវត្ថុ ................................................................ ៥២
៣.៣.៩.ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬដីកាសម្រេចមិនអនុញ្ញាតឱ្យលក់ ................................................................ ៥៣
៣.៣.១០.ការបង់ថ្លៃលក់ ................................................................ ៥៣
**៣.៤.ការប្រមូលសិទ្ធិលើបំណុលដោយម្ចាស់បំណុលនៃការអនុវត្ត** ................................................................ ៥៤
**សេចក្តីសន្និដ្ឋាន** ................................................................ ៥៥
**អនុសាសន៍** ................................................................ ៥៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ជាសញ្ញាបញ្ចប់នៃសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃនៅកម្ពុជា និងនាំកម្ពុជាឈាន ឆ្ពោះទៅរកមាគ៌ាសន្តិភាព វឌ្ឍនភាព និងចីរភាព។ ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានកំណត់អំពី មាគ៌ាសេដ្ឋកិច្ចកម្ពុជាដោយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី និងទទួលស្គាល់នូវកម្មសិទ្ធិឯកជនស្រប ច្បាប់។ ផ្អែកលើមូលដ្ឋាននេះប្រជាជនខ្មែរគ្រប់រូបអាចទិញ លក់ ដាក់ជាប្រាតិភោគ សន្តតិកម្ម ឬធ្វើប្រតិបត្តិការ ស្របច្បាប់ផ្សេងៗទៀតគ្រប់បែបយ៉ាងលើកម្មសិទ្ធិឯកជនរបស់ខ្លួន បន្ថែមពីលើនេះប្រជាពលរដ្ឋក៏អាចប្រកបនូវ អាជីវកម្ម ពាណិជ្ជកិច្ច ជំនួញជួញដូរស្របច្បាប់សព្វសារពើដោយសេរី តាមសមត្ថភាព លទ្ធភាពខ្លួន និងតម្រូវ ការរបស់សង្គមជាតិ។ ក្រលេក មកមើលការដឹកនាំប្រទេសវិញ វិស័យសេដ្ឋកិច្ចតែងតែត្រូវបានរដ្ឋាភិបាល តម្កល់ជាអាទិភាព រដ្ឋាភិបាលកម្ពុជាកន្លងមក ក៏ដូចជាបច្ចុប្បន្ន បាននិងកំពុងខិតខំស្វះស្វែងយ៉ាងស្វិតស្វាញ ក្នុងការតាក់តែងនូវគោលនយោបាយជាតិ និងយុទ្ធសាស្ត្រគ្រប់បែបយ៉ាង សម្តៅធានាជំរុញសន្ទុះសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដូចជាតាមរយៈគោលនយោបាយទាក់ទាញ គៀងគរ វិនិយោគិនជាតិ និងអន្តរជាតិឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា ក្នុងនោះក៏មានការជួយជ្រោមជ្រែងផ្នែក ធនធានថវិកា ជំនាញបច្ចេកទេសដល់ប្រជាពលរដ្ឋទាំងឡាយក្នុងការប្រកបរបរផ្សេងៗជាអាទិ៍ផងដែរ។

ដោយឈរលើមូលដ្ឋាននៃសុខសន្តិភាព ស្ថិរភាពនយោបាយ ប្រព័ន្ធគតិយុត្តល្អប្រសើរ និងការដឹកនាំដ៏ ឈ្លៀសវៃរបស់រដ្ឋាភិបាលកម្ពុជានេះហើយ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាបោះជំហានទៅមុខឥតឈប់ឈរពីមួយថ្ងៃ ទៅមួយថ្ងៃ។ សកម្មភាពវិនិយោគ អាជីវកម្ម ពាណិជ្ជកម្ម ជំនួញជួញដូរ ទាំងខ្នាតតូច មធ្យម និងធំគ្រប់ប្រភេទ កំពុងរីកដុះដាលយ៉ាងផុលផុសក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ។ កត្តារីកចម្រើននៃសេដ្ឋកិច្ច ពាណិជ្ជកម្មនេះ ក៏បណ្តាលឱ្យប្រតិបត្តិការកម្ចីប្រាក់រស់រវើកឡើងផងដែរ ព្រោះមានប្រជាពលរដ្ឋខ្លះចង់បើកអាជីវកម្មរកស៊ី ប៉ុន្តែ ខ្វះដើមទុន រីឯអ្នកខ្លះទៀតកំពុងបំពេញពាណិជ្ជកិច្ចហើយ ប៉ុន្តែត្រូវការមូលធនបន្ថែមដើម្បីពង្រីកទ្រង់ទ្រាយនៃ ពាណិជ្ជកិច្ចរបស់ខ្លួន ដូច្នេះពួកគាត់ត្រូវធ្វើកម្ចីមកដោះស្រាយបញ្ហាទាំងនេះ។ ការខ្ចីនេះទៀតសោត ប្រសិនបើខ្ចី ក្នុងទំហំតូចតាច នោះវាមិនមែនជាបញ្ហានោះទេ ប៉ុន្តែបើខ្ចីក្នុងទំហំធំ ដើម្បីជាទំនុកចិត្តនៃម្ចាស់បំណុល ក៏ដូចជា ធានានូវលទ្ធភាពនៃការប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនមកវិញ ម្ចាស់បំណុលតែងតែតម្រូវឱ្យកូនបំណុលយក កម្មសិទ្ធិលើវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ(ធានា) ឬក៏តម្រូវឱ្យមានតតិយជនណាមួយធានា។ បច្ចុប្បន្នក្នុង ក្របខណ្ឌក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ ដែលប្រសូត្រចេញពីកិច្ចសហប្រតិបត្តិការកម្ពុជា ជប៉ុន ប្រតិបត្តិការ ធានានេះមានច្រើនប្រភេទណាស់ ដូចជាឯកសិទ្ធិ សិទ្ធិឃាត់ទុក ហ៊ីប៉ូតែក ការបញ្ចាំ ប្រាតិភោគដោយអនុប្បទាន និងការធានាដោយបុគ្គល។ ក្នុងចំណោមប្រតិបត្តិការធានាទាំងនោះ មានប្រតិបត្តិការពីរប្រភេទដែលកំពុងតែ

ពេញនិយមខ្លាំងនៅកម្ពុជា គឺហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ ដែលសុទ្ធសឹងតែជាការយកនូវកម្មសិទ្ធិលើអចលនវត្ថុទៅដាក់ធានាបំណុល។

ប៉ុន្តែបើទោះបីជាប្រតិបត្តិការទាំងពីរនេះមានអាយុកាលចំណាស់ណាស់ទៅហើយក្នុងប្រព័ន្ធនៃនីតិខ្មែរយ៉ាងណាក្តី ក៏នៅតែមានប្រជាពលរដ្ឋទូទៅជាច្រើនមានការយល់ច្រឡំលើប្រតិបត្តិការទាំងពីរនេះដែរ ដោយហេតុតែសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះមានលក្ខណៈស្រដៀងគ្នាខ្លាំងពេក ពោលគឺប្រជាពលរដ្ឋយើងកំពុងតែបំពេញប្រតិបត្តិការធានាទាំងពីរប្រភេទនេះយ៉ាងមមាញឹកក្នុងជីវភាពប្រចាំថ្ងៃ តែស្ថិតក្នុងស្ថានភាពមួយស្រពេចស្រពិល មិនយល់ពីភាពខុសគ្នានៃអានុភាព សិទ្ធិ និងករណីកិច្ចនៃភាគីទាំងឡាយក្នុងប្រតិបត្តិការទាំងនេះឡើយ។ អាស្រ័យហេតុនេះមានសំណួរគតិយុត្តជាច្រើនលើកឡើងជុំវិញបញ្ហានេះថា *តើហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ មានលក្ខណៈដូច និងខុសគ្នាយ៉ាងដូចម្តេចខ្លះ? តើហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ មានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងដូចម្តេចខ្លះ? តើគួរជ្រើសរើសប្រតិបត្តិការមួយណាដែលមានលក្ខណៈប្រសើរជាង?*

ផ្អែកលើមូលហេតុនេះហើយ ដែលជំរុញទឹកចិត្តយើងខ្ញុំក្នុងនាមជាអ្នកសិក្សានីតិសាស្រ្តឱ្យសម្រេចចិត្តសិក្សាលើប្រធានបទមួយនេះគឺ “**ប្រៀបធៀបហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ**” ។ សារណាបទនេះមានគោលបំណងបកស្រាយឱ្យបានជាក់ច្បាស់អំពីភាពខុសគ្នានៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ ដោយផ្តោតជាពិសេសត្រង់ចំណុចសិទ្ធិ និងករណីកិច្ចនៃភាគីនីមួយៗក្នុងកិច្ចសន្យាទាំងពីរនេះ ជាងនេះទៅទៀត តាមរយៈការបកស្រាយ និងវែកញែក យើងខ្ញុំនឹងព្យាយាមបង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះ និងផ្តល់ជាអនុសាសន៍ខ្លះៗផងដែរ ជាពិសេសទៅទៀតនោះ យើងខ្ញុំក៏នឹងឆ្លៀតរំលេចអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំផងដែរ ករណីដែលកូនបំណុលអលទ្ធភាពសង ឬសងមិនគ្រប់។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាបទនេះនឹងក្លាយទៅជាអត្ថបទជំនួយស្មារតីមួយ ក្នុងនាមជាមិត្តភក្តិដ៏ល្អរបស់មិត្តនិស្សិតជំនាន់ក្រោយៗទៀត ដែលមានបំណងចង់ស្វែងយល់លើប្រធានបទនេះ ហើយមួយទៀតនោះគឺចំពោះប្រជាពលរដ្ឋទូទៅ ដើម្បីអាចបែងចែកប្រតិបត្តិការធានាកាតព្វកិច្ចទាំងពីរប្រភេទនេះឱ្យច្បាស់ លើសពីនេះទៅទៀត យើងខ្ញុំសង្ឃឹមថា ដោយផ្អែកលើស្ថានភាពផ្ទាល់ខ្លួន ប្រជាពលរដ្ឋទាំងឡាយអាចសម្រេចចិត្តថា តើគួរជ្រើសរើសប្រតិបត្តិការមួយណាដែលស័ក្តិសមនឹងខ្លួនជាង ព្រមទាំងយល់អំពីសិទ្ធិរបស់ខ្លួន និងជាមូលដ្ឋានឈានទៅដល់ការការពារសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងករណីដែលឈ្មួញទុច្ចរិតខ្លះបានរំលោភបំពានក្នុងប្រតិបត្តិការនៃកិច្ចធានាទាំងពីរប្រភេទនេះ។

យើងដឹងហើយថា បណ្តាប្រទេសភាគច្រើននៅលើសកលលោកយើងនេះ ក្នុងប្រព័ន្ធនៃនីតិរដ្ឋប្បវេណីរបស់ពួកគេ ទាក់ទងទៅនឹងសិទ្ធិប្រត្យក្សរមែងមានចែងនូវប្រតិបត្តិការហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុនេះ

ដូច្នេះយើងខ្ញុំសូមធ្វើការកំណត់អំពីព្រំដែននៃការសិក្សាស្រាវជ្រាវនេះគឺក្នុងប្រទេសកម្ពុជាយើងប៉ុណ្ណោះ។ ជាងនេះទៅទៀត ទោះក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ប្រតិបត្តិការនេះចាប់បដិសន្ធិឡើងក្នុងបទដ្ឋានគតិយុត្តយូរណាស់ទៅហើយ ពោលគឺក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ និងមានការប្រែប្រួលឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយទៀត អាស្រ័យដោយរបបនយោបាយ បរិបទសង្គមជាអាទិ៍ ដូច្នេះសារណាបទយើងខ្ញុំសូមកំណត់វិសាលភាពនៃការសិក្សាដោយយកក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ជាគោល ហើយគ្រាន់តែបកស្រាយដោយត្រួសៗអំពីការវិវត្តន៍នៃបទដ្ឋានគតិយុត្តទាក់ទងនឹងប្រតិបត្តិការធានាទាំងពីរប្រភេទនេះប៉ុណ្ណោះ។ និយាយជារួមមក វិសាលភាពនៃការសិក្សារបស់យើងខ្ញុំគឺ “ប្រទេសកម្ពុជា ព្រមទាំងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦” ។

ទាក់ទងទៅនឹងវិធីសាស្ត្រនៃការស្រាវជ្រាវវិញ យើងខ្ញុំពឹងផ្អែកខ្លាំងទៅលើការសិក្សាផ្អែកទ្រឹស្តី ជាពិសេសគឺទៅលើច្បាប់ និងបទដ្ឋានគតិយុត្តដែលកំពុងនៅជាធរមាន ក្រៅពីនេះក៏មានស្នាដៃស្រាវជ្រាវ ចងក្រងនិពន្ធរបស់លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកសិក្សានានា ដែលយើងប្រមែប្រមូលមកពីបណ្ណាល័យ បណ្ណាគារ តូបសៀវភៅ ក៏ដូចជាតាមប្រព័ន្ធអ៊ីនធើណេតផងដែរ។ រីឯការអនុវត្តជាក់ស្តែងវិញ យើងខ្ញុំព្យាយាមស្រាវជ្រាវ និងលើកយកមកជាមូលដ្ឋានខ្លះៗផងដែរ តាមរយៈការអង្កេតទៅលើតថភាពសង្គមជាក់ស្តែង ការសាកសួរទៅកាន់អ្នកអនុវត្តច្បាប់ បន្ទាប់មកចងក្រងព័ត៌មានទាំងនោះ។

ដើម្បីជាភាពងាយស្រួលដល់ការសិក្សា យើងខ្ញុំបានធ្វើការប្រៀបធៀបនូវសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះដោយបែងចែកជា៣ជំពូកដូចតទៅ៖

- ❖ ជំពូកទី១ សញ្ញាណទូទៅ
- ❖ ជំពូកទី២ ការបង្កើត អានុភាព និងការរលត់
- ❖ ជំពូកទី៣ នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ។

# ជំពូកទី១

# សញ្ញាណក្ដៅ

# ជំពូកទី១

# សញ្ញាណទូទៅ

ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ គឺជាសិទ្ធិប្រាតិភោគប្រត្យក្ស ដែលជាមែកធាងមួយនៃសិទ្ធិប្រត្យក្ស។ ក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បញ្ញត្តិស្តីពីហ៊ីប៉ូតែកត្រូវបានចែងនៅក្នុង ជំពូកទី៥ នៃគន្ថីទី៦ រីឯបញ្ញត្តិស្តីពីការបញ្ចាំអចលនវត្ថុវិញ ត្រូវបានចែងនៅក្នុងផ្នែកទី៣ នៃជំពូកទី៤ នៃគន្ថីទី៦ ។ មុននឹងឈានទៅសិក្សាអំពីខ្លឹមសារស៊ីជម្រៅនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ យើងខ្ញុំសូមធ្វើការបង្ហាញជូននូវសញ្ញាណទូទៅជុំវិញសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះជាមុនសិន ដែលយើងខ្ញុំនឹងរៀបរាប់អំពីការវិវត្តន៍នៃបទដ្ឋានគតិយុត្ត អត្ថន័យ លក្ខណៈទូទៅ និងកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ។

## ១.១.ការវិវត្តន៍នៃបទដ្ឋានគតិយុត្តទាក់ទងនឹងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុនៅកម្ពុជា

ប្រតិបត្តិការនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុមានអាយុកាលចំណាស់ណាស់ទៅហើយនៅក្នុងប្រព័ន្ធនៃនីតិខ្មែរ។ ជាក់ស្តែងប្រព័ន្ធនៃប្រតិបត្តិការធានាទាំងពីរនេះត្រូវបានបញ្ញត្តិយ៉ាងជាក់ច្បាស់ក្នុងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ១៩២០។ តាមរយៈមាត្រា១៣១២នៃច្បាប់នេះ បានបញ្ញត្តិបែងចែកកិច្ចធានាជាពីរបែប គឺប្រាតិភោគបុគ្គល (កិច្ចធានាដោយបុគ្គល) និងប្រាតិភោគប្រត្យក្ស(កិច្ចធានាដោយទ្រព្យ)។ ប្រាតិភោគប្រត្យក្សនេះបែងចែកជាពីរប្រភេទបន្តទៀត គឺការបញ្ចាំ និងហ៊ីប៉ូតែក។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ បានចែងអំពីការបញ្ចាំដោយខ្លឹមសារពិស្តារ ប៉ុន្តែបញ្ញត្តិស្តីពីហ៊ីប៉ូតែកវិញគឺចែងដោយសង្ខេបខ្លី ពោលគឺមានតែ៣មាត្រាប៉ុណ្ណោះ។

ជាបន្ទាប់មកទៀត យើងឃើញមានក្រឹត្យច្បាប់លេខ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ដែលមានចែងផងដែរអំពីប្រតិបត្តិការធានា ប៉ុន្តែប្រតិបត្តិការធានាដែលមានចែងក្នុងក្រឹត្យច្បាប់នេះ យើងសង្កេតឃើញមានតែពីរប៉ុណ្ណោះ គឺការបញ្ចាំចលនវត្ថុ និងកិច្ចធានាដោយបុគ្គល ដោយពុំឃើញមានវត្តមាននៃការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែកឡើយ ព្រោះក្នុងដំណាក់កាលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ គឺជាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាន់យកសេដ្ឋកិច្ចផែនការ ដីធ្លីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ ជនណាក៏ដោយគ្មានសិទ្ធិទិញ លក់ បញ្ចាំ ឬប្រវាស់ដីធ្លីបានឡើយ។[1]

លុះដល់ឆ្នាំ១៩៨៩ កំណែទម្រង់រដ្ឋចាប់ផ្តើម ដោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ប្តូរមកជារបបសេដ្ឋកិច្ចទីផ្សារសេរី និងបើកឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីឡើងវិញ។ វត្តមាននៃការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែកក៏បានលេចរូបរាងឡើងជាថ្មីម្តងទៀតនៅក្នុងក្រឹត្យលេខ ១០០ ក្រ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល ចុះថ្ងៃទី

[1] មាត្រា១៤ និងមាត្រា១៧ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨១

១៣ ខែតុលា ឆ្នាំ១៩៩២ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា។ អ្វីដែលគួរជាទីកត់សម្គាល់នោះគឺ បញ្ញត្តិស្តីពីហ៊ីប៉ូតែកដែលចែងនៅក្នុងច្បាប់នេះមានលក្ខណៈពិស្តារជាងមុន បើធៀបជាមួយក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ១៩២០ ដោយនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីហ៊ីប៉ូតែកគឺមាន៧មាត្រា។ ជាពិសេសទៅទៀតនោះគឺមានរបស់ដ៏ធំមួយដែលពុំមានចែងក្នុងច្បាប់ឆ្នាំ១៩២០ មាត្រា១៦៨នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ចែងថា *គេអាចដាក់ហ៊ីប៉ូតែកច្រើនដងបន្តបន្ទាប់គ្នាលើអចលនវត្ថុតែមួយក្នុងរយៈពេលតែមួយអោយម្ចាស់បំណុលច្រើននាក់។ ម្ចាស់បំណុលម្នាក់ៗមានសិទ្ធិតាមលំដាប់បុរិមានៃការប្រថាប់ត្រា* ។ តាមរយៈបញ្ញត្តិនេះ កូនបំណុលម្នាក់អាចយកអចលនវត្ថុតែមួយទៅដាក់ហ៊ីប៉ូតែកចំពោះម្ចាស់បំណុលច្រើននាក់បានក្នុងពេលតែមួយ ហើយម្ចាស់បំណុលនីមួយៗទទួលបានសិទ្ធិសងបំណុលនៅពេលលក់អចលនវត្ថុ តាមលំដាប់នៃការបង្កើតហ៊ីប៉ូតែក ពោលគឺម្ចាស់បំណុលណាបង្កើតហ៊ីប៉ូតែកមុន ម្ចាស់បំណុលនោះនឹងទទួលបានការសងជាមុន។

របត់នយោបាយកម្ពុជាវិវត្តន៍ទៅមុខឈានចូលដល់របប ព្រះរាជាណាចក្រកម្ពុជាទី២ សម័យកាលនេះកម្ពុជាចាប់ផ្តើមអភិវឌ្ឍបន្តិចម្តងៗលើគ្រប់វិស័យ ការកសាងប្រព័ន្ធតតិយុត្តនៅកម្ពុជាក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ដែរ។ ព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល បានចូលមកជំនួសច្បាប់ភូមិបាលឆ្នាំ១៩៩២។ ច្បាប់ភូមិបាលឆ្នាំ២០០១ នេះមានចែងអំពីការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែកដូចគ្នា អ្វីដែលខុសគ្នាខ្លាំងជាមួយនឹងច្បាប់ភូមិបាលឆ្នាំ១៩៩២នោះគឺ ច្បាប់ភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិពីប្រតិបត្តិការធានាមួយប្រភេទទៀតលើសពីច្បាប់ភូមិបាលឆ្នាំ១៩៩២ នោះគឺការដាក់ធានា។ ផ្អែកតាមមាត្រា២១៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលផ្តល់និយមន័យដល់ការដាក់ធានា យើងអាចយល់បានថា ការដាក់ធានាគឺមានលក្ខណៈស្រដៀងនឹងហ៊ីប៉ូតែកដែរ ដោយកូនបំណុលមិនចាំបាច់ផ្ទេរការកាន់កាប់អចលនវត្ថុដល់ម្ចាស់បំណុលឡើយ ពោលគឺកូនបំណុលនៅតែអាចប្រើប្រាស់ អាស្រ័យផលពីអចលនវត្ថុនោះបានដដែល ប៉ុន្តែអ្វីដែលខុសគ្នានោះគឺការដាក់ធានា កូនបំណុលត្រូវតម្កល់ប័ណ្ណកម្មសិទ្ធិនៃអចលនវត្ថុនៅម្ចាស់បំណុល ហើយហ៊ីប៉ូតែកមិនចាំបាច់ធ្វើដូច្នេះទេ។

ក្រោយមកទៀត ដោយមានកិច្ចសហប្រតិបត្តិការពីប្រទេសជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ថា JICA ក្រមរដ្ឋប្បវេណីថ្មីមួយបានបង្កើតឡើង និងត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺជានវានុវត្តន៍នៃច្បាប់ស៊ីវិលដ៏គួរឱ្យកត់សម្គាល់នៅក្នុងប្រវត្តិនីតិខ្មែរ។ បើនិយាយពីប្រតិបត្តិការធានាវិញ ក្រមនេះក្រៅពីរក្សានូវកិច្ចធានាជាលក្ខណៈប្រពៃណីនៅក្នុងនីតិរដ្ឋប្បវេណីខ្មែរដូចជាការបញ្ចាំ(ទាំងចលនវត្ថុ និងអចលនវត្ថុ) និងហ៊ីប៉ូតែក លើសពីនេះក៏បានបញ្ចូលនូវកិច្ចធានាថ្មីៗជាច្រើនទៀតដែលពុំធ្លាប់មានវត្តមាននៅក្នុងនីតិ

រដ្ឋប្បវេណីខ្មែរ ដែលមានដូចជាសិទ្ធិឃាត់ទុក ឯកសិទ្ធិ និងប្រាតិភោគដោយអនុប្បទាន។ ប៉ុន្តែការដាក់ធានាដែលមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ពុំត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ទៀតទេ។ ដូច្នេះមានសំណួររបស់អ្នកសិក្សាជាច្រើនបានលើកឡើងថា តើការដាក់ធានាដែលបានបង្កើតឡើងស្របតាមបញ្ញត្តិនៃច្បាប់ភូមិបាលឆ្នាំ២០០១ មុនការប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវចាត់ចែងយ៉ាងដូចម្តេចក្រោយការចូលជាធរមាននៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧? សំណួរនេះត្រូវបានឆ្លើយដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ត្រង់មាត្រា៥៥ ពោលគឺការដាក់ធានាទាំងឡាយណាដែលស្របនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវចាត់ទុកជាហ៊ីប៉ូតែកតាមក្រមរដ្ឋប្បវេណីក្រោយការអនុវត្តក្រមនេះ ហើយម្ចាស់សិទ្ធិលើការដាក់ធានាស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវប្រគល់ប័ណ្ណកម្មសិទ្ធិទៅឱ្យអ្នកបង្កើតវិញភ្លាមក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រម។

ជារួមមក ការបញ្ចាំអចលនវត្ថុ និងហ៊ីប៉ូតែកបានឆ្លុះបញ្ចាំងក្នុងទិដ្ឋភាពច្បាប់តាំងពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មកម្ល៉េះ ហើយបាត់មុខមួយរយៈក្នុងនីតិខ្មែរដោយសារតែរបបនយោបាយដែលកម្ពុជាប្រកាន់យក។ បន្ទាប់មកទៀតវាបានលេចវត្តមាននៅក្នុងច្បាប់ភូមិបាលទាំងពីរលើក ពោលគឺឆ្នាំ១៩៩២ និងឆ្នាំ២០០១ ហើយជាចុងក្រោយគឺត្រូវបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ យើងឃើញថាពីមួយដំណាក់កាលទៅមួយដំណាក់កាល បញ្ញត្តិស្តីពីកិច្ចធានាទាំងពីរប្រភេទនេះ ត្រូវបានធ្វើការវិវត្តន៍ឱ្យកាន់តែច្បាស់លាស់ និងពិស្តារឡើង ព្រមទាំងសម្របទៅតាមបរិបទសង្គមនៃសម័យកាលនីមួយៗ ជាពិសេសគឺនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

បន្ទាប់ពីសិក្សាអំពីការវិវត្តន៍នៃបទដ្ឋានគតិយុត្តទាក់ទងនឹងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុរួចមក យើងនឹងបន្តទៅសិក្សាអំពីអត្ថន័យនៃប្រតិបត្តិការធានាទាំងពីរប្រភេទនេះឱ្យបានពិស្តារ។

## ១.២.អត្ថន័យនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

ក្នុងផ្នែកនេះ យើងខ្ញុំនឹងធ្វើការសិក្សាអំពីអត្ថន័យនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុដាច់ដោយឡែកពីគ្នា បន្ទាប់មកដោយផ្អែកលើអត្ថន័យនេះ យើងខ្ញុំនឹងធ្វើការប្រៀបធៀបអំពីភាពដូច និងខុសគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ។

### ១.២.១.អត្ថន័យនៃហ៊ីប៉ូតែក

*ហ៊ីប៉ូតែកគឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយប្រភេទ ដែលម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបាន*

*ដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនមិនផ្ទេរការកាន់កាប់* ។[2] ផ្អែកតាមនិយមន័យនេះ យើងឃើញថា ហ៊ីប៉ូតែក គឺជាសិទ្ធិប្រាតិភោគប្រត្យក្សមួយដែលកើតឡើងដោយបុគ្គលម្នាក់ជាកូនបំណុល ឬតតិយជន បានយកអចលនវត្ថុរបស់ខ្លួនទៅដាក់ធានាលើបំណុលចំពោះម្ចាស់បំណុល ដោយមិនមានការផ្ទេរការកាន់កាប់អចលនវត្ថុនោះទេ ពោលគឺកូនបំណុល ឬតតិយជនដែលជាកម្មសិទ្ធិករនៃអចលនវត្ថុនោះនៅតែអាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះបានដដែល។ មិនត្រឹមតែមិនចាំបាច់ផ្ទេរការកាន់កាប់ទេ កូនបំណុល ឬតតិយជនក៏មិនចាំបាច់ប្រគល់ប័ណ្ណកម្មសិទ្ធិដល់ម្ចាស់បំណុលដែរ។ ហើយក្នុងករណីដែលដល់កាលកំណត់សងហើយ កូនបំណុលមិនបានសងនូវបំណុលនោះ ឬសងមិនគ្រប់ចំនួន ម្ចាស់បំណុលហ៊ីប៉ូតែកអាចអះអាងអំពីសិទ្ធិរបស់ខ្លួន និងសុំឱ្យតុលាការអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ ហើយប្រាក់ដែលបានមកពីការលក់ដោយបង្ខំត្រូវសងទៅម្ចាស់បំណុលហ៊ីប៉ូតែកជាអាទិភាពមុនម្ចាស់បំណុលដទៃទៀត។

ឧទាហរណ៍ **ក** ជំពាក់បំណុល **ខ** ចំនួន១.០០០ដុល្លារ។ **ក** មានដីមួយកន្លែងតម្លៃ១.២០០ដុល្លារ។ **ក** បានព្រមព្រៀងយកដីនេះដាក់ជាប្រាតិភោគដើម្បីធានាបំណុលរបស់ **ខ** ដោយមិនផ្ទេរការកាន់កាប់ដីនេះឱ្យទៅ **ខ** ទេ រូបភាពនេះគឺជាហ៊ីប៉ូតែក។ **ក** ក៏បានជំពាក់បំណុល **គ** ម្នាក់ទៀតផងដែរ ក្នុងទំហំទឹកប្រាក់៣០០ដុល្លារ ប៉ុន្តែមិនបានបង្កើតហ៊ីប៉ូតែកទេ។ ឧបមាថាដល់ថ្ងៃកំណត់សងចំពោះបំណុលទាំងពីរហើយ តែ **ក** មិនមានប្រាក់សងចំពោះម្ចាស់បំណុលទាំងពីរនេះទេ ដូច្នេះ **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកអាចដាក់ពាក្យសុំទៅតុលាការអោយអនុវត្តដោយបង្ខំចំពោះដីនេះបាន។ សន្មតថាដីនេះលក់បានតម្លៃ១.២០០ដុល្លារ ដូចនេះប្រាក់ចំនួន១.០០០ដុល្លារដែលបានមកពីការលក់ដោយបង្ខំត្រូវសងទៅម្ចាស់បំណុល **ខ** ជាមុនសិន ហើយនៅសល់២០០ដុល្លារទើបសងទៅម្ចាស់បំណុល **គ**។ បានជាបែងចែកបែបនេះ ព្រោះ **ខ** ជាម្ចាស់បំណុលហ៊ីប៉ូតែកដែលមានសិទ្ធិទទួលបានការសងជាអាទិភាពមុនម្ចាស់បំណុលដទៃទៀត រីឯ **គ** គឺជាម្ចាស់បំណុលធម្មតាតែប៉ុណ្ណោះ។

### ១.២.២.អត្ថន័យនៃការបញ្ចាំអចលនវត្ថុ

អត្ថន័យនៃការបញ្ចាំវិញ មានចែងនៅក្នុងមាត្រា៨១៦ នៃក្រមរដ្ឋប្បវេណីដោយបញ្ញត្តិថា *ម្ចាស់សិទ្ធិលើការបញ្ចាំ មានសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុលឬតតិយជន ដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។* យោងតាមអត្ថន័យនេះ យើងអាចទាញបានថា ការបញ្ចាំអចលនវត្ថុគឺជាសិទ្ធិប្រាតិភោគមួយប្រភេទ ដែលកើត

[2] មាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ឡើងដោយកូនបំណុល ឬតតិយជនបានយកអចលនវត្ថុរបស់ខ្លួនទៅដាក់ធានាឱ្យម្ចាស់បំណុល ដោយត្រូវផ្ទេរនូវការកាន់កាប់អចលនវត្ថុដល់ម្ចាស់បំណុល ពោលគឺកូនបំណុល ឬតតិយជនមិនមានសិទ្ធិប្រើប្រាស់ ឬអាស្រ័យផលលើអចលនវត្ថុនោះទៀតទេ។ *ការផ្ទេរការកាន់កាប់នេះគឺមានលក្ខណៈដាច់ខាត* ។[3] ហើយក្នុងករណីដែលកូនបំណុលមិនមានប្រាក់សងម្ចាស់បំណុលទេ ម្ចាស់បំណុលដែលមានសិទ្ធិលើការបញ្ចាំនេះអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះបាន ហើយប្រាក់ដែលបានមកពីការលក់ដោយបង្ខំត្រូវសងជាអាទិភាពដល់ម្ចាស់សិទ្ធិលើការបញ្ចាំ។

ឧទាហរណ៍ថា **ក** ខ្ចីប្រាក់ **ខ** ចំនួន១.០០០ដុល្លារ ហើយដើម្បីធានាសិទ្ធិលើបំណុលរបស់ **ខ** បុគ្គល **ក** បានយកដីរបស់ខ្លួនតម្លៃ១.១០០ដុល្លារ ដាក់ជាប្រាតិភោគឱ្យ **ខ** ដោយបានផ្ទេរការកាន់កាប់ដីនេះឱ្យ **ខ** ផងដែរ ពោលគឺ **ក** មិនមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើដីនេះទៀតទេ។ រូបភាពនៃប្រាតិភោគនេះគឺជាការបញ្ចាំអចលនវត្ថុ។

### ១.២.៣.ប្រៀបធៀបអត្ថន័យ

សរុបមក ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុមានលក្ខណៈដូចគ្នាច្រើន រហូតធ្វើឱ្យអ្នកសិក្សាមួយចំនួនមិនអាចញែកដាច់រវាងសិទ្ធិប្រាតិភោគទាំងពីរនេះបាន។ ផ្អែកតាមអត្ថន័យខាងលើ យើងឃើញថា ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុមានលក្ខណៈដូចគ្នាជាអាទិ៍ដូចជា សុទ្ធតែជាសិទ្ធិប្រាតិភោគប្រត្យក្ស, កម្មវត្ថុជាអចលនវត្ថុ, ហើយអចលនវត្ថុនោះទៀតសោតអាចជាកម្មសិទ្ធិកូនបំណុលផ្ទាល់ ឬតតិយជនក៏បាន, ម្ចាស់បំណុលមានសិទ្ធិទទួលបានការសងជាអាទិភាពមុនម្ចាស់បំណុលដទៃទៀត។ រីឯចំណុចខុសគ្នានោះគឺ ចំពោះហ៊ីប៉ូតែក កូនបំណុល ឬអ្នកធានាដោយវត្ថុមិនចាំបាច់ផ្ទេរការកាន់កាប់អចលនវត្ថុទៅឱ្យម្ចាស់បំណុលទេ ពោលគឺពួកគេនៅតែអាចប្រើប្រាស់ អាស្រ័យផលលើអចលនវត្ថុនោះបានដូចធម្មតាដដែល ចំណែកឯការបញ្ចាំអចលនវត្ថុវិញគឺផ្ទុយស្រលះពីនេះ កូនបំណុល ឬអ្នកធានាដោយវត្ថុដាច់ខាតត្រូវតែផ្ទេរការកាន់កាប់អចលនវត្ថុនោះទៅឱ្យម្ចាស់បំណុល លុះដល់ខ្លួនបានសងបំណុលគ្រប់គ្រាន់រួចរាល់ ទើបម្ចាស់បំណុលមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការផ្ទេរអចលនវត្ថុនោះឱ្យកូនបំណុលវិញ។

## ១.៣.លក្ខណៈនៃសិទ្ធិប្រាតិភោគ

ដោយសារតែលក្ខណៈដូចដែលបានរៀបរាប់ខាងក្រោមនេះ គឺជាលក្ខណៈរួមនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ(ហ៊ីប៉ូតែក និងការបញ្ចាំ) ដូច្នេះយើងខ្ញុំនឹងធ្វើអត្ថាធិប្បាយជារួមតែម្តង។

[3] មាត្រា៨១៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ១.៣.១.ទំនាក់ទំនងនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល

#### ១.៣.១.១.ភាពបន្ទាប់បន្សំនៃសិទ្ធិប្រាតិភោគ

សិទ្ធិប្រាតិភោគត្រង់នេះគឺចង់សម្ដៅដល់ហ៊ីប៉ូតែក និងសិទ្ធិលើការបញ្ចាំ។ តាមទ្រឹស្ដីនៃកិច្ចសន្យាគោល និងកិច្ចសន្យាបន្ទាប់បន្សំ ប្រសិនបើកិច្ចសន្យាគោលត្រូវបានរំលាយ លុបចោល ឬមោឃៈ វានឹងជះឥទ្ធិពលដល់កិច្ចសន្យាបន្ទាប់បន្សំ ពោលគឺកិច្ចសន្យាបន្ទាប់បន្សំនឹងត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិដែរ។ ត្រង់នេះសិទ្ធិលើបំណុលគឺជាកិច្ចសន្យាគោល រីឯហ៊ីប៉ូតែក និងសិទ្ធិលើការបញ្ចាំគឺជាកិច្ចសន្យាបន្ទាប់បន្សំ ដូច្នេះក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវបានរំលាយ លុបចោល មោឃៈ ឬ រលត់ ដោយមូលហេតុផ្សេងៗ នោះហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុក៏នឹងបាត់បង់អានុភាពដែរ។ ចំណុចនេះគឺមានចែងយ៉ាងច្បាស់ផងដែរក្នុងមាត្រា ៧៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ឧទាហរណ៍ទី១ **ក** (អ្នកលក់) និង **ខ** (អ្នកទិញ) បានបង្កើតកិច្ចសន្យាលក់ទិញដី ដោយក្នុងនោះ **ខ** បានដាក់ហ៊ីប៉ូតែកនូវដីរបស់ខ្លួនមួយកន្លែងដើម្បីធានាកាតព្វកិច្ចថ្លៃទិញចំពោះ **ក** ប៉ុន្តែក្រោយមក **ខ** បានលុបចោលកិច្ចសន្យាលក់ទិញវិញ ដោយសារមានការភាន់ច្រឡំ។ ការលុបចោលនេះ នាំឱ្យកិច្ចសន្យាលក់ទិញគ្មានអានុភាព ហេតុនេះហ៊ីប៉ូតែកក៏បាត់បង់អានុភាពតាមនោះដែរ។

ឧទាហរណ៍ទី២ **ក** បានយកផ្ទះរបស់ខ្លួនទៅដាក់បញ្ចាំឱ្យ **ខ** ដើម្បីធានាសិទ្ធិលើបំណុលក្នុងតម្លៃ ២០.០០០ដុល្លារអាមេរិក។ ក្រោយមកសិទ្ធិលើបំណុលដែល **ខ** មានលើ **ក** ត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល។ ការរលត់នៃសិទ្ធិលើបំណុលនេះនាំឱ្យសិទ្ធិលើការបញ្ចាំអចលនវត្ថុក៏ត្រូវបាត់បង់អានុភាពដែរ។ **ខ** ត្រូវប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំឱ្យទៅ **ក** វិញដោយពេញច្បាប់។

#### ១.៣.១.២.ភាពទៅជាមួយគ្នានៃសិទ្ធិប្រាតិភោគ

ក្នុងករណីដែលសិទ្ធិលើបំណុលដែលត្រូវបានធានាត្រូវបានផ្ទេរ នោះសិទ្ធិប្រាតិភោគប្រត្យក្ស (ត្រង់នេះសម្ដៅលើហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ) ក៏ត្រូវបានផ្ទេរទៅឱ្យអ្នកដែលទទួលសិទ្ធិលើបំណុលនោះដែរ លើកលែងតែមានការព្រមព្រៀងពិសេសផ្សេងពីនេះ។[4]

ឧទាហរណ៍ **ក** (ជាម្ចាស់បំណុល) និង **ខ** (ជាកូនបំណុល) ក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានតម្លៃ ១០.០០០ដុល្លារ។ **ខ** បានយកអចលនវត្ថុទៅដាក់ហ៊ីប៉ូតែកដើម្បីធានាសិទ្ធិលើបំណុលរបស់ **ក**។ នៅថ្ងៃមួយ **ក** ត្រូវការប្រាក់បន្ទាន់ ប៉ុន្តែ **ក** មិនអាចទារប្រាក់ពី **ខ** ឡើយ ព្រោះកាលកំណត់សងមិនទាន់មកដល់ ដូច្នេះ **ក**

---

[4]កថាខណ្ឌទី១ មាត្រា៧៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សម្រេចលក់សិទ្ធិលើបំណុលរបស់ខ្លួនឱ្យទៅ **គ**។ ការផ្ទេរអនុប្បទានសិទ្ធិលើបំណុលនេះ មានអានុភាពផ្ទេរហ៊ីប៉ូតែកទៅឱ្យ **គ** ផងដែរ លើកលែងតែ **ក** និង **គ** បានព្រមព្រៀងគ្នាពិសេសផ្សេងពីនេះ។

**១.៣.១.៣.ភាពអវិភាគនៃសិទ្ធិប្រាតិភោគ**

សិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើតឡើងដើម្បីធានាសិទ្ធិលើបំណុល រហូតដល់ម្ចាស់សិទ្ធិប្រាតិភោគទទួលបានសំណងនៃសិទ្ធិលើបំណុលទាំងអស់។ ដូច្នេះក្នុងករណីដែលសិទ្ធិលើបំណុលមិនទាន់បានសងអស់ទេ ម្ចាស់សិទ្ធិប្រាតិភោគអាចអនុវត្តសិទ្ធិប្រាតិភោគរបស់ខ្លួនបានទាំងស្រុងលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគនោះ ទោះជាសិទ្ធិលើបំណុលដែលមិនទាន់សងមានទំហំតូចយ៉ាងណាក៏ដោយ។[5]

ឧទាហរណ៍ **ក** (ជាម្ចាស់បំណុល) និង **ខ** (កូនបំណុល) ក្នុងកិច្ចសន្យាខ្ចីបរិភោគតម្លៃ១០.០០០ដុល្លារ ដោយ **ខ** បានដាក់ដីមួយកន្លែងរបស់ខ្លួនជាហ៊ីប៉ូតែកដើម្បីធានាបំណុល។ លុះដល់ថ្ងៃកំណត់សង **ខ** បានសងប្រាក់ **ក** ចំនួន៨.០០០ដុល្លារ ពោលគឺនៅខ្វះ២.០០០ដុល្លារទៀត។ ក្នុងករណីនេះ **ក** នៅតែអាចអនុវត្តហ៊ីប៉ូតែករបស់ខ្លួនលើដីនេះបានដោយពេញលេញទាំងស្រុង ពោលគឺសិទ្ធិហ៊ីប៉ូតែកលើដីនោះមិនមានការរួមតូចនោះទេ។

**១.៣.២.ទំនាក់ទំនងនៃសិទ្ធិប្រាតិភោគ និងអចលនវត្ថុជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ**

**១.៣.២.១.អានុភាពតាមនៃសិទ្ធិប្រាតិភោគ**

អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុ ទោះបីជាអចលនវត្ថុនោះត្រូវបានកម្មសិទ្ធិករផ្ទេរអនុប្បទានទៅឱ្យតតិយជនក៏ដោយ ក៏ហ៊ីប៉ូតែក និងសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅតែបន្តមានអត្ថិភាពលើអចលនវត្ថុនោះដដែល ពោលគឺម្ចាស់បំណុលហ៊ីប៉ូតែក ឬម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចអះអាងអំពីសិទ្ធិរបស់ខ្លួនចំពោះតតិយជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុនោះបាន[6] ។ ប៉ុន្តែមានលក្ខខណ្ឌមួយ នោះគឺម្ចាស់បំណុលហ៊ីប៉ូតែក និងម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវបំពេញលក្ខខណ្ឌតតាំងចំពោះតតិយជនឱ្យបានត្រឹមត្រូវ ពោលគឺត្រូវបង្កើតកិច្ចសន្យាក្នុងទម្រង់ជាលិខិតយថាភូត និងត្រូវចុះបញ្ជីសិទ្ធិប្រាតិភោគក្នុងសៀវភៅគោលបញ្ជីដីធ្លី ដែលយើងនឹងធ្វើការរៀបរាប់ដោយពិស្តារនៅចំណុចបន្តបន្ទាប់ទៀតអំពីបញ្ហាលក្ខខណ្ឌតតាំងនេះ។

ឧទាហរណ៍ **ខ** បានយកដី(L)មួយរបស់ខ្លួនដាក់ហ៊ីប៉ូតែកចំពោះ **ក** ដើម្បីធានាបំណុល។ ក្រោយមកទៀត **ខ** បានលក់ដីនេះឱ្យ **គ**។ ក្នុងករណីនេះប្រសិនបើ **ក** បានបំពេញលក្ខខណ្ឌតតាំង(លិខិតយថាភូត និងចុះបញ្ជី) នោះ **ក** អាចអះអាងអំពីសិទ្ធិប្រាតិភោគរបស់ខ្លួនចំពោះ **គ** (តតិយជនដែលបានធ្វើលទ្ធកម្ម)បាន។

[5] មាត្រា៧៧១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា៧៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្ទុយមកវិញ ប្រសិនបើ **ក** មិនបានបំពេញលក្ខខណ្ឌតតាំងឱ្យបានត្រឹមត្រូវទេ ដូចជាមានលិខិតយថាភូត ប៉ុន្តែមិនបានចុះបញ្ជីជាដើម នោះ **ក** មិនអាចអះអាងអំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគរបស់ខ្លួនចំពោះ **គ** បានឡើយ។

**១.៣.២.២.ការអនុវត្តសិទ្ធិប្រាតិភោគ**

ប្រសិនបើដល់ថ្ងៃកំណត់សងបំណុលហើយ កូនបំណុលមិនសង ឬមិនបានផ្តល់សំណងគ្រប់ជូនដល់ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគ(ហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុ) នោះម្ចាស់បំណុលអាចអនុវត្តសិទ្ធិប្រាតិភោគនេះតាមនីតិវិធីដូចដែលមានចែងក្នុងច្បាប់ជាធរមាន។[7] ការអនុវត្តសិទ្ធិប្រាតិភោគទាំងនេះ ម្ចាស់សិទ្ធិប្រាតិភោគមិនអាចអនុវត្តដោយខ្លួនឯងទេ គឺត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីអនុវត្តការលក់ដោយបង្ខំនូវអចលនវត្ថុនោះ រួចតុលាការនឹងយកប្រាក់ដែលបានមកពីការលក់ដោយបង្ខំមកសងម្ចាស់សិទ្ធិប្រាតិភោគដោយអាទិភាព។ នីតិវិធីនៃការអនុវត្តនេះនឹងត្រូវរៀបរាប់នៅជំពូក៣។

## **១.៤.កម្មវត្ថុ**

### **១.៤.១.កម្មវត្ថុនៃហ៊ីប៉ូតែក**

ផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ វត្ថុដែលអាចដាក់ជាហ៊ីប៉ូតែកបានមានដូចជា៖

**(ក) អចលនវត្ថុ**

មាត្រា៨៤៣នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា ម្ចាស់បំណុលមានសិទ្ធិទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត ចំពោះអចលនវត្ថុដែលបានដាក់ជាប្រាតិភោគនៃកាតព្វកិច្ច ដោយកូនបំណុល ឬតតិយជនមិនផ្ទេរការកាន់កាប់។ តាមអត្ថន័យនៃហ៊ីប៉ូតែកនេះ យើងឃើញថាកម្មវត្ថុនៃហ៊ីប៉ូតែកត្រូវតែជាអចលនវត្ថុ ដែលអចលនវត្ថុនេះទៀតសោតត្រូវតែជាកម្មសិទ្ធិ ឬចំណែកនៃកម្មសិទ្ធិអវិភាគរបស់កូនបំណុល ឬតតិយជន(អ្នកធានាដោយវត្ថុ)។

**(ខ) សិទ្ធិជួលអចិន្ត្រៃយ៍**

សិទ្ធិជួលអចិន្ត្រៃយ៍ក៏អាចជាកម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែកបានដែរ។ [8] សិទ្ធិជួលអចិន្ត្រៃយ៍សម្តៅទៅលើសិទ្ធិជួលអចលនវត្ថុរយៈពេលវែងចាប់ពី១៥ឆ្នាំឡើងទៅដល់៥០ឆ្នាំ។ [9] បានជាសិទ្ធិជួលអចិន្ត្រៃយ៍អាចដាក់ហ៊ីប៉ូតែកបាន ព្រោះសិទ្ធិជួលអចិន្ត្រៃយ៍ជាសិទ្ធិភ្ជាប់ទៅនឹងអចលនវត្ថុដែលមានតម្លៃជាសេដ្ឋកិច្ច ដែលអាចធ្វើអនុប្បទានបាន ម្យ៉ាងទៀតសិទ្ធិជួលអចិន្ត្រៃយ៍ដែលបង្កើតឡើងដោយបានចុះបញ្ជីត្រឹមត្រូវ ទោះបីជា

[7] មាត្រា៧៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] កថាខណ្ឌទី២ មាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[9] មាត្រា២៤៤ និងមាត្រា២៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍នោះត្រូវបានធ្វើអនុប្បទានទៅឱ្យតតិយជនក៏ដោយ ក៏សិទ្ធិជួលអចិន្ត្រៃយ៍នៅតែបន្តមានអត្ថិភាពលើអចលនវត្ថុនោះដដែល។

ឧទាហរណ៍ថា **ក** ជាម្ចាស់កម្មសិទ្ធិករនៃដីមួយកន្លែងបានជួលដីធ្លីឱ្យ **ខ** ក្នុងរយៈពេល៣០ឆ្នាំ។ ដូច្នេះ **ខ** អាចយកសិទ្ធិជួលអចិន្ត្រៃយ៍នេះទៅបង្កើតហ៊ីប៉ូតែកបាន ដើម្បីជាប្រាតិភោគធានាបំណុលរបស់ខ្លួន។

**(គ)ផលុបភោគ**

ផលុបភោគក៏អាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដែរ។[10] ផលុបភោគសម្តៅទៅលើសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី។[11] មូលហេតុដែលផលុបភោគអាចក្លាយជាកម្មវត្ថុនៃហ៊ីប៉ូតែកបានក៏មិនសូវខុសគ្នាប៉ុន្មានដែរពីសិទ្ធិជួលអចិន្ត្រៃយ៍ ពោលគឺជាសិទ្ធិដែលភ្ជាប់នឹងអចលនវត្ថុ អាចធ្វើអនុប្បទានបាន ហើយតតិយជនដែលធ្វើលទ្ធកម្មលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគក៏ត្រូវធ្វើលទ្ធកម្មនូវផលុបភោគផងដែរ។

**(ឃ) វត្ថុដែលកំណត់ដោយច្បាប់ពិសេស**

ជាគោលការណ៍ក្រមរដ្ឋប្បវេណីទទួលស្គាល់ការបង្កើតហ៊ីប៉ូតែកចំពោះអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ។ ប៉ុន្តែក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ផងដែរ ករណីដែលច្បាប់ពិសេសទទួលស្គាល់វត្ថុផ្សេងដទៃទៀត ដែលអាចយកមកធ្វើជាកម្មវត្ថុនៃហ៊ីប៉ូតែកបាន។

### ១.៤.២.កម្មវត្ថុនៃការបញ្ចាំអចលនវត្ថុ

ចំពោះការបញ្ចាំអចលនវត្ថុវិញ កម្មវត្ថុរបស់វាគឺជាអចលនវត្ថុនេះឯង។ សន្ធានុក្រមផ្នែករដ្ឋប្បវេណីបានផ្តល់និយមន័យដល់អចលនវត្ថុថាជា ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអគារ សំណង់ជាដើម។ មិនត្រឹមតែប៉ុណ្ណោះទេ សិទ្ធិជួលអចិន្ត្រៃយ៍[12] និងផលុបភោគ[13] ក៏អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំអចលនវត្ថុបានដែរ។

ꩨꩨꩨ📖ꩨꩨꩨ

[10] កថាខណ្ឌទី២ មាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា២៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[12] កថាខណ្ឌទី១ មាត្រា២៥២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[13] មាត្រា២៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី២

# ការបង្កើត អានុភាព

# និងការរលត់

# ជំពូកទី២

# ការបង្កើត អានុភាព និងការរលត់

នៅក្នុងជំពូកនេះ យើងខ្ញុំនឹងធ្វើការសិក្សា ក៏ដូចជាប្រៀបធៀបដោយស៊ីជម្រៅរវាង ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ។ ដោយជាដំបូងយើងនឹងផ្តើមការសិក្សាចេញពីការបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ រួមមានទាំងលក្ខខណ្ឌសុពលភាព និងលក្ខខណ្ឌតតាំង បន្ទាប់មក យើងនឹងសិក្សាអំពីអានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ ដែលកើតមានក្រោយការបង្កើត និងជាចុងក្រោយ យើងនឹងបកស្រាយអំពីការរលត់នៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ។

## ២.១.ការបង្កើតហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

### ២.១.១.លក្ខខណ្ឌសុពលភាពគូភាគី

#### ២.១.១.១.លក្ខខណ្ឌសុពលភាពនៃហ៊ីប៉ូតែក

លក្ខខណ្ឌសុពលភាពនៃហ៊ីប៉ូតែកសម្តៅលើលក្ខខណ្ឌដើម្បីធ្វើឱ្យកិច្ចសន្យាហ៊ីប៉ូតែកមានអានុភាពចំពោះគូភាគីនៃកិច្ចសន្យានោះ ពោលគឺមានអានុភាពលើម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលបានដាក់អចលនវត្ថុជាប្រាតិភោគ។ លក្ខខណ្ឌសុពលភាពនេះសំខាន់ណាស់ ប្រសិនបើមិនបានបំពេញតាមលក្ខខណ្ឌសុពលភាពនេះទេ កិច្ចសន្យាហ៊ីប៉ូតែកនឹងមិនបង្កើតអានុភាពឡើយ។

មាត្រា ៨៤៤ នៃក្រមរដ្ឋប្បវេណីបានចែងថា ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើងដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ។ ផ្អែកតាមមាត្រានេះ យើងឃើញថាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាហ៊ីប៉ូតែកគឺមានតែមួយប៉ុណ្ណោះ ពោលគឺការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលយកអចលនវត្ថុខ្លួនមកដាក់ប្រាតិភោគ។

មាត្រានេះពុំបានចែងអំពីលក្ខខណ្ឌទម្រង់ ដើម្បីកំណត់ថាជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាហ៊ីប៉ូតែកសម្រាប់គូភាគីឡើយ ពោលគឺគូភាគីមានសេរីភាពក្នុងការជ្រើសរើសទម្រង់នៃកិច្ចសន្យាដើម្បីបង្កើតកិច្ចសន្យាហ៊ីប៉ូតែករបស់ខ្លួន ដូចជាក្នុងទម្រង់ផ្ទាល់មាត់ លាយលក្ខណ៍អក្សរ ឬធ្វើជាលិខិតឯកជន លិខិតយថាភូតជាដើម។ ប៉ុន្តែទោះបីជាដូច្នេះក៏ដោយ ក៏គូភាគីគួរតែបង្កើតកិច្ចសន្យាហ៊ីប៉ូតែកក្នុងទម្រង់ជាលិខិតយថាភូតដែរ ដោយសំអាងលើហេតុផល៣យ៉ាង ទី១គឺងាយស្រួលក្នុងនីតិវិធីនៃការចុះបញ្ជីហ៊ីប៉ូតែក ប្រសិនបើគូភាគីបង្កើតត្រឹមកិច្ចសន្យាផ្ទាល់មាត់ ឬបង្កើតកិច្ចសន្យាលាយលក្ខណ៍អក្សរតែក្នុងទម្រង់ជាលិខិតឯកជន នោះនៅពេលដែលគូភាគីចង់យកទៅចុះបញ្ជីត្រូវធ្វើលិខិតយថាភូតសិន ដូច្នេះវានាំឱ្យខាតបង់ពេលវេលា និងចំណាយថវិកាច្រើនដង។ ហេតុផលទី២ គឺការបង្កើតកិច្ចសន្យាក្នុងទម្រង់យថាភូតគឺជាលក្ខខណ្ឌមួយនៃលក្ខខណ្ឌតតាំងហ៊ីប៉ូតែកចំពោះ

តតិយជន។ ហេតុផលទី៣ គឺក្នុងនីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក គឺតម្រូវឱ្យមានលិខិតអនុវត្ត ហើយលិខិតអនុវត្តមួយក្នុងចំណោមលិខិតអនុវត្តទាំងអស់ គឺជាលិខិតយថាភូតដែលធ្វើឡើងដោយសារការី។[14]

**២.១.១.២.លក្ខខណ្ឌសុពលភាពនៃការបញ្ចាំអចលនវត្ថុ**

មាត្រា៨១៨ នៃក្រមរដ្ឋប្បវេណីចែងថា សិទ្ធិលើការបញ្ចាំត្រូវកើតឡើង ដោយកូនបំណុល ឬតតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំ។

ផ្អែកតាមមាត្រានេះឃើញថា ក្រៅពីការព្រមព្រៀងរបស់គូភាគី នៅមានលក្ខខណ្ឌចាំបាច់មួយទៀតដើម្បីធ្វើឱ្យកិច្ចសន្យាបញ្ចាំមានសុពលភាព នោះគឺការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំធ្វើការកាន់កាប់ ដោយច្បាប់មិនអនុញ្ញាតឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំដោយផ្ទាល់នោះទេ។

ថ្វីត្បិតតែក្រមរដ្ឋប្បវេណីមិនបានកំណត់នូវទម្រង់កិច្ចសន្យាណាមួយជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបញ្ចាំក៏ដោយ ប៉ុន្តែកិច្ចសន្យាបញ្ចាំក៏គួរតែបង្កើតឡើងក្នុងទម្រង់ជាលិខិតយថាភូតដែរ ក្រោមហេតុផលដូចដែលបានបញ្ជាក់ក្នុងចំណុច ២.១.១.១.លក្ខខណ្ឌសុពលភាពនៃហ៊ីប៉ូតែក។

**២.១.២.លក្ខខណ្ឌតតាំង**

**២.១.២.១.លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក**

លក្ខខណ្ឌតតាំងគឺសម្តៅលើលក្ខខណ្ឌសម្រាប់ធ្វើការអះអាងអំពីអានុភាពចំពោះតតិយជនទាក់ទងទៅនឹងការបង្កើត ការផ្ទេរ និងការកែប្រែសិទ្ធិប្រត្យក្ស។ ឬនិយាយម្យ៉ាងទៀតដោយងាយយល់ថា លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក គឺជាលក្ខខណ្ឌដើម្បីធ្វើឱ្យហ៊ីប៉ូតែកមានអានុភាពចំពោះតតិយជន ក្រៅពីគូភាគីនៃកិច្ចសន្យាហ៊ីប៉ូតែក។

ឧទាហរណ៍ក្នុងស្ថានភាពដែលកូនបំណុលម្នាក់ជំពាក់បំណុលម្ចាស់បំណុលច្រើននាក់ក្នុងពេលតែមួយ ដូច្នេះដើម្បីអាចឱ្យម្ចាស់បំណុលហ៊ីប៉ូតែកអាចអះអាងនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះម្ចាស់បំណុលផ្សេងទៀតបាន នោះចាំបាច់ត្រូវបង្កើតហ៊ីប៉ូតែកឡើងដោយគោរពតាមលក្ខខណ្ឌតតាំងនេះ។ ឧទាហរណ៍មួយទៀត ក្នុងករណីដែលកូនបំណុលបានយកអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកលក់ទៅឱ្យតតិយជនណាម្នាក់ ដូច្នេះម្ចាស់បំណុលហ៊ីប៉ូតែកនឹងអាចអះអាងអំពីសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះអ្នកធ្វើលទ្ធកម្មកម្មសិទ្ធិបាន លុះត្រាតែបានបង្កើតហ៊ីប៉ូតែកឡើងដោយគោរពតាមលក្ខខណ្ឌតតាំង។

មាត្រា៨៤៥ នៃក្រមរដ្ឋប្បវេណីបានចែងថា ម្ចាស់បំណុលហ៊ីប៉ូតែកមិនអាចយកហ៊ីប៉ូតែកនោះមកតតាំងចំពោះតតិយជន ក្រៅពីអ្នកដែលបង្កើតហ៊ីប៉ូតែកបានឡើយ ប្រសិនបើមិនបានបង្កើតកិច្ចសន្យាហ៊ីប៉ូតែកនោះ

[14] មាត្រា៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដោយលិខិតយថាភូត និងមិនបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីទេ។ ផ្អែកតាមបញ្ញត្តិនេះ យើងអាចទាញបានថាលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកមានពីរគឺ ត្រូវបង្កើតកិច្ចសន្យាហ៊ីប៉ូតែកក្នុងទម្រង់ជាលិខិតយថាភូត និងយកទៅចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

លិខិតយថាភូតក្នុងកិច្ចសន្យាហ៊ីប៉ូតែក គឺជាលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីប្រើប្រាស់ក្នុងនីតិវិធីនៃការចុះបញ្ជី។[15] មន្ត្រីមានសមត្ថកិច្ចនៅទីនេះគឺសម្តៅលើរដ្ឋបាលឃុំសង្កាត់នៃទីតាំងអចលនវត្ថុ[16] និងរដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្ត[17]។ លើសពីនេះទៅទៀត បច្ចុប្បន្ននេះសិទ្ធិអំណាចក្នុងនាមជាមន្ត្រីមានសមត្ថកិច្ចនេះ ក៏ត្រូវបានផ្តល់ជូនទៅសារការី ដើម្បីចុះហត្ថលេខា និងប្រថាប់ត្រាលើកិច្ចសន្យារបស់គូភាគីផងដែរ។[18]

បន្ទាប់ពីបង្កើតកិច្ចសន្យាហ៊ីប៉ូតែកក្នុងទម្រង់លិខិតយថាភូតហើយ គូភាគីត្រូវយកទៅដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីរបស់រដ្ឋបាលសុរិយោដី។ រដ្ឋបាលសុរិយោដីដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក គឺរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត។ រដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត មានទីតាំងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានី ខេត្ត។ នៅពេលស្នើសុំចុះបញ្ជី គូភាគីត្រូវបំពេញពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដែលនឹងមានជូនភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃសារណាបទនេះ។

ការតម្រូវឱ្យចុះបញ្ជីយ៉ាងដូច្នេះ គឺដើម្បីជម្រាបដល់សាធារណជនឱ្យបានជ្រាបថា អចលនវត្ថុនេះបានជាប់ជាបន្ទុកនៃហ៊ីប៉ូតែកហើយ ដែលវានឹងបង្កើតអានុភាពចំពោះតតិយជន ដូចជាម្ចាស់បំណុលដទៃទៀត ឬជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុហ៊ីប៉ូតែកជាដើម។ ដូច្នេះមុននឹងឱ្យកូនបំណុលណាម្នាក់ខ្ចីលុយដោយដាក់អចលនវត្ថុជាប្រាតិភោគ ម្ចាស់បំណុលនោះអាចទៅឆែកមើលនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីសិន ថាតើអចលនវត្ថុនោះមានជាប់ហ៊ីប៉ូតែកដែរឬទេ បើជាប់បន្ទុកហ៊ីប៉ូតែក តើគួរឱ្យខ្ចីក្នុងទំហំប៉ុន្មាន ដែលអាចធានាលទ្ធភាពក្នុងការសងបាន។ រីឯអ្នកទិញអចលនវត្ថុក៏ដូចគ្នា អាចឆែកមើលមុននឹងសម្រេចចិត្តទិញអចលនវត្ថុនោះ ព្រោះអ្នកធ្វើលទ្ធកម្មកម្មសិទ្ធិបន្តត្រូវធ្វើលទ្ធកម្មលើអចលនវត្ថុដោយជាប់បន្ទុកហ៊ីប៉ូតែក ។

[15] កថាខណ្ឌ២ មាត្រា៩ នៃច្បាប់ស្តីពីការដាក់ឱ្យអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១

[16] ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ លេខ១៥៩ប្រក/ជនស/មថ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ប្រក/ជនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី

[17] ប្រការ៥ នៃប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

[18] ម៉ៅ សិលា, 《ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា》, ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ២០១៨, http://salatraju.com/post/349 , ចូលទស្សនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១

#### ២.១.២.២.លក្ខខណ្ឌតតាំងនៃការបញ្ចាំអចលនវត្ថុ

បើយើងសង្កេតមើលនៅក្នុងក្រមរដ្ឋប្បវេណី យើងពុំមានឃើញបទបញ្ញត្តិណាមួយនៃក្រមរដ្ឋប្បវេណីបានចែងអំពីលក្ខខណ្ឌតតាំងនៃការបញ្ចាំអចលនវត្ថុឡើយ។

ប៉ុន្តែ៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថា *ក្រៅពីបញ្ញត្តិនៃផ្នែកទី៣ (ការបញ្ចាំអចលនវត្ថុ) នេះ បញ្ញត្តិនៃជំពូកទី៥ (ហ៊ីប៉ូតែក) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ* ។ ផ្អែកតាមបញ្ញត្តិនេះមានន័យថា បញ្ញត្តិពាក់ព័ន្ធនឹងហ៊ីប៉ូតែកគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុ លើកលែងតែបញ្ញត្តិណាដែលផ្ទុយនឹងបញ្ញត្តិនៃផ្នែកទី៣ ស្តីពីការបញ្ចាំអចលនវត្ថុប៉ុណ្ណោះ។ ដូច្នេះ មាត្រា៨៤៥ នៃក្រមរដ្ឋប្បវេណី ស្តីពីលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកក៏ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការបញ្ចាំអចលនវត្ថុ នាំឱ្យលក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំអចលនវត្ថុមានពីរដែរ គឺត្រូវបង្កើតកិច្ចសន្យាក្នុងទម្រង់ជាលិខិតយថាភូត និងត្រូវយកទៅចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃរដ្ឋបាលសុរិយោដី។ ខ្លឹមសារពិស្តារនៃលិខិតយថាភូត និងការចុះបញ្ជីគឺមានលក្ខណៈដូចនឹងការពិពណ៌នាក្នុងចំណុច ២.១.២.១.លក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកខាងលើ។

## ២.២.អានុភាពនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

### ២.២.១.អានុភាពនៃហ៊ីប៉ូតែក

#### ២.២.១.១.ទំហំអានុភាពនៃហ៊ីប៉ូតែក

នៅពេលដែលហ៊ីប៉ូតែកបានបង្កើតឡើងនៅលើដីមួយកន្លែង ហ៊ីប៉ូតែកនោះមានអានុភាពលើវត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារដែលមាននៅលើដីហ៊ីប៉ូតែកនោះផងដែរ។[19] ពាក្យថា "ហ៊ីប៉ូតែកមានអានុភាព" ត្រង់នេះបញ្ជាក់អំពីទំហំទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលបានការសងបានដោយមានអាទិភាពពីប្រាក់ដែលបានមកពីការលក់ ក្នុងករណីដែលកូនបំណុលមិនបានសងបំណុល។[20] បានន័យថា ប្រសិនបើហ៊ីប៉ូតែកបានបង្កើតលើដីមួយ ហើយដល់ពេលកំណត់សងបំណុល ប៉ុន្តែកូនបំណុលមិនសង ឬសងមិនគ្រប់ចំនួននូវសិទ្ធិលើបំណុល នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចរឹបអូសដី និងវត្ថុទាំងឡាយដែលភ្ជាប់លើដីព្រមទាំងអាគារផងទៅលក់ដោយបង្ខំ ហើយទំហំទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកអាចទទួលបានការសងដោយអាទិភាពនោះគឺទំហំទឹកប្រាក់សរុបដែលបានមកពីការលក់ដី វត្ថុដែលភ្ជាប់នឹងដីនោះ រួមទាំងអាគារផងដែរ ពោលគឺមិនមែនកម្រិតត្រឹមតែទំហំទឹកប្រាក់ដែលបានមកពីការលក់ដីនោះទេ ទោះបីជាការដាក់ហ៊ីប៉ូតែកគឺដាក់ត្រឹមតែដីក៏ដោយ។

[19] វាក្យខណ្ឌ១ កថាខណ្ឌ១ មាត្រា៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[20] សេចក្តីកំណត់មាត្រា៨៤៦ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៤៖ គន្ថីទី៦, ឆ្នាំ២០១០

មួយវិញទៀត យើងដឹងហើយថាអ្នកបង្កើតហ៊ីប៉ូតែកនៅតែមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុជាកម្មវត្ថុនៃហ៊ីប៉ូតែកបានដដែល ដូចនេះអាចមានករណីថានៅពេលដែលបង្កើតហ៊ីប៉ូតែក ដីនោះគឺជាដីទទេ តែក្រោយពីបង្កើតហ៊ីប៉ូតែករួច អ្នកបង្កើតហ៊ីប៉ូតែកបានភ្ជាប់វត្ថុ ឬសង់អាគារនៅលើដីនោះ ដូច្នេះហ៊ីប៉ូតែកក៏មានអានុភាពទៅលើវត្ថុដែលបានភ្ជាប់ ឬអាគារដែលបានសាងសង់ឡើងក្រោយការបង្កើតហ៊ីប៉ូតែកផងដែរ។[21] លើសពីនេះទៀត ប្រសិនបើអ្នកបង្កើតហ៊ីប៉ូតែក ឬតតិយជនសាងសង់អាគារនៅលើដីហ៊ីប៉ូតែក ក្រោយការបង្កើតហ៊ីប៉ូតែក ហើយអ្នកបង្កើតហ៊ីប៉ូតែកមានកម្មសិទ្ធិលើអាគារនោះ នោះម្ចាស់បំណុលហ៊ីប៉ូតែកមានជម្រើសអាចទាមទារឱ្យវាយនូវអាគារនោះចោលបាន ដោយទុកតែដីហ៊ីប៉ូតែកដើម្បីលក់ដោយបង្ខំ ប្រសិនបើថ្លៃលក់អាគាររួមជាមួយនឹងដីនោះមានតម្លៃថោកជាងការលក់ដីទទេ។[22]

គំនិតទាំងនេះ គឺយោងទៅតាមមាត្រា១២២ នៃក្រមរដ្ឋប្បវេណី ដែលកំណត់ថា វត្ថុដែលនៅជាប់នឹងដី ឬវត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេសអាគារ ឬសំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬពូជដែលសាបនៅលើដី ដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី។

លើសពីនេះទៅទៀត អានុភាពដូចដែលបានបកស្រាយខាងលើនេះគឺមានលក្ខណៈអាជ្ញាបញ្ញាពោលគឺភាគីនៃកិច្ចសន្យាហ៊ីប៉ូតែកមិនអាចបង្កើតការព្រមព្រៀងផ្សេងពីនេះបានទេ។ [23] ចំណុចនេះគឺផ្ទុយទាំងស្រុងពីគោលគំនិតនៃក្រមរដ្ឋប្បវេណីជប៉ុន ពោលគឺនីតិរដ្ឋប្បវេណីជប៉ុនបានចាត់ទុកដី និងអាគារគឺជាអចលនវត្ថុផ្សេងគ្នា និងឯករាជ្យពីគ្នា ហើយហ៊ីប៉ូតែកដែលបង្កើតលើដី និងហ៊ីប៉ូតែកដែលបង្កើតលើអាគារគឺខុសគ្នា ដូច្នេះហ៊ីប៉ូតែកដែលបង្កើតលើដី គ្មានអានុភាពលើអាគារទេ ហើយហ៊ីប៉ូតែកលើអាគារក៏គ្មានអានុភាពលើដីដែរ។ ក្រមរដ្ឋប្បវេណីជប៉ុនក៏បានអនុញ្ញាតឱ្យគូភាគីនៃកិច្ចសន្យាហ៊ីប៉ូតែកមានសិទ្ធិកំណត់អំពីទំហំអានុភាពនៃហ៊ីប៉ូតែកទៀតផង។[24]

**២.២.១.២.អានុភាពនៃហ៊ីប៉ូតែកលើដីចំពោះអាគារដែលជាកម្មសិទ្ធិរបស់តតិយជន**

ក្នុងករណីដែលតតិយជនមានកម្មសិទ្ធិលើអាគារនៅលើដីដែលបានដាក់ជាហ៊ីប៉ូតែកដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬសិទ្ធិជួល ហ៊ីប៉ូតែកនោះពុំមានអានុភាពលើអាគារនោះឡើយ។[25] ក្រមរដ្ឋប្បវេណីខ្មែរអនុញ្ញាតឱ្យមានកម្មសិទ្ធិលើអាគារនៅលើដីដែលជាកម្មសិទ្ធិរបស់អ្នកដទៃ តាមរយៈសិទ្ធិជួល

[21] វាក្យខណ្ឌ២ កថាខណ្ឌ១ មាត្រា៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[22] កថាខណ្ឌទី១ មាត្រា៨៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[23] កថាខណ្ឌ២ មាត្រា៨៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[24] សេចក្តីកំណត់មាត្រា៨៤៦ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៤៖ គន្លឹទី៦, ឆ្នាំ២០១០

[25] មាត្រា៨៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អចិន្ត្រៃយ៍ ផលុបភោគជាអាទិ៍បាន ដូចមានចែងក្នុងមាត្រា១២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ បានន័យថា ក្នុងករណីដែលជនម្នាក់មានសិទ្ធិលើដីរបស់អ្នកដទៃដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគជាអាទិ៍ បន្ទាប់មកជននោះបានសាងសង់អាគារលើដីនោះ ដូច្នេះអាគារនោះនឹងក្លាយជាកម្មសិទ្ធិរបស់ជននោះ។ ដូចនេះ កូនបំណុលដែលយកដី ដោយនៅលើដីនោះមានអាគារជាកម្មសិទ្ធិរបស់តតិយជនដោយផ្អែកលើសិទ្ធិជួល អចិន្ត្រៃយ៍ ផលុបភោគជាអាទិ៍នោះ ទៅដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុលចំពោះម្ចាស់បំណុល ហ៊ីប៉ូតែកនឹងមិន បង្កើតអានុភាពលើអាគារនោះឡើយ។

តែក៏មានករណីអញ្ញត្រកម្មផងដែរ ពោលគឺប្រសិនបើកម្មសិទ្ធិករនៃអាគារនោះមិនអាចយកសិទ្ធិជួល អចិន្ត្រៃយ៍ ផលុបភោគ ឬសិទ្ធិជួល របស់ខ្លួនទៅតតាំងនឹងម្ចាស់បំណុលហ៊ីប៉ូតែកបានទេ នោះម្ចាស់បំណុល ហ៊ីប៉ូតែកអាចលក់ដោយបង្ខំទាំងដី និងអាគារបានផងដែរ។[26] ឧទាហរណ៍ថា អ្នកជួលអចិន្ត្រៃយ៍នោះមិនបានចុះ បញ្ជីឡើយ ដូច្នេះមិនអាចអះអាងអំពីសិទ្ធិជួលរបស់ខ្លួនចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបានឡើយ។

**២.២.១.៣.អានុភាពនៃហ៊ីប៉ូតែកចំពោះផល**

សិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុ មិនមានអានុភាពចំពោះផលដែលកើតចេញពីអចលនវត្ថុនោះទេ ទោះជា ផលស៊ីវិល ឬផលធម្មជាតិក៏ដោយ។[27] បញ្ញត្តិនេះគឺបង្កើតឡើងដើម្បីឱ្យស្របតាមបញ្ញត្តិដែលចែងថា អ្នកបង្កើត ហ៊ីប៉ូតែកមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក។ ផលស៊ីវិល គឺជាប្រាក់ ដូចជាប្រាក់ថ្លៃឈ្នួលជាអាទិ៍ ឬវត្ថុផ្សេងទៀតដែលទទួលជាថ្នូរចំពោះការប្រើវត្ថុណាមួយ។ រីឯផលធម្មជាតិវិញ គឺ ជាវត្ថុដែលបានកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្មតាមវិធីប្រើធម្មតារបស់វា ឧទាហរណ៍ដូចជាផ្លែឈើ បន្លែជា ដើម។ [28] ដូច្នេះក្នុងករណីដែលអ្នកបង្កើតហ៊ីប៉ូតែកបានដាំដំណាំលើដីដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ផលដែល ទទួលបានពីដំណាំ(ផលធម្មជាតិ)នោះត្រូវបានបង្កើតជាប្រយោជន៍ដល់អ្នកបង្កើតហ៊ីប៉ូតែក ករណីមួយទៀត អ្នកបង្កើតហ៊ីប៉ូតែកបានយកដីរបស់ខ្លួនទៅដាក់ជួលឱ្យតតិយជន ដូច្នេះប្រាក់ថ្លៃឈ្នួល(ផលស៊ីវិល)នោះនឹង ត្រូវបានជាប្រយោជន៍ដល់អ្នកបង្កើតហ៊ីប៉ូតែកដូចគ្នា។

មួយវិញទៀត មាត្រា៨៤៨ ត្រង់វាក្យខណ្ឌទី២ បានចែងកំណត់ពីពេលដែលសិទ្ធិអាស្រ័យផលត្រូវបាន កម្រិតគឺជាពេលដែលអចលនវត្ថុត្រូវបានរឹបអូស។ ពោលគឺហ៊ីប៉ូតែកនឹងបង្កើតអានុភាពលើផលចាប់ពី ពេលដែលអចលនវត្ថុហ៊ីប៉ូតែកត្រូវបានរឹបអូសក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។ នីតិវិធីដែលអនុវត្តចំពោះផល

[26] កថាខណ្ឌទី២ មាត្រា៨៥៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[27] វាក្យខណ្ឌទី១ មាត្រា៨៤៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[28] មាត្រា១២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រោយការរឹបអូសមានចែងក្នុងមាត្រា ៥១៦ (ការរឹបអូសសិទ្ធិលើបំណុលដែលជាថ្លៃឈ្នួលអចលនវត្ថុ) នៃក្រមនីតិវិធីរដ្ឋប្បវេណី។

### ២.២.១.៤.ឧបាទេសកម្មលើវត្ថុ

ហ៊ីប៉ូតែកជាសិទ្ធិដែលបានបង្កើតឡើងដើម្បីប្តូរទៅនឹងតម្លៃនៃកម្មវត្ថុជាក់លាក់ណាមួយ។ ដូច្នេះនៅពេលដែលអ្នកបង្កើតហ៊ីប៉ូតែកបានលក់អចលនវត្ថុរបស់ខ្លួនទៅឱ្យតតិយជន ឬអចលនវត្ថុនោះត្រូវបានបាត់បង់ ឬខូចខាតដោយកំហុសរបស់តតិយជន ម្ចាស់បំណុលហ៊ីប៉ូតែកអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះប្រាក់ ឬវត្ថុផ្សេងដទៃទៀតដែលជាតាវកាលិកតបនៃការលក់ ឬសំណងជួសជុលព្យសនៈកម្មដែលកើតចេញពីការខូចខាត ឬការបាត់បង់នោះ ដែលអ្នកបង្កើតហ៊ីប៉ូតែកត្រូវទទួល នេះគឺជាឧបាទេសកម្មលើវត្ថុ។[29] ការណ៍នេះគឺជារឿងសមហេតុសមផលបំផុត ព្រោះប្រាក់ ឬវត្ថុដទៃទៀតដែលកើតចេញពីការលក់ ការខូចខាត ឬការបាត់បង់អចលនវត្ថុហ៊ីប៉ូតែក គឺជាវត្ថុបម្លែងពីអចលនវត្ថុហ៊ីប៉ូតែកនោះ។

ប៉ុន្តែប្រសិនបើប្រាក់ត្រូវបានបង់ ឬវត្ថុដទៃទៀតនោះត្រូវបានប្រគល់ដល់ដៃអ្នកបង្កើតហ៊ីប៉ូតែកហើយ ម្ចាស់បំណុលហ៊ីប៉ូតែកពុំអាចអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនបានទៀតឡើយ។[30] ព្រោះហ៊ីប៉ូតែកត្រូវបានបង្កើតឡើងដើម្បីអនុវត្តទៅលើកម្មវត្ថុមួយជាក់លាក់ ប៉ុន្តែនៅក្រោយពេលដែលប្រាក់ ឬវត្ថុដទៃទៀតនោះបានបង់ ឬប្រគល់ដល់អ្នកបង្កើតហ៊ីប៉ូតែកហើយ វានឹងច្រលំជាមួយនឹងទ្រព្យសម្បត្តិផ្សេងទៀតរបស់អ្នកបង្កើតហ៊ីប៉ូតែក ពោលគឺវាមិនអាចបែងចែកដាច់ពីទ្រព្យសម្បត្តិរបស់អ្នកបង្កើតហ៊ីប៉ូតែកបាន ដូច្នេះក្រមរដ្ឋប្បវេណីបានកម្រិតនូវការអនុវត្តសិទ្ធិពីសំណាក់ម្ចាស់បំណុលហ៊ីប៉ូតែក។

សរុបជារួមមក ម្ចាស់បំណុលហ៊ីប៉ូតែកអាចធ្វើឧបាទេសកម្មលើប្រាក់ ឬវត្ថុដទៃទៀត ដែលកើតចេញពីការលក់ ឬការខូតខាត ការបាត់បង់នូវអចលនវត្ថុហ៊ីប៉ូតែកបាន នៅមុនពេលដែលប្រាក់ ឬវត្ថុនោះត្រូវបានបង់ ឬប្រគល់ឱ្យអ្នកបង្កើតហ៊ីប៉ូតែក។ ផ្ទុយមកវិញប្រសិនបើប្រាក់ ឬវត្ថុនោះបានប្រគល់ដល់អ្នកបង្កើតហ៊ីប៉ូតែកហើយ ម្ចាស់បំណុលហ៊ីប៉ូតែកនឹងបាត់បង់សិទ្ធិក្នុងការធ្វើឧបាទេសកម្ម។

### ២.២.១.៥.សិទ្ធិតាមទារសំណងរបស់អ្នកធានាដោយវត្ថុ

ផ្អែកតាមបញ្ញត្តិនៃមាត្រា៨៤៦នៃក្រមរដ្ឋប្បវេណី យើងឃើញថាតតិយជនអាចយកនូវអចលនវត្ថុរបស់ខ្លួនទៅដាក់ជាហ៊ីប៉ូតែកដើម្បីធានាបំណុលឱ្យកូនបំណុលបាន។ ដូច្នេះវាអាចកើតមានករណីថា ដល់កាលបរិច្ឆេទកំណត់សងបំណុល កូនបំណុលពុំមានលទ្ធភាពសងម្ចាស់បំណុលទេ ហើយម្ចាស់បំណុលបានអនុវត្តសិទ្ធិហ៊ីប៉ូតែក ដោយរឹបអូសអចលនវត្ថុនោះទៅលក់ដោយបង្ខំដើម្បីសងបំណុលខ្លួន។ ក៏មានករណីខ្លះទៀត អ្នក

[29] វាក្យខណ្ឌទី១ កថាខណ្ឌទី១ នៃមាត្រា៨៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[30] វាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រា៨៤៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ធានាដោយវត្ថុ ដើម្បីរក្សាអចលនវត្ថុរបស់ខ្លួនបញ្ចៀសពីការអនុវត្តដោយបង្ខំ ក៏បានសងបំណុលជំនួសឱ្យកូនបំណុល ដែលសកម្មភាពទាំងនេះសុទ្ធសឹងតែជាការណ៍មួយនាំឱ្យខូចប្រយោជន៍របស់អ្នកធានាដោយវត្ថុ។

ដូច្នេះដើម្បីជាភាពយុត្តិធម៌ចំពោះអ្នកធានាដោយវត្ថុ ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ ត្រង់មាត្រា៨៥០ បានផ្តល់សិទ្ធិដល់អ្នកធានាដោយវត្ថុអាចធ្វើការទាមទារនូវសំណងពីកូនបំណុលបាន ក្នុងករណីដែលខ្លួនបានចេញសងជំនួសកូនបំណុលទៅកាន់ម្ចាស់បំណុល ឬករណីដែលម្ចាស់បំណុលបានរឹបអូសនូវអចលនវត្ថុរបស់ខ្លួន ដោយសារតែកូនបំណុលអលទ្ធភាពសងបំណុល។

មាត្រានេះបានបញ្ញត្តិផងដែរថា ការទាមទារសំណងនេះត្រូវអនុវត្តតាមបញ្ញត្តិស្តីពីការធានា ដូច្នេះបញ្ញត្តិមាត្រា៩១១ និងបញ្ញត្តិបន្តបន្ទាប់ដែលទាក់ទង ត្រូវយកមកអនុវត្តចំពោះករណីនេះ។

**២.២.១.៦.ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា**

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានានេះ មានន័យថាជាទំហំដែលអាចទទួលការសងដោយមានអាទិភាព។ ផ្អែកតាមមាត្រា៨៥២ នៃក្រមរដ្ឋប្បវេណី ទំហំដែលអាចទទួលបានការសងដោយមានអាទិភាពត្រូវបានកម្រិតត្រឹមសិទ្ធិលើបំណុលចំពោះប្រាក់ដើម ព្រមទាំងការប្រាក់ និងប្រាក់សំណងការខូចខាតជាអាទិ៍ក្នុងរយៈពេល២ឆ្នាំចុងក្រោយតែប៉ុណ្ណោះ។ រីឯការប្រាក់ និងប្រាក់សំណងការខូចខាតជាអាទិ៍ដែលមានមុនរយៈពេល២ឆ្នាំចុងក្រោយនេះ ម្ចាស់បំណុលនៅតែមានសិទ្ធិទាមទារពីកូនបំណុលដដែល ប៉ុន្តែក្នុងនាមជាម្ចាស់បំណុលធម្មតា។

ឧទាហរណ៍ទី១ លោក **ក** មានដីមួយកន្លែងតម្លៃ៣.០០០ដុល្លារ។ លោក **ក** បានយកដីនេះទៅដាក់ហ៊ីប៉ូតែកឱ្យលោក **ខ** ដើម្បីធានាបំណុលតម្លៃ១.៥០០ដុល្លារ ដោយការប្រាក់ក្នុងមួយឆ្នាំ១០% បំណុលនេះត្រូវបានខ្ចីសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២១។ លោក **ក** ពុំដែលបានបង់ការប្រាក់ឱ្យ លោក **ខ** ឡើយ។ ដូច្នេះប្រសិនបើកាលបរិច្ឆេទកំណត់សងមកដល់ ហើយលោក **ក** គ្មានលទ្ធភាពសង នោះលោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកមានសិទ្ធិទទួលការសងជាអាទិភាពនូវប្រាក់ដើមចំនួន១.៥០០ដុល្លារ ព្រមទាំងការប្រាក់សម្រាប់រយៈពេល២ឆ្នាំចុងក្រោយ ពោលគឺពីឆ្នាំ២០១៩ ដល់ ២០២១ ដែលមានតម្លៃស្មើនឹង ១.៥០០ × ១០% × ២ ឆ្នាំ = ៣០០ដុល្លារ។ ដូច្នេះលោក **ខ** មានសិទ្ធិទទួលបានការសងជាអាទិភាពនូវទឹកប្រាក់សរុបចំនួន ១.៨០០ដុល្លារ។ រីឯការប្រាក់រយៈពេល ៣ឆ្នាំទៀត គឺពីឆ្នាំ២០១៦ ដល់ ២០១៩ ដែលមានតម្លៃ៤៥០ដុល្លារ លោក **ខ** នៅតែអាចទាមទារពីលោក **ក** បានដដែល តែក្នុងនាមជាម្ចាស់បំណុលធម្មតា ពុំអាចទាមទារក្នុងនាមជាម្ចាស់បំណុលហ៊ីប៉ូតែកបានឡើយ។

បានជាច្បាប់ចែងយ៉ាងដូច្នេះ ព្រោះយើងដឹងហើយថាអចលនវត្ថុមួយអាចបង្កើតហ៊ីប៉ូតែកបានជាច្រើន ដូច្នេះដើម្បីឱ្យម្ចាស់បំណុលលំដាប់ទាបជាងអាចដឹងថាតម្លៃនៃអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែកនោះនៅ

សល់ក្នុងទំហំប៉ុន្មាន ហើយថាតើម្ចាស់បំណុលគួរឱ្យខ្ចីប្រាក់ក្នុងទំហំប៉ុន្មាន ដែលអាចធានាការសងបាន ច្បាប់បានកម្រិតអំពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាឱ្យបានច្បាស់លាស់។ ប្រសិនបើគ្មានបញ្ញត្តិបែបនេះទេ វានឹងក្លាយជាហានិភ័យចំពោះម្ចាស់បំណុលលំដាប់ទាបជាង ដែលមិនអាចដឹងច្បាស់ពីទំហំជាក់លាក់នៃសិទ្ធិលើបំណុលដែលត្រូវបានធានាចំពោះម្ចាស់បំណុលមុន។

តាមរយៈឧទាហរណ៍ទី១ខាងលើ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាចំពោះម្ចាស់បំណុល **ខ** គឺ ១.៨០០ដុល្លារ។ ដូច្នេះម្ចាស់បំណុលក្រោយៗ បើចង់ឱ្យលោក **ក** ខ្ចីបំណុលដោយដាក់អចលនវត្ថុជាប្រាតិភោគ ម្ចាស់បំណុលនោះអាចដឹងថាអចលនវត្ថុនោះអាចធានាបំណុលបានត្រឹមតែ ១.២០០ដុល្លារទៀតប៉ុណ្ណោះ ដូច្នេះខ្លួនគួរឱ្យលោក **ក** ខ្ចីត្រឹមតែ១.២០០ដុល្លារប៉ុណ្ណោះ ឬអាចទាបជាង១.២០០ដុល្លារ ប្រសិនបើមានគិតការប្រាក់ផងនោះ។

**២.២.១.៧.លំដាប់នៃហ៊ីប៉ូតែក**

ចំណុចពិសេសបំផុតមួយក្នុងចំណោមចំណុចពិសេសជាច្រើនទៀតនៃហ៊ីប៉ូតែកគឺ អចលនវត្ថុមួយអាចត្រូវបានគេយកទៅបង្កើតហ៊ីប៉ូតែកច្រើនបាន ពោលគឺអាចនឹងមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើននាក់លើអចលនវត្ថុតែមួយ។ ដូច្នេះវានឹងមានបញ្ហាថានៅពេលដែលអចលនវត្ថុជាកម្មវត្ថុហ៊ីប៉ូតែកត្រូវបានលក់ដោយការអនុវត្តដោយបង្ខំ តើម្ចាស់បំណុលណាដែលអាចទទួលបានសំណងជាអាទិភាព?

ដើម្បីដោះស្រាយនូវបញ្ហានេះ ក្រមរដ្ឋប្បវេណីខ្មែរមាត្រា៨៥១ ចែងថា *ក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែកនៅលើអចលនវត្ថុតែមួយដើម្បីធានាសិទ្ធិលើបំណុលច្រើន លំដាប់នៃហ៊ីប៉ូតែកនោះត្រូវអនុលោមតាមពេលវេលាដែលបានចុះបញ្ជី។* បញ្ញត្តិនៃមាត្រានេះបានយកពេលវេលានៃការចុះបញ្ជីដែលជាលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកមកធ្វើជាមូលដ្ឋាននៃការកំណត់លំដាប់អាទិភាពនៃហ៊ីប៉ូតែក។ ឧបមាថាលោក **ក** មានដីមួយកន្លែង ហើយគាត់បានយកដីនោះដាក់ហ៊ីប៉ូតែកដើម្បីធានាបំណុល លោក **ខ** តម្លៃ២.០០០ដុល្លារ ដោយបានចុះបញ្ជីត្រឹមត្រូវ។ បន្ទាប់មកទៀត លោក **ក** បានយកដីដដែលនោះដាក់ហ៊ីប៉ូតែកធានាបំណុលលោក **គ** តម្លៃ២.០០០ដុល្លារ ដោយហ៊ីប៉ូតែកបានចុះបញ្ជីត្រឹមត្រូវ។ រំលងមួយរយៈមក លោក **ក** ក៏ខ្ចីប្រាក់ពីលោក **ឃ** ទៀតចំនួន១.៥០០ដុល្លារ ដោយបានយកដីដដែលនោះដាក់ហ៊ីប៉ូតែក និងបានចុះបញ្ជីត្រឹមត្រូវ។ ក្នុងករណីដូចនេះ ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា៨៥១នៃក្រមរដ្ឋប្បវេណី លោក **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី១ លោក **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី២ រីឯ លោក **ឃ** វិញគឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី៣។ នៅពេលដែលអនុវត្តហ៊ីប៉ូតែក លុយដែលបានមកពីការលក់ដោយបង្ខំគឺត្រូវចែកជូនលោក **ខ** សិន បន្ទាប់មកទើប **គ** និង **ឃ** តាមក្រោយ។

លើសពីនេះទៀត ក៏មានចម្ងល់ផងដែរថា តើមានតែម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទីមួយទេឬដែលអាចដាក់ពាក្យសុំអនុវត្តសិទ្ធិហ៊ីប៉ូតែកមុនគេបាន? ឬក៏ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងក៏អាចដាក់ពាក្យសុំអនុវត្តសិទ្ធិហ៊ីប៉ូតែកមុនម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់លើខ្លួនបានដែរ?

ចម្លើយទៅនឹងសំណួរនេះគឺមានចែងក្នុងច្បាប់នីតិវិធីពោលគឺក្រមនីតិវិធីរដ្ឋប្បវេណី ដោយបានចែងថា *សិទ្ធិប្រាតិភោគប្រត្យក្សលើអចលនវត្ថុ សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ និងសិទ្ធិជួលអចលនវត្ថុ ដែលអាចតតាំងនឹងសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបន្តអត្ថិភាពក្រោយការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគ។ ក្រៅពីនេះ សិទ្ធិលើអចលនវត្ថុត្រូវរលត់ដោយការលក់។* [31] ផ្អែកតាមបញ្ញត្តិនេះ ឃើញថាក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបានប្រកាន់យកគោលការណ៍ទទួលបន្ត តាមគោលការណ៍នេះ ក្នុងចំណោមបន្ទុកលើអចលនវត្ថុទាំងអស់ បន្ទុកដែលមិនអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបាន នឹងត្រូវរលត់ក្រោយការលក់ដោយបង្ខំនៃអចលនវត្ថុនោះ រីឯសិទ្ធិផ្សេងទៀតដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្ត នឹងត្រូវបន្តអត្ថិភាព ហើយអ្នកទិញនឹងធ្វើលទ្ធកម្មនូវអចលនវត្ថុនោះដោយភ្ជាប់នឹងបន្ទុកនោះ។[32]

ដូច្នេះម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទាបជាងក៏អាចចាប់ផ្តើមអនុវត្តសិទ្ធិហ៊ីប៉ូតែកមុនម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ខ្ពស់បានដែរ។ ហើយបើម្ចាស់បំណុលហ៊ីប៉ូតែកណាមួយអនុវត្តសិទ្ធិហ៊ីប៉ូតែក នោះហ៊ីប៉ូតែកដែលមានលំដាប់ទាបជាងនឹងត្រូវរលត់ដោយស្វ័យប្រវត្តិ ហើយត្រូវចូលមកចែកចំណែកជាមួយគេដែរ ចំណែកឯហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងហ៊ីប៉ូតែកដែលធ្វើការអនុវត្តនោះនៅបន្តមានអត្ថិភាពដដែលក្រោយការអនុវត្ត ហើយអ្នកទិញដែលធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រូវធ្វើលទ្ធកម្មដោយភ្ជាប់នូវបន្ទុកហ៊ីប៉ូតែកពោលគឺម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ខ្ពស់ជាងនោះ អាចអនុវត្តសិទ្ធិប្រាតិភោគប្រត្យក្សរបស់ខ្លួនបានដដែលលើអចលនវត្ថុនោះ។ ឧទាហរណ៍ងាយយល់ថា មានម្ចាស់បំណុលហ៊ីប៉ូតែកបីនាក់ គឺលំដាប់១ លំដាប់២ និងលំដាប់៣ ករណីនេះចង់ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់២ ឬ ៣ដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែកមុនម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់១ក៏បានដែរ។ ឧបមាថាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់២អនុវត្តសិទ្ធិមុន ដូច្នេះហ៊ីប៉ូតែកលំដាប់ទី៣នឹងត្រូវរលត់ដោយស្វ័យប្រវត្តិ ហើយចូលមកចែកចំណែកជាមួយលំដាប់២ ប៉ុន្តែចំពោះហ៊ីប៉ូតែកលំដាប់១វិញគឺមិនរលត់ទេ អ្នកទិញត្រូវធ្វើលទ្ធកម្មលើអចលនវត្ថុហ៊ីប៉ូតែកដោយភ្ជាប់នូវបន្ទុកហ៊ីប៉ូតែកលំដាប់១នោះ។

---

[31] កថាខណ្ឌទី១ និង២ នៃមាត្រា៥១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[32] សេចក្តីកំណត់មាត្រា៥១០, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

**២.២.១.៨.ហ៊ីប៉ូតែករួម**

ហ៊ីប៉ូតែករួម គឺជាហ៊ីប៉ូតែកដែលបង្កើតឡើងលើអចលនវត្ថុច្រើន ដើម្បីធានាសិទ្ធិលើបំណុលតែមួយ។[33] ក្នុងករណីហ៊ីប៉ូតែករួមនេះ កាលបើកូនបំណុលពុំមានលទ្ធភាពសងបំណុលទេ ម្ចាស់បំណុលមានជម្រើសពីរក្នុងការអនុវត្ត ជម្រើសទី១គឺអនុវត្តដោយបង្ខំលើអចលនវត្ថុទាំងអស់ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែករួម ក្នុងករណីនេះបន្ទុកនៃសិទ្ធិលើបំណុលត្រូវចែកទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗនោះ។ [34] រីឯជម្រើសទី២វិញ គឺម្ចាស់បំណុលហ៊ីប៉ូតែករួម អាចអនុវត្តដោយបង្ខំលើអចលនវត្ថុតែមួយប៉ុណ្ណោះ ក្នុងចំណោមអចលនវត្ថុទាំងអស់ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែករួម ក្នុងករណីនេះម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់បន្ទាប់ អាចអនុវត្តហ៊ីប៉ូតែករបស់ម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់នៅខាងលើដោយឧបាទេសកម្មបាន រហូតដល់ចំនួនទឹកប្រាក់ដែលម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ខ្ពស់ជាងនោះ ត្រូវទទួលការសងចំពោះអចលនវត្ថុផ្សេងទៀត។ [35]

ឧទាហរណ៍ថា លោក **ក** មានសិទ្ធិហ៊ីប៉ូតែកចំពោះលោក **ខ** ចំនួន៦០០ដុល្លារ ដោយហ៊ីប៉ូតែកត្រូវបានបង្កើតលើអចលនវត្ថុចំនួន៣ គឺដីទីមួយ(១)មានតម្លៃ៦០០ដុល្លារ ដីទីពីរ(២)មានតម្លៃ៤០០ដុល្លារ និងដីទីបី(៣)មានតម្លៃ២០០ដុល្លារ។ លើសពីនេះទៀត លោក **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទីពីរលើដីទីមួយ(១) សិទ្ធិលើបំណុលតម្លៃ៣០០ដុល្លារ។ ដូច្នេះក្នុងករណីដែលដល់ពេលកំណត់សងហើយ តែលោក **ខ** គ្មានលទ្ធភាពសង តើលោក **ក** មានជម្រើសយ៉ាងដូចម្ដេចខ្លះក្នុងការអនុវត្តសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន? ហើយជម្រើសនីមួយៗត្រូវបែងចែកចំណែកយ៉ាងដូចម្ដេចខ្លះ?

ដោយលោក **ក** គឺជាម្ចាស់បំណុលនៃហ៊ីប៉ូតែករួម ដូច្នេះផ្អែកតាមមាត្រា៨៥៧ នៃក្រមរដ្ឋប្បវេណី លោក **ក** មានជម្រើសពីរក្នុងការអនុវត្តហ៊ីប៉ូតែក។ ជម្រើសទី១ គឺ លោក **ក** អនុវត្តលើអចលនវត្ថុទាំងបីនោះព្រមគ្នា ក្នុងករណីនេះលុយសរុបដែលបានមកពីការលក់អចលនវត្ថុទាំងបីគឺ១.២០០ដុល្លារ ដោយត្រូវចែកចំណែកទៅតាមសមាមាត្រនៃតម្លៃអចលនវត្ថុនីមួយៗ។ តាមបញ្ញត្តិនេះលោក **ក** ត្រូវទទួលបានប្រាក់ចំនួន៣០០ដុល្លារ ពីដីទីមួយ(១) ២០០ដុល្លារ ពីដីទីពីរ(២) និង១០០ដុល្លារ ពីដីទីបី(៣)។ ចំពោះលោក **គ** ដែលមានសិទ្ធិហ៊ីប៉ូតែកលំដាប់ទីពីរលើដីទីមួយ(១) សិទ្ធិហ៊ីប៉ូតែកនេះត្រូវរលត់ដែរ ព្រោះដូចដែលបានបកស្រាយពីចំណុចមុន ការអនុវត្តនៃសិទ្ធិហ៊ីប៉ូតែកលំដាប់ខ្ពស់ជាងនឹងធ្វើឱ្យហ៊ីប៉ូតែកលំដាប់ទាបជាងរលត់ដោយស្វ័យប្រវត្តិ។ ហើយលោក **គ** មានសិទ្ធិទទួលប្រាក់ចំនួន៣០០ដុល្លារ ដែលសល់ពីការកាត់ប្រាក់ចំនួន៣០០ដុល្លារ សងទៅលោក **ក** ។

---

[33] សេចក្ដីកំណត់មាត្រា៨៥៧, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៤: គន្លឹទី៦, ឆ្នាំ២០១០

[34] កថាខណ្ឌទី១ នៃមាត្រា៨៥៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[35] កថាខណ្ឌទី២ នៃមាត្រា៨៥៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ក្រៅពីជម្រើសនេះ លោក **ក** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែករួមក៏អាចអនុវត្តទៅលើតែអចលនវត្ថុណាមួយ ក្នុងចំណោមអចលនវត្ថុទាំងបីក៏បាន ឧបមាថា លោក **ក** សម្រេចចិត្តអនុវត្តដោយបង្ខំលើដីទីមួយ(១)តែមួយគត់ ដូច្នេះលោក **ក** អាចទទួលបានប្រាក់ទាំងអស់ពីការលក់ដោយបង្ខំនូវដីទីមួយ(១) ពោលគឺទទួលបាន ៦០០ដុល្លារ ល្មមគ្រប់នឹងសិទ្ធិលើបំណុលរបស់គាត់តែម្តង។ ចំណែកឯលោក **ខ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទីពីរលើដីទីមួយ(១) តាមគោលការណ៍ទូទៅ គឺគាត់មិនអាចទទួលបានការសងជាអាទិភាពទៀតទេ ព្រោះលុយទាំងអស់ដែលបានមកពីការលក់ត្រូវផ្តល់ឱ្យលោក **ក** អស់ហើយ ប៉ុន្តែមិនដូច្នេះទេ លោក **ខ** ត្រូវបានសង្គ្រោះដោយវាក្យខណ្ឌទី២ កថាខណ្ឌទី២ នៃមាត្រា៨៥៧ លោក **ខ** អាចធ្វើឧបាទេសកម្មនូវសិទ្ធិលើបំណុលរបស់លោក **ក** ចំពោះអចលនវត្ថុដទៃទៀតបាន (ដីទីពីរ និងដីទីបី) ពោលគឺលោក **ខ** អាចទទួលបានប្រាក់ចំនួន២០០ដុល្លារ ពីដីទីពីរ(២) និង ១០០ដុល្លារ ពីដីទីបី(៣) សរុបទៅគឺ ៣០០ដុល្លារដដែល។

ផ្អែកតាមឧទាហរណ៍នេះ យើងអាចទាញសេចក្តីសន្និដ្ឋានថា បញ្ញត្តិនេះត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិម្ចាស់បំណុលហ៊ីប៉ូតែកដែលមានលំដាប់ទាបជាង ក្នុងករណីហ៊ីប៉ូតែករួម ដោយធ្វើយ៉ាងណាបញ្ចៀសនូវភាពអយុត្តិធម៌ មិនឱ្យម្ចាស់បំណុលលំដាប់ខ្ពស់ប្រព្រឹត្តតាមទំនើងចិត្ត ធ្វើឱ្យខូចប្រយោជន៍ម្ចាស់បំណុលលំដាប់ទាប។ ដូច្នេះយើងឃើញថាទោះបីជាម្ចាស់បំណុលលំដាប់ខ្ពស់បានជ្រើសរើសវិធីណាក៏ដោយ ក៏មិនធ្វើឱ្យខូចប្រយោជន៍ម្ចាស់បំណុលលំដាប់ទាបឡើយ។

### ២.២.១.៩.ការចាត់ចែងហ៊ីប៉ូតែក

#### ក.ហ៊ីប៉ូតែកបន្ត

ម្ចាស់បំណុលហ៊ីប៉ូតែកអាចយកសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនទៅដាក់ជាប្រាតិភោគសម្រាប់ធានាបំណុលខ្លួនឯង ឬតតិយជនបាន ការណ៍នេះហៅថាហ៊ីប៉ូតែកបន្ត។

ប្រសិនបើសិទ្ធិលើបំណុលដែលធានាដោយហ៊ីប៉ូតែកដើម និងសិទ្ធិលើបំណុលដែលធានាដោយហ៊ីប៉ូតែកបន្តដល់ពេលកំណត់សងព្រមគ្នា នោះនៅពេលអនុវត្តហ៊ីប៉ូតែកដើម គេត្រូវចែកចំណែកនូវប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកបន្តជាមុនសិន ក្នុងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកដើម បើនៅសល់ប្រាក់ពីការចែកចំណែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកបន្ត ទើបចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកដើម។ ប៉ុន្តែក្នុងករណីដែលសិទ្ធិលើបំណុលដែលធានាដោយហ៊ីប៉ូតែកដើមដល់ពេលកំណត់សង ហើយសិទ្ធិលើបំណុលដែលធានាដោយហ៊ីប៉ូតែកបន្តមិនទាន់ដល់ពេលកំណត់សងទេ ម្ចាស់បំណុលហ៊ីប៉ូតែកបន្ត មានសិទ្ធិត្រឹមទាមទារឱ្យតម្កល់ចំនួនទឹកប្រាក់ដែលខ្លួនអាចទទួលការសងប៉ុណ្ណោះ។[36]

[36] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី មាត្រា៨៥៩ នៃក្រមរដ្ឋប្បវេណី និងមាត្រា៨៥៩

ឧទាហរណ៍ថា លោក **ក** គឺជាម្ចាស់បំណុលហ៊ីប៉ូតែករបស់លោក **ខ** ចំនួន២.០០០ដុល្លារ ដោយមានដី (L) ជាប្រាតិភោគ។ បន្ទាប់មកដោយសារតែត្រូវការលុយបង្វិលអាជីវកម្ម លោក **ក** បានយកសិទ្ធិហ៊ីប៉ូតែករបស់ខ្លួននោះដាក់ហ៊ីប៉ូតែកបន្តឱ្យលោក **គ** ដើម្បីធានាបំណុលចំនួន១.៥០០ដុល្លារ។ ឧបមាថា ទាំងសិទ្ធិលើបំណុលរបស់លោក **ក** និងសិទ្ធិលើបំណុលរបស់លោក **គ** បានដល់ពេលកំណត់ត្រូវសងដូចគ្នា ដូច្នេះប្រាក់ចំនួន ១.៥០០ដុល្លារដែលបានមកពីការលក់ដោយបង្ខំនូវដី(L) ត្រូវចែកទៅឱ្យលោក **គ** ដែលជាម្ចាស់បំណុលហ៊ីប៉ូតែកបន្ត រីឯប្រាក់សល់ចំនួន៥០០ដុល្លារត្រូវចែកទៅឱ្យលោក **ក**។ ប៉ុន្តែបើសិនជាសិទ្ធិលើបំណុលរបស់លោក **ក** បានដល់ពេលកំណត់សង ប៉ុន្តែសិទ្ធិលើបំណុលរបស់ **គ** ពុំទាន់ដល់ពេលកំណត់សងទេ នៅពេលអនុវត្តហ៊ីប៉ូតែក លោក **គ** គ្រាន់តែមានសិទ្ធិទាមទារឱ្យតម្កល់ប្រាក់ចំនួន១.៥០០ដុល្លារប៉ុណ្ណោះ ហើយប្រាក់ចំនួន៥០០ដុល្លារទៀតអាចសងទៅលោក **ក** បាន។

ការចាត់ចែងបន្តនេះនឹងមានអានុភាពទៅបាន លុះត្រាតែបានធ្វើឡើងដោយលិខិតយថាភូត និងបានចុះបញ្ជីបន្ថែមអំពីហ៊ីប៉ូតែកនោះ យើងអាចនិយាយបានថានេះជាលក្ខខណ្ឌសុពលភាពនៃហ៊ីប៉ូតែកបន្ត។[37]

រីឯលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកបន្តវិញ គឺតម្រូវឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ធ្វើការជូនដំណឹងអំពីហ៊ីប៉ូតែកបន្តទៅកាន់កូនបំណុលដែលមានកាតព្វកិច្ចចម្បង ឬទទួលការយល់ព្រមពីកូនបំណុលនោះ ដើម្បីឱ្យការចាត់ចែងហ៊ីប៉ូតែកបង្កើតអានុភាពចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក និងប្រតិសិទ្ធិរបស់ជនទាំងនោះបាន។ បញ្ញត្តិនេះចែងឡើងគឺដើម្បីការពារដល់កូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានាជាអាទិ៍ ដើម្បីឱ្យពួកគេដឹងអំពីការចាត់ចែងហ៊ីប៉ូតែក និងដឹងថាតើនរណាគឺជាម្ចាស់បំណុលហ៊ីប៉ូតែកពិតប្រាកដ។ [38] ក្នុងករណីដែលកូនបំណុលដែលមានកាតព្វកិច្ចចម្បងបានទទួលដំណឹង ឬបានយល់ព្រមចំពោះការចាត់ចែងហ៊ីប៉ូតែកហើយនោះ ប្រសិនបើកូនបំណុលនោះធ្វើការសងនូវសិទ្ធិលើបំណុលទៅកាន់ម្ចាស់បំណុលហ៊ីប៉ូតែក ដោយគ្មានការយល់ព្រមពីម្ចាស់បំណុលហ៊ីប៉ូតែកបន្តទេ កូនបំណុលដែលមានកាតព្វកិច្ចចម្បង ពុំអាចអះអាងអំពីការសងនោះចំពោះម្ចាស់បំណុលហ៊ីប៉ូតែកបន្តបានឡើយ ឬអាចនិយាយម្យ៉ាងទៀតថា ម្ចាស់បំណុលហ៊ីប៉ូតែកបន្តនៅតែអាចទាមទារឱ្យកូនបំណុលដែលមានកាតព្វកិច្ចចម្បងធ្វើការសងបានដដែល។[39]

[37]កថាខណ្ឌទី១ មាត្រា៨៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[38] កថាខណ្ឌទី២ មាត្រា៨៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[39] កថាខណ្ឌទី៣ មាត្រា៨៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**ខ.អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក**

ម្ចាស់បំណុលហ៊ីប៉ូតែកអាចធ្វើអនុប្បទាន ឬធ្វើការបោះបង់នូវហ៊ីប៉ូតែករបស់ខ្លួនសម្រាប់ប្រយោជន៍ដល់ម្ចាស់បំណុលផ្សេងទៀត ដែលមានកូនបំណុលដូចគ្នាបាន។

កាលណាម្ចាស់បំណុលហ៊ីប៉ូតែកបានធ្វើអនុប្បទាននូវហ៊ីប៉ូតែកនោះទៅឱ្យម្ចាស់បំណុលផ្សេងទៀត ម្ចាស់បំណុលហ៊ីប៉ូតែក (អនុប្បទាយី) នឹងក្លាយជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ចំណែកឯម្ចាស់បំណុលដែលទទួលបានអនុប្បទានហ៊ីប៉ូតែក (អនុប្បទានិក) នឹងក្លាយជាម្ចាស់បំណុលហ៊ីប៉ូតែក។ ពោលគឺរវាងភាគីនៃអនុប្បទានហ៊ីប៉ូតែក សិទ្ធិលើបំណុលរបស់អនុប្បទានិក មានអាទិភាពជាងសិទ្ធិលើបំណុលរបស់អនុប្បទាយី។[40]

ម្ចាស់បំណុលដែលបានបោះបង់ហ៊ីប៉ូតែកមិនអាចអះអាងហ៊ីប៉ូតែករបស់ខ្លួន ចំពោះម្ចាស់បំណុលដែលទទួលបានផលប្រយោជន៍ពីការបោះបង់ហ៊ីប៉ូតែកបានឡើយ។[41] មានន័យថា រវាងគូភាគីនៃការបោះបង់ហ៊ីប៉ូតែក ភាគីទាំងសងខាងមិនអាចអះអាងពីសិទ្ធិទៅវិញទៅមកបានឡើយ។ ហើយការចែកចំណែករវាងម្ចាស់បំណុលដែលជាភាគីនៃការបោះបង់ហ៊ីប៉ូតែកគឺត្រូវចែកតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ។

មួយវិញទៀត ទាំងការធ្វើអនុប្បទានហ៊ីប៉ូតែក និងការបោះបង់ហ៊ីប៉ូតែក គឺមានអានុភាពចំពោះតែភាគីពាក់ព័ន្ធនឹងទំនាក់ទំនងនៃការធ្វើអនុប្បទាន និងការបោះបង់ហ៊ីប៉ូតែកតែប៉ុណ្ណោះ ហើយគ្មានអនុភាពចំពោះម្ចាស់បំណុលផ្សេងទៀតនោះទេ។

*ដើម្បីស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅលើចំណុចនេះ យើងខ្ញុំសូមធ្វើការឧទាហរណ៍មួយដូចខាងក្រោម៖*

**ក** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី១លើដី(L) នូវទឹកប្រាក់ចំនួន២.០០០ដុល្លារ។ រីឯ **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី២លើដី(L) នូវទឹកប្រាក់ចំនួន៣.០០០ដុល្លារ។ ចំណែកឯ **គ** គឺជាម្ចាស់បំណុលលើសិទ្ធិលើបំណុលចំនួន២.០០០ដុល្លារ ដោយគ្មានហ៊ីប៉ូតែកទេ។ **ឃ** គឺជាកូនបំណុល និងជាម្ចាស់កម្មសិទ្ធិករនៃដី(L)។ សន្មតថា ដី(L) មានតម្លៃ៥.០០០ដុល្លារ តាមតម្លៃទីផ្សារ។

ក្នុងករណីនៃការចែកចំណែកធម្មតាដែលបានមកពីការលក់ដោយបង្ខំនូវដី(L) គឺ **ក** ត្រូវទទួលបានចំណែក ២.០០០ដុល្លារ **ខ** ត្រូវទទួលបានចំណែក ៣.០០០ដុល្លារ រីឯ **គ** គឺទទួលបានចំណែក ០ដុល្លារ (ព្រោះដីL លក់បានតែ៥.០០០ដុល្លារ ហើយចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក **ក** និង **ខ** អស់ហើយ)។

[40] កថាខណ្ឌទី២ មាត្រា៨៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[41] កថាខណ្ឌទី៣ មាត្រា៨៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ឧបមាថា **ក** (ម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់១) បានធ្វើអនុប្បទានហ៊ីប៉ូតែករបស់ខ្លួនជាប្រយោជន៍សម្រាប់ **គ** (ម្ចាស់បំណុលធម្មតា)។ ដូច្នេះតាមបញ្ញត្តិខាងលើ យើងឃើញថា **ក** នឹងក្លាយទៅជាម្ចាស់បំណុលដែលគ្មានហ៊ីប៉ូតែក ហើយ **គ** នឹងក្លាយជាម្ចាស់បំណុលហ៊ីប៉ូតែកវិញ។ ដែលធ្វើឱ្យការចែកចំណែកមានការផ្លាស់ប្តូរគឺ **ក** ត្រូវទទួលបានប្រាក់ ០ដុល្លារ, **ខ** ត្រូវទទួលបានប្រាក់ ៣.០០០ដុល្លារ, រីឯ **គ** គឺត្រូវទទួលបាន ២.០០០ដុល្លារ។

ឧបមាមួយទៀតថា **ក** បានបោះបង់ហ៊ីប៉ូតែកទៅឱ្យ **គ**។ ក្នុងករណីនេះ **ក** និង **គ** គឺមិនអាចអះអាងពីសិទ្ធិអាទិភាពចំពោះគ្នាទៅវិញទៅមកបាននោះទេ។ ដូច្នេះការចែកចំណែក ២.០០០ដុល្លារ ដែលត្រូវចែកទៅឱ្យ **ក** ត្រូវចែកតាមសមាមាត្រនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ **ក** និង **គ** ដោយចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ **ក** និង **គ** គឺស្មើគ្នា (២.០០០ដុល្លារដូចគ្នា) ដូច្នេះប្រាក់នេះត្រូវបានទៅ **ក** ១.០០០ដុល្លារ និង **គ** ១.០០០ ដុល្លារ។ បន្ទាប់មកទៀត ទឹកប្រាក់ដែលនៅសល់ចំនួន៣.០០០ដុល្លារ ត្រូវបានចែកទៅឱ្យ **ខ** ដដែល។

ដូច្នេះតាមរយៈឧទាហរណ៍ខាងលើ គឺមិនមានការប៉ះពាល់ផលប្រយោជន៍របស់ **ខ** ទេ ទោះជាករណីនៃអនុប្បទាន ឬ ករណីនៃការបោះបង់ហ៊ីប៉ូតែកក៏ដោយ ព្រោះ **ខ** គឺជាតតិយជននៃទំនាក់ទំនងអនុប្បទាន និងការបោះបង់ហ៊ីប៉ូតែកនោះ។

**គ.អនុប្បទាន ឬការបោះបង់នូវលំដាប់នៃហ៊ីប៉ូតែក**

ក្នុងករណីដែលមានម្ចាស់បំណុលហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយ នោះម្ចាស់បំណុលហ៊ីប៉ូតែកទាំងនោះអាចធ្វើអនុប្បទាន បោះបង់ និងផ្លាស់ប្តូរនូវលំដាប់នៃហ៊ីប៉ូតែកបាន តាមការព្រមព្រៀងរវាងម្ចាស់បំណុលហ៊ីប៉ូតែកទាំងឡាយ។

ក្នុងករណីអនុប្បទានលំដាប់នៃហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលបានអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែក អាចទទួលបានការសងដោយមានអាទិភាពជាងម្ចាស់បំណុលហ៊ីប៉ូតែកដែលបានធ្វើអនុប្បទាននូវលំដាប់នោះ នូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុហ៊ីប៉ូតែកនោះ ត្រឹមកម្រិតនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកឱ្យទៅម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនោះ។[42]

ក្នុងករណីបោះបង់លំដាប់នៃហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកដែលទទួលបាននូវការបោះបង់លំដាប់នៃហ៊ីប៉ូតែក អាចទទួលការសងដោយមានសមភាពជាមួយម្ចាស់បំណុលដែលបានលះបង់លំដាប់ហ៊ីប៉ូតែកនោះ

[42] កថាខណ្ឌទី២ មាត្រា៨៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

តាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល នៅក្នុងទំហំនៃចំនួនទឹកប្រាក់សរុបនៃចំណែកដែលត្រូវចែកទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកទាំងពីរនាក់នោះ។[43]

ម្ចាស់បំណុលហ៊ីប៉ូតែកដែលបានព្រមព្រៀងគ្នាក្នុងការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែកអាចអនុវត្តហ៊ីប៉ូតែកបានតាមការព្រមព្រៀងនោះ។[44]

ការមើលតែទៅលើបញ្ញត្តិច្បាប់ដូចដែលបានលើកឡើងខាងលើ ហាក់មានការលំបាកយល់ខ្លាំង ដូច្នេះយើងខ្ញុំសូមលើកជាឧទាហរណ៍មកបង្ហាញដើម្បីឱ្យការសិក្សាកាន់តែមានលក្ខណៈស៊ីជម្រៅ។

ឧទាហរណ៍ថា **ក** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់ទី១ លើដី(L)នូវទឹកប្រាក់ចំនួន១.៥០០ដុល្លារ។ **ខ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់២ លើដី(L)នូវទឹកប្រាក់ចំនួន១.០០០ដុល្លារ។ **គ** គឺជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់៣លើដី(L) នូវទឹកប្រាក់ចំនួន១.០០០ដុល្លារ។ **ឃ** គឺជាកូនបំណុល ហើយក៏ជាម្ចាស់កម្មសិទ្ធិករនៃដី(L)ផងដែរ។ សន្មតថាដី(L)មានតម្លៃ ២.៨០០ដុល្លារ តាមតម្លៃទីផ្សារ។

ប្រសិនបើហ៊ីប៉ូតែកត្រូវបានអនុវត្ត ហើយអចលនវត្ថុត្រូវបានលក់ដោយបង្ខំក្នុងតម្លៃ២.៨០០ដុល្លារ នោះទឹកប្រាក់ដែលបានមកពីការលក់ដោយបង្ខំចំនួន១.៥០០ដុល្លារ ត្រូវចែកទៅឱ្យ **ក**, ប្រាក់ចំនួន១.០០០ដុល្លារទៀត ត្រូវចែកទៅឱ្យ **ខ**, រីឯ **គ** វិញគឺទទួលបាននូវទឹកប្រាក់ចំនួនតែ៣០០ដុល្លារតែប៉ុណ្ណោះ ហើយបំណុលចំនួន៧០០ដុល្លារទៀត **គ** អាចទារពី **ឃ** បានក្នុងឋានៈជាម្ចាស់បំណុលធម្មតាមានសិទ្ធិស្មើនឹងម្ចាស់បំណុលដទៃទៀតដែរ។

ឧបមាថា **ក** បានធ្វើអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែកឱ្យទៅ **គ** នោះ **គ** អាចទទួលបានការសងដោយមានអាទិភាពនូវសិទ្ធិលើបំណុលទាំងអស់ ក្នុងទំហំនៃទឹកប្រាក់ចំនួន១.៥០០ដុល្លារ ដែលត្រូវចែកទៅឱ្យ **ក** បូកនឹងទឹកប្រាក់ចំនួន៣០០ដុល្លារដែលត្រូវចែកទៅឱ្យ **គ**។ ដូច្នេះ **គ** ត្រូវទទួលបានប្រាក់ចំនួន១.០០០ដុល្លារ (ដែលជាសិទ្ធិលើបំណុលរបស់ខ្លួនទាំងមូល) ហើយទឹកប្រាក់ចំនួន៨០០ដុល្លារ ដែលនៅសល់ទើបត្រូវចែកទៅឱ្យ **ក**។ ចំណែកឯ **ខ** វិញ គឺនៅតែទទួលបានទឹកប្រាក់ចំនួន១.០០០ដុល្លារដដែល ព្រោះ **ខ** គឺជាតតិយជននៃការធ្វើអនុប្បទាននូវលំដាប់នៃហ៊ីប៉ូតែកនេះ។

ឧបមាទៀតថា **ក** បានបោះបង់នូវលំដាប់ហ៊ីប៉ូតែកទៅឱ្យ **គ**។ ដូច្នេះក្នុងករណីនេះ **ក** និង **គ** អាចទទួលបានការសងដោយមានអាទិភាពក្នុងលំដាប់ស្មើគ្នា ក្នុងទំហំនៃទឹកប្រាក់ចំនួន១.៨០០ដុល្លារបាន។ ចំណែកឯការចែកចំណែកនូវទឹកប្រាក់ទៅឱ្យ **ក** និង **គ** គឺត្រូវចែកទៅតាមសមាមាត្រនៃសិទ្ធិលើបំណុល

[43] កថាខណ្ឌទី៣ មាត្រា៨៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[44] កថាខណ្ឌទី៤ មាត្រា៨៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

របស់ម្ចាស់បំណុលនីមួយៗ។ ដោយ **ក** មានសមាមាត្រ ៦០% នៃសិទ្ធិលើបំណុលសរុប រីឯ **គ** វិញ គឺមានសមាមាត្រស្មើនឹង៤០% នៃសិទ្ធិលើបំណុលសរុប។ ហេតុនេះគេបាន **ក** ទទួលបានចំណែកនូវទឹកប្រាក់ចំនួន ១.០៨០ដុល្លារ និង **គ** ទទួលបានចំណែកនូវទឹកប្រាក់ចំនួន៧២០ដុល្លារ។ ហើយនិយាយពី **ខ** វិញ គឺនៅតែទទួលបាន ១.០០០ដុល្លារដដែល។

ឧទាហរណ៍មួយទៀតថា **ក ខ** និង **គ** បានព្រមព្រៀងគ្នាផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែក ដោយព្រមព្រៀងថា **ខ** ប្តូរទៅជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់១វិញ **គ** ប្តូរជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់២ និង **ក** ប្តូរទៅជាម្ចាស់បំណុលហ៊ីប៉ូតែកលំដាប់១។ ក្នុងករណីនេះ **ខ** ត្រូវទទួលបានចំណែកមុនគេនូវទឹកប្រាក់ចំនួន១.០០០ដុល្លារ បន្ទាប់មក **គ** ត្រូវទទួលបានចំណែកក្នុងលំដាប់ទី២ គឺទឹកប្រាក់ចំនួន១.០០០ដុល្លារ រីឯ **ក** វិញត្រូវទទួលបានចំណែកក្នុងលំដាប់ទី៣ នូវទឹកប្រាក់ដែលនៅសល់ចំនួន៨០០ដុល្លារ។

**ឃ.ភាពខុសគ្នានៃអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក និង អនុប្បទាន ឬការបោះបង់លំដាប់នៃហ៊ីប៉ូតែក**

ឆ្លងតាមរយៈការពិនិត្យដ៏លម្អិតលើបញ្ញត្តិមាត្រា៨៦០ និងមាត្រា៨៦១ នៃក្រមរដ្ឋប្បវេណី និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ព្រមទាំងស្នាដៃស្រាវជ្រាវដទៃទៀត យើងអាចធ្វើការសន្និដ្ឋានបានថា អនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ជាមួយនិងអនុប្បទាន ឬការបោះបង់លំដាប់នៃហ៊ីប៉ូតែកខុសគ្នាត្រង់ថា៖ អនុប្បទាន និងការបោះបង់ហ៊ីប៉ូតែក អនុប្បទាយី ឬអ្នកបោះបង់ហ៊ីប៉ូតែក គឺជាម្ចាស់បំណុលហ៊ីប៉ូតែក ហើយអ្នកដែលទទួលប្រយោជន៍ពីអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក គឺជាម្ចាស់បំណុលធម្មតាដែលគ្មានហ៊ីប៉ូតែកទេ។ ខុសស្រឡះពីនេះ ក្នុងករណីនៃអនុប្បទាន ឬការបោះបង់នូវលំដាប់នៃហ៊ីប៉ូតែក គឺទាំងអ្នកធ្វើអនុប្បទាន ឬបោះបង់នូវលំដាប់នៃហ៊ីប៉ូតែក និងអ្នកដែលទទួលប្រយោជន៍ពីការធ្វើអនុប្បទាន ឬការបោះបង់នូវលំដាប់នៃហ៊ីប៉ូតែកសុទ្ធសឹងតែជាម្ចាស់បំណុលហ៊ីប៉ូតែកដូចគ្នា។

អ្វីដែលគួរតែរំលឹកមួយទៀតផងដែរនោះ គឺដើម្បីឱ្យអនុប្បទាន ឬការបោះបង់ហ៊ីប៉ូតែក ក៏ដូចជាអនុប្បទានការបោះបង់ និងការព្រមព្រៀងផ្លាស់ប្តូរលំដាប់នៃហ៊ីប៉ូតែក មានអានុភាពទៅបាន គឺត្រូវធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូត និងត្រូវចុះបញ្ជីបន្ថែមនៅរដ្ឋបាលសុរិយោដីផងដែរ។ មួយវិញទៀត ដើម្បីឱ្យការចាត់ចែងដូចដែលបានរៀបរាប់ខាងលើនេះ អាចយកទៅតតាំងចំពោះកូនបំណុលដែលមានកាតព្វកិច្ចចម្បង អ្នកធានា អ្នកបង្កើតហ៊ីប៉ូតែក ឬប្រតិសិទ្ធិរបស់ជនទាំងនោះបាន គឺម្ចាស់បំណុលដែលបានធ្វើប្រតិបត្តិការចាត់ចែងនោះត្រូវជូនដំណឹងទៅកូនបំណុលចម្បង ឬទទួលការយល់ព្រមពីកូនបំណុលនោះ ចំពោះការចាត់ចែងនោះ។[45]

---

[45] កថាខណ្ឌទី១ និងទី២ នៃមាត្រា៨៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ២.២.២.អានុភាពនៃការបញ្ចាំអចលនវត្ថុ

#### ២.២.២.១.សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលលើអចលនវត្ថុនៃការបញ្ចាំ

ជាគោលការណ៍ទូទៅ ម្ចាស់បំណុលពុំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីវត្ថុបញ្ចាំបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតពីកូនបំណុល ប៉ុន្តែចំពោះការបញ្ចាំអចលនវត្ថុវិញគឺមានលក្ខណៈពិសេស ពោលគឺម្ចាស់បំណុលអាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំបានដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ដោយមិនចាំបាច់មានការយល់ព្រមពីកូនបំណុលឡើយ។[46] ប៉ុន្តែក៏មានលក្ខខណ្ឌមួយផងដែរ គឺម្ចាស់បំណុលត្រូវប្រើប្រាស់អចលនវត្ថុនោះតាមវិធីប្រើប្រាស់ធម្មតា ពាក្យថា **តាមវិធីប្រើប្រាស់ធម្មតា** សំដៅលើការប្រើប្រាស់តាមលក្ខណៈដើមនៃវត្ថុ ឧទាហរណ៍ថាបើដីនោះគឺជាដីសម្រាប់ធ្វើកសិកម្ម ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រើប្រាស់ដីនោះសម្រាប់ធ្វើកសិកម្ម មិនអាចប្រើប្រាស់ដើម្បីសង់ផ្ទះជួលបានទេ។[47]

#### ២.២.២.២.បញ្ញត្តិពិសេសសម្រាប់ដីកសិកម្ម

បញ្ញត្តិពិសេសនេះយើងសូមធ្វើការបែងជាពីរករណីផ្សេងពីគ្នា គឺករណីដែលសិទ្ធិលើបំណុលដែលគ្មានកំណត់ពេល និងសិទ្ធិលើបំណុលដែលមានកំណត់ពេល។

ចំពោះករណីសិទ្ធិលើបំណុលដែលគ្មានកំណត់ពេល កូនបំណុលអាចធ្វើការរំលត់សិទ្ធិលើបំណុលដោយការសងនៅពេលណាក៏បានដែរ ដែលធ្វើឱ្យម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចត្រៀមខ្លួនទុកជាមុនក្នុងការប្រគល់ដីនោះទៅឱ្យកូនបំណុលវិញភ្លាមៗបានទេ ដូចជាករណីដែលម្ចាស់សិទ្ធិលើការបញ្ចាំទើបតែបានសាបគ្រាប់ពូជ ឬដាំដំណាំនៅលើដីនោះ ក្រោយមកបន្តិចកូនបំណុលក៏បានធ្វើការសងបំណុលទៅម្ចាស់សិទ្ធិ ធ្វើឱ្យបំណុលរលត់ ដូច្នេះការណ៍ដែលតម្រូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំប្រគល់ដីឱ្យវិញភ្លាមៗ ទាំងដែលមិនទាន់ប្រមូលផលផងគឺជារឿងមួយដែលមិនសមរម្យឡើយ។ ហេតុនេះហើយកថាខណ្ឌទី២នៃមាត្រា៨៣៤បានបញ្ញត្តិថា ក្នុងករណីនៃសិទ្ធិលើបំណុលដែលគ្មានកំណត់ពេលជាក់លាក់ ទោះបីជាសិទ្ធិលើបំណុលរលត់ដោយការសងក៏ដោយ បើរដូវប្រមូលផលដំណាំដែលម្ចាស់បំណុលបានសាប ឬដាំពីមុន នឹងដល់នៅក្នុងអំឡុងពេល១ឆ្នាំ ម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើដីនោះរហូតដល់ពេលប្រមូលផលនោះបាន។

ចំពោះករណីសិទ្ធិលើបំណុលដែលមានកំណត់ពេលច្បាស់លាស់វិញ ម្ចាស់សិទ្ធិលើការបញ្ចាំអាចដឹងយ៉ាងជាក់ច្បាស់អំពីកាលបរិច្ឆេទកំណត់នៃការសងបំណុល ដែលធ្វើឱ្យគាត់អាចត្រៀមខ្លួនទុកជាមុនបានក្នុងការប្រគល់ដីនោះឱ្យទៅកូនបំណុលវិញ ដូច្នេះបើកាលបរិច្ឆេទកំណត់សងមកដល់ ហើយកូនបំណុលបានសង

[46] កថាខណ្ឌទី១ មាត្រា៨៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[47] ទំព័រ១៥៣, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ២, រៀបរៀងដោយក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ការកែសម្រួលលើការបោះពុម្ពលើកទី១ ឆ្នាំ២០១៣

បំណុលគ្រប់ចំនួន ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់ដីនោះទៅឱ្យកូនបំណុលវិញភ្លាម។ ប៉ុន្តែប្រសិនបើកាលបរិច្ឆេទនៃការសងបំណុលមិនទាន់មកដល់ទេ ហើយកូនបំណុលបានរំលត់កាតព្វកិច្ចមុន នោះម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ដីនោះដើម្បីធ្វើកសិកម្មបានរហូតដល់រដូវប្រមូលផល ប្រសិនបើបានបំពេញលក្ខខណ្ឌពីរ៖ ទី១គឺរដូវប្រមូលនូវដំណាំដែលម្ចាស់សិទ្ធិលើការបញ្ចាំបានដាំ ឬសាបពីមុននោះនឹងមកដល់ក្នុងអំឡុងពេល១ឆ្នាំក្រោយពីការរំលត់សិទ្ធិលើបំណុល និងទី២គឺរដូវប្រមូលផលនោះត្រូវមកដល់មុនកាលបរិច្ឆេទនៃការសងសិទ្ធិលើបំណុល។[48] បើក្នុងចំណោមលក្ខខណ្ឌទាំងពីរនេះ មានលក្ខខណ្ឌណាមួយមិនត្រូវបានបំពេញទេ នោះម្ចាស់សិទ្ធិលើការបញ្ចាំត្រូវប្រគល់អចលនវត្ថុនោះវិញភ្លាមទៅឱ្យកូនបំណុល។

**២.២.២.៣.បន្ទុកសោហ៊ុយសម្រាប់ការគ្រប់គ្រងវត្ថុបញ្ចាំ**

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវចេញសោហ៊ុយគ្រប់គ្រង និងត្រូវទទួលបន្ទុកផ្សេងៗចំពោះអចលនវត្ថុនោះ។[49] ការតម្រូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុទទួលបន្ទុកទាំងនេះ វាគឺជាការសមហេតុផលមួយ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះ។ ប៉ុន្តែមិនមែនមានន័យថាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុទទួលបន្ទុកក្នុងការបង់ពន្ធនោះទេ ការបង់ពន្ធគឺជាកាតព្វកិច្ចរបស់កម្មសិទ្ធិករនៃអចលនវត្ថុ។[50]

**២.២.២.៤.ការប្រាក់នៃសិទ្ធិលើបំណុល**

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ មិនអាចទាមទារការប្រាក់នៃសិទ្ធិលើបំណុលរបស់ខ្លួនបានទេ។[51] វាក៏ជាប្រការមួយដ៏សមហេតុសមផលដែរ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំបាន ដែលនេះគឺជាថ្នូរទៅនឹងសិទ្ធិលើបំណុលហើយ។

**២.២.២.៥.ការសន្យាពិសេសក្នុងកិច្ចសន្យាបញ្ចាំ**

ដូចដែលបានរៀបរាប់ខាងលើ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងជាក់លាក់នូវសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំរបស់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ (ចំណុច ២.២.២.២) ក៏ដូចជាបញ្ញត្តិដែលតម្រូវឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុត្រូវទទួលខុសត្រូវចំពោះបន្ទុកសោហ៊ុយសម្រាប់ការគ្រប់គ្រងអចលនវត្ថុ (ចំណុច២.២.២.៣) និងបញ្ញត្តិដែលហាមឃាត់ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមិនឱ្យយកការប្រាក់នៃសិទ្ធិលើបំណុលពីកូនបំណុលឡើយ (ចំណុច២.២.២.៤)។ ទោះបីជាមានបញ្ញត្តិទាំង៣ខាងលើនេះក៏ដោយ ក៏ក្រមរដ្ឋប្បវេណីខ្មែរអនុញ្ញាតឱ្យគូភាគីនៃកិច្ចសន្យាបញ្ចាំអចលនវត្ថុ

[48] កថាខណ្ឌទី៣ មាត្រា៨៣៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[49] មាត្រា៨៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[50] សេចក្តីកំណត់មាត្រា៨៣៥, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៤៖ គន្ថីទី៦, ឆ្នាំ២០១០
[51] មាត្រា៨៣៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

អាចធ្វើការព្រមព្រៀងផ្សេងពីនេះបាន នេះគឺជាការទទួលស្គាល់នូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ប្រសិនបើគូភាគីនៃកិច្ចសន្យាមិនបានព្រមព្រៀងទេ ទើបបញ្ញត្តិច្បាប់ចូលមកអន្តរាគមន៍លើទំនាក់ទំនងនេះ។

ឧទាហរណ៍ថា កូនបំណុល និងម្ចាស់បំណុលបានព្រមព្រៀងនៅក្នុងកិច្ចសន្យាបញ្ចាំថា កូនបំណុលគឺជាអ្នកទទួលបន្ទុកចេញសោហ៊ុយក្នុងការគ្រប់គ្រងវត្ថុបញ្ចាំ និងបន្ទុកផ្សេងៗទៀតទាំងអស់។ ការព្រមព្រៀងនេះ ត្បិតមើលទៅហាក់មិនសូវមានសមភាពទេ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុជាកម្មវត្ថុនៃការបញ្ចាំ ហើយថែមទាំងរួចផុតពីបន្ទុកកាតព្វកិច្ចចេញសោហ៊ុយចំណាយគ្រប់គ្រងអចលនវត្ថុទៀត ប៉ុន្តែច្បាប់ទទួលស្គាល់អានុភាពនៃការព្រមព្រៀងបែបនេះ។ ឧទាហរណ៍មួយទៀតថា ភាគីនៃកិច្ចសន្យាបញ្ចាំបានព្រមព្រៀងគ្នាថា ម្ចាស់បំណុល(ម្ចាស់សិទ្ធិលើការបញ្ចាំ) អាចយកការប្រាក់នៃសិទ្ធិលើបំណុលបាន ការព្រមព្រៀងបែបនេះក៏ត្រូវបានទទួលស្គាល់នូវអានុភាពផងដែរ។

**២.២.២.៦.អំឡុងពេលនៃសិទ្ធិលើការបញ្ចាំមានអត្ថិភាព**

កិច្ចសន្យាបញ្ចាំអចលនវត្ថុមិនអាចធ្វើឡើងលើសពីចិរវេលា៥ឆ្នាំបានឡើយ ប្រសិនបើគូភាគីបានបង្កើតសិទ្ធិលើការបញ្ចាំវែងជាងចិរវេលា ៥ឆ្នាំ ចិរវេលានេះត្រូវបន្ថយមកត្រឹម ៥ឆ្នាំវិញ។ ប៉ុន្តែនៅពេលដែលផុតចិរវេលា ៥ឆ្នាំ កិច្ចសន្យាបញ្ចាំអចលនវត្ថុអាចធ្វើការបន្តបាន ប៉ុន្តែអំឡុងពេលនៃការបន្តនេះមិនអាចលើសពីចិរវេលា ៥ឆ្នាំទេ គិតចាប់ពីពេលបន្ត។[52]

**២.២.២.៧.ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីហ៊ីប៉ូតែក**

ក្រៅពីបញ្ញត្តិដូចដែលចែងនៅក្នុងផ្នែកស្តីពីការបញ្ចាំអចលនវត្ថុនេះ បញ្ញត្តិស្តីពីហ៊ីប៉ូតែកត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះសិទ្ធិលើការបញ្ចាំអចលនវត្ថុ។[53] ដូច្នេះមានន័យថា បញ្ញត្តិនៃហ៊ីប៉ូតែកក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរក្នុងករណីនៃការបញ្ចាំអចលនវត្ថុ លើកលែងតែបញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីបញ្ញត្តិនៃការបញ្ចាំអចលនវត្ថុ។

ដើម្បីឱ្យកាន់តែជាក់ច្បាស់ យើងខ្ញុំសូមបង្ហាញនូវបញ្ញត្តិខ្លះៗដែលអនុវត្តដូចគ្នារវាងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ។ ឧទាហរណ៍៖

មាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីស្តីពីលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែកគឺត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការបញ្ចាំអចលនវត្ថុ ដូច្នេះដើម្បីឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចតតាំងនូវសិទ្ធិលើការបញ្ចាំរបស់ខ្លួនចំពោះតតិយជនបាន សិទ្ធិលើការបញ្ចាំនោះត្រូវធ្វើឡើងក្នុងទម្រង់ជាលិខិតយថាភូត និងត្រូវយកទៅចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃរដ្ឋបាលសុរិយោដីរាជធានី-ខេត្ត។

[52] មាត្រា៨៣៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[53] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

មាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណីដែលចែងអំពីទំហំនៃអានុភាពហ៊ីប៉ូតែក ត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីការបញ្ចាំអចលនវត្ថុ ដូច្នេះប្រសិនបើដីមួយកន្លែងត្រូវបានដាក់ជាកម្មវត្ថុនៃការបញ្ចាំ នោះការបញ្ចាំនឹងមានអានុភាពចំពោះអាគារដែលសង់លើដីនោះផងដែរ ទោះបីជាអាគារនោះបានសាងសង់ឡើងមុនពេល ឬក្រោយពេលនៃការបង្កើតការបញ្ចាំក៏ដោយ។

មាត្រា ៨៥២ នៃក្រមរដ្ឋប្បវេណីស្តីពីទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ត្រូវយកមកអនុវត្តដូចគ្នាក្នុងករណីការបញ្ចាំអចលនវត្ថុ ពោលគឺប្រសិនបើគូភាគីនៃកិច្ចសន្យាបញ្ចាំបានព្រមព្រៀងគ្នា ដោយឱ្យម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុអាចទាមទារនូវការប្រាក់នៃសិទ្ធិលើបំណុល ឬធនលាភផ្សេងៗទៀតបាន ដូច្នេះម្ចាស់សិទ្ធិលើការបញ្ចាំអាចអនុវត្តបានចំពោះតែការប្រាក់ ឬធនលាភជាអាទិ៍ដែលដល់កំណត់ពេលសម្រាប់អំឡុងពេល២ឆ្នាំចុងក្រោយប៉ុណ្ណោះ។

## ២.៣.ការរលត់នៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

### ២.៣.១.ការរលត់ដោយការទាមទារ

ក្រមរដ្ឋប្បវេណីខ្មែរបានបញ្ញត្តិអំពីការរលត់នៃហ៊ីប៉ូតែកដោយការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក ពោលគឺប្រសិនបើតតិយជនបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុហ៊ីប៉ូតែកដោយការទិញ ម្ចាស់បំណុលហ៊ីប៉ូតែកអាចទាមទារឱ្យអ្នកទិញនោះសងថ្លៃលក់មកឱ្យខ្លួនបាន ហើយប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនោះធ្វើការសងថ្លៃលក់តាមការទាមទាររបស់ម្ចាស់បំណុលហ៊ីប៉ូតែក នោះហ៊ីប៉ូតែកនឹងត្រូវរលត់។ [54] បញ្ញត្តិនេះចែងឡើងដោយផ្អែកតាមសិទ្ធិតតាំងចំពោះតតិយជនដោយម្ចាស់បំណុលហ៊ីប៉ូតែក ពោលគឺកាលបើហ៊ីប៉ូតែកបានធ្វើឡើងដោយគោរពតាមលក្ខខណ្ឌតតាំងនៃហ៊ីប៉ូតែក នោះម្ចាស់បំណុលហ៊ីប៉ូតែកអាចអះអាងអំពីសិទ្ធិហ៊ីប៉ូតែករបស់ខ្លួនចំពោះតតិយជនបាន។

បញ្ញត្តិនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីការបញ្ចាំអចលនវត្ថុ។[55]

### ២.៣.២.ការរលត់ដោយអាជ្ញាយុកាល

#### ២.៣.២.១.ការរលត់ដោយអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

ដូចដែលបានបកស្រាយពីខាងលើរួចមកហើយ ហ៊ីប៉ូតែកគឺជាសិទ្ធិប្រាតិភោគប្រត្យក្សដែលត្រូវបានបង្កើតឡើងដោយផ្អែកលើសិទ្ធិលើបំណុល ឬអាចនិយាយម្យ៉ាងទៀតថាហ៊ីប៉ូតែកគឺជាសិទ្ធិបន្ទាប់បន្សំនៃសិទ្ធិលើបំណុល។ ហេតុដូច្នេះហើយ បើកាលណាសិទ្ធិលើបំណុលត្រូវបានរលត់ដោយអាជ្ញាយុកាល នឹងនាំឱ្យសិទ្ធិប្រាតិភោគប្រត្យក្សត្រូវរលត់ទៅតាមនោះដែរ។ ហ៊ីប៉ូតែកមិនអាចរលត់ដោយអាជ្ញាយុកាលដោយឯករាជ្យពីសិទ្ធិលើបំណុល

[54] មាត្រា៨៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[55] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បានឡើយ។ ហើយប្រសិនបើម្ចាស់បំណុលហ៊ីប៉ូតែកបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានា(ដូចមានបញ្ញត្តិក្នុងមាត្រា៨៨៩នៃក្រមរដ្ឋប្បវេណី) នោះហ៊ីប៉ូតែកមិនអាចរលត់បានឡើយ បើទោះបីជាម្ចាស់បំណុលមិនបានធ្វើនីតិវិធីផ្អាកអាជ្ញាយុកាលចំពោះហ៊ីប៉ូតែកក៏ដោយ។

បញ្ញត្តិដូចដែលបានបកស្រាយក្នុងចំណុចនេះត្រូវយកមកអនុវត្តដូចគ្នាចំពោះករណីការបញ្ចាំអចលនវត្ថុ។[56]

**២.៣.២.២.ការរលត់ដោយលទ្ធកម្មនូវអចលនវត្ថុដោយអាជ្ញាយុកាល**

ពេលដែលបុគ្គលក្រៅពីកូនបំណុល ឬក្រៅពីអ្នកដែលបានបង្កើតហ៊ីប៉ូតែក បានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ដោយមានលក្ខខណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃការទទួលសិទ្ធិ ហ៊ីប៉ូតែកត្រូវរលត់។[57] មានន័យថា ប្រសិនបើតតិយជនក្រៅពីកូនបំណុល និងអ្នកដែលបានបង្កើតហ៊ីប៉ូតែកបានកាន់កាប់អចលនវត្ថុហ៊ីប៉ូតែក ហើយបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល នោះហ៊ីប៉ូតែកនឹងត្រូវរលត់។ បានជាបញ្ញត្តិនេះគឺចែងយ៉ាងដូច្នេះ ព្រោះការធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល គឺជាលទ្ធកម្មតាំងពីដំបូង ពោលគឺជាលទ្ធកម្មកម្មសិទ្ធិដោយពេញលេញ ដោយគ្មានជាប់បន្ទុកណាមួយនោះទេ។ ចំណុចនេះគឺផ្ទុយពីលទ្ធកម្មបន្ត ដែលតម្រូវឱ្យអ្នកធ្វើលទ្ធកម្មបន្តត្រូវទទួលនូវបន្ទុកទាំងអស់ដែលមានលើវត្ថុនោះ ជាអាទិ៍ដូចជាការទិញអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកដោយតតិយជន គឺជាលទ្ធកម្មបន្ត ដូច្នេះអ្នកទិញត្រូវទទួលបន្ទុកហ៊ីប៉ូតែកលើអចលនវត្ថុនោះផងដែរ។

ប៉ុន្តែក្រមរដ្ឋប្បវេណីក៏បានចែងនូវបញ្ញត្តិមួយដើម្បីការពារម្ចាស់បំណុលហ៊ីប៉ូតែកផងដែរ ពោលគឺប្រសិនបើតតិយជនដែលបានធ្វើលទ្ធកម្មនូវអចលនវត្ថុហ៊ីប៉ូតែកបានដឹងនៅពេលដែលខ្លួនបានធ្វើលទ្ធកម្មថាហ៊ីប៉ូតែកត្រូវបានបង្កើតឡើងលើអចលនវត្ថុនោះ នោះហ៊ីប៉ូតែកមិនត្រូវរលត់ឡើយ។ ដូច្នេះក្នុងករណីដែលអ្នកធ្វើលទ្ធកម្មដោយអាជ្ញាយុកាលជាជនទុច្ចរិត នោះក្រមរដ្ឋប្បវេណីមិនការពារទេ ម្ចាស់បំណុលហ៊ីប៉ូតែកនៅតែអាចអះអាងនូវហ៊ីប៉ូតែកចំពោះតតិយជននោះបានដដែល។ ទុច្ចរិតត្រង់នេះគឺចង់សម្តៅដល់អ្នកធ្វើលទ្ធកម្មបានដឹងអំពីអត្ថិភាពនៃហ៊ីប៉ូតែកលើអចលនវត្ថុនោះ ហើយនៅតែធ្វើលទ្ធកម្ម។

បញ្ញត្តិនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះករណីការបញ្ចាំអចលនវត្ថុ។[58]

៙៙៙🕮៚៚៚

[56] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[57] មាត្រា៨៦៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[58] មាត្រា៨៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូកទី៣
# នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក
# និងការបញ្ចាំអចលនវត្ថុ

# ជំពូកទី៣

# នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ

នៅក្នុងសារណាបទនេះ យើងខ្ញុំក៏ចង់រំលេចផងដែរនូវនីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ។ ប៉ុន្តែដោយសារតែកម្មវត្ថុនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុសុទ្ធសឹងតែជាអចលនវត្ថុ ដូច្នេះការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះគឺពុំសូវមានភាពខុសគ្នាទេ ហេតុនេះហើយយើងខ្ញុំនឹងសរសេរនូវនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះជាមួយគ្នាតែម្តង។ មួយវិញទៀត ដោយសារតែការមើលទៅលើតថភាពសង្គមកម្ពុជាយើងជាក់ស្តែង ភាគច្រើនយើងឃើញថាហ៊ីប៉ូតែកច្រើនកើតមាននៅក្នុងប្រតិបត្តិការកម្ចីប្រាក់នៅធនាគារ ដោយកូនបំណុលបានយកអចលនវត្ថុរបស់ខ្លួនទៅដាក់ជាប្រាតិភោគឱ្យធនាគារ(ម្ចាស់បំណុល)ដើម្បីធានាបំណុលរបស់ខ្លួនដោយមិនផ្ទេរការកាន់កាប់ ប៉ុន្តែធនាគារភាគច្រើនបានបង្កើតខសន្យាពិសេសមួយជាមួយកូនបំណុល ដោយតម្រូវឱ្យកូនបំណុលប្រគល់ប័ណ្ណកម្មសិទ្ធិដាក់តម្កល់នៅធនាគារផងដែរ ទាំងដែលបញ្ញត្តិនេះពុំមានចែងនៅក្នុងច្បាប់នោះទេ ដូច្នេះធ្វើឱ្យកូនបំណុលពុំអាចបង្កើតហ៊ីប៉ូតែកថ្មីលើអចលនវត្ថុដដែលនោះជាមួយម្ចាស់បំណុលផ្សេងទៀតបានទេ ព្រោះម្ចាស់បំណុលផ្សេងទៀតនោះក៏ត្រូវការឱ្យតម្កល់ប័ណ្ណសម្គាល់កម្មសិទ្ធិផងដែរ ដែលនេះទំនងជាកម្អែលដែលនៅសល់ពីការដាក់ធានាដែលមានចែងក្នុងច្បាប់ភូមិបាលចាស់ហើយមើលទៅ ម្យ៉ាងវាធ្វើឱ្យម្ចាស់បំណុលកាន់តែមានទំនុកចិត្តផង។ ហើយក្នុងការអនុវត្តជាក់ស្តែងប្រសិនបើតម្លៃនៃអចលនវត្ថុហ៊ីប៉ូតែកនោះខ្ពស់ជាងតម្លៃនៃសិទ្ធិលើបំណុល ហើយកូនបំណុលមានបំណងចង់ខ្ចីប្រាក់បន្ថែម ភាគច្រើនកូនបំណុលនោះនឹងទៅចរចារជាមួយធនាគារដដែលនោះ ដើម្បីសុំធ្វើកម្ចីបន្ថែម។ អ្វីដែលយើងខ្ញុំលើកឡើងពីតថភាពសង្គមត្រង់ចំណុចនេះគឺចង់បង្ហាញថាការបង្កើតហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយចំពោះម្ចាស់បំណុលផ្សេងគ្នាដូចដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺពុំសូវកើតមានឡើយនៅក្នុងតថភាពសង្គមជាក់ស្តែង ពោលគឺភាគច្រើនអចលនវត្ថុមួយគឺជាប្រាតិភោគសម្រាប់ធានាសិទ្ធិលើបំណុលចំពោះម្ចាស់បំណុលតែមួយប៉ុណ្ណោះ ដូច្នេះហើយសារណាបទរបស់យើងខ្ញុំត្រង់ចំណុចនេះគឺកំណត់វិសាលភាពនៃការបកស្រាយនូវនីតិវិធីនៃការអនុវត្តដោយសន្មតថា **មានម្ចាស់បំណុលនៃការអនុវត្តតែមួយ**ប៉ុណ្ណោះ។

## ៣.១.ការដាក់ពាក្យសុំ និងការពិនិត្យពាក្យសុំ

### ៣.១.១.ការរៀបចំដាក់ពាក្យ

ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀបចំនូវឯកសារចំនួន៤ គឺ៖

❖ ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត

- ❖ រូបមន្តអនុវត្ត
- ❖ លិខិតបញ្ជាក់អំពីការបញ្ជូន
- ❖ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ។

**៣.១.១.១.ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត**

ផ្អែកតាមមាត្រា៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧ ការអនុវត្តសិទ្ធិប្រាតិភោគគឺតម្រូវឱ្យមានលិខិតអនុវត្ត ហើយលិខិតអនុវត្តនោះទៀតសោតត្រូវបានបែងចែកជាពីរប្រភេទគឺ៖

- ❖ សាលក្រម ឬសាលដីកាស្ថាពរដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ។ ឧទាហរណ៍មានដូចជា សាលក្រមស្ថាពរដែលទទួលស្គាល់នូវការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលច្រានចោលការទាមទារនៃបណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃហ៊ីប៉ូតែក សាលក្រមស្ថាពរដែលបង្គាប់ឱ្យធ្វើនីតិវិធីចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក កំណត់ហេតុសះជា ឬកំណត់ហេតុទទួលស្គាល់ការទាមទារដែលមានអត្ថន័យដូចគ្នានឹងសាលក្រមខាងលើនេះជាអាទិ៍។[59]
- ❖ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ។ ត្រង់នេះគឺសម្តៅដល់លិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុ។[60]

ដោយសារតែតុលាការជាអ្នករក្សាទុកនូវច្បាប់ដើមនៃសាលក្រម ឬសាលដីកាស្ថាពរ ដូច្នេះហើយម្ចាស់បំណុលនៃការអនុវត្តត្រូវទៅស្នើសុំលិខិតចម្លងយថាភូតនៃសាលក្រម ឬសាលដីកាស្ថាពរទាំងនោះពីតុលាការដែលបានចេញសាលក្រម ឬសាលដីកានោះ។ ក្រឡាបញ្ជីត្រូវថតចម្លងសាលក្រម ឬសាលដីកាស្ថាពរនោះ ហើយបញ្ជាក់ថាជាឯកសារចម្លងយថាភូត ហើយនិងចុះហត្ថលេខា រួចហើយបញ្ជូនទៅម្ចាស់បំណុលនៃការអនុវត្ត។[61]

ប្រសិនបើនៅពេលបង្កើតហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តបានពឹងពាក់សារការីឱ្យធ្វើលិខិតយថាភូត ដូច្នេះលិខិតយថាភូតនេះគឺមានតម្លៃជាលិខិតអនុវត្ត។ ម្ចាស់បំណុលនៃការអនុវត្តត្រូវស្នើសុំសារការីឱ្យចេញឯកសារចម្លងយថាភូតនៃលិខិតនោះ។

[59] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា៤៩៦

[60] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា៤៩៦

[61] មាត្រា២៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

**៣.១.១.២.រូបមន្តនៃការអនុវត្ត**

នៅពេលដែលម្ចាស់បំណុលនៃការអនុវត្តទទួលបានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តហើយ ក្នុងករណីដែលលិខិតអនុវត្តគឺជាសាលក្រម ឬសាលដីកាស្ថាពរ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់នូវ**ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត** រួមជាមួយនឹង**ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត**ទៅកាន់ក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿង។ ប្រសិនបើលិខិតអនុវត្តគឺជាលិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក នោះម្ចាស់បំណុលនៃការអនុវត្តត្រូវស្នើសុំឱ្យសារការីចេញនូវរូបមន្តនៃការអនុវត្ត។[62] ក្រឡាបញ្ជី ឬសារការីធ្វើការផ្ទៀងផ្ទាត់លើច្បាប់ដើមនៃលិខិតអនុវត្ត និងសំណុំរឿងជាអាទិ៍ ហើយធ្វើការត្រួតពិនិត្យថាតើបានសរសេរអំពីអត្ថិភាពនៃប្រាតិភោគឬអត់ និងធ្វើការពិនិត្យសាលក្រមថាបានចូលជាស្ថាពរហើយឬនៅ ប្រសិនបើយល់ឃើញថាត្រឹមត្រូវ ក្រឡាបញ្ជី ឬសារការីនឹងផ្តល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។[63]

ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តដែលម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់ជូនទៅក្រឡាបញ្ជី ឬសារការី ត្រូវធ្វើឡើងដោយលិខិតជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោមនេះ៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត (ថាតើជាសាលក្រម ឬសាលដីកាស្ថាពរដែលបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬជាលិខិតយថាភូតដែលចេញដោយសារការី)។
- ហេតុការណ៍ និងមូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តនៃអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦(រូបមន្តអនុវត្តពិសេស) ឬកថាខណ្ឌទី១ នៃមាត្រា៣៥៨(ការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់ជាអាទិ៍) នៃក្រមនេះ។[64]

ក្រឡាបញ្ជី ឬសារការីត្រូវចេញរូបមន្តអនុវត្តតាមវិធីសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃ**ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត**នូវចំណុចនីមួយៗដូចដែលមានចែងក្នុងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តនោះ ដោយសរសេរថ្ងៃ ខែ ឆ្នាំ នៃការផ្តល់រូបមន្តនៃការអនុវត្តផង។ ជាធម្មតា រូបមន្តនៃការអនុវត្តសរសេរថា "ម្ចាស់បំណុលនៃការអនុវត្ត ក អាចអនុវត្តហ៊ីប៉ូតែកចំពោះកូនបំណុលនៃការអនុវត្ត ខ បាន ដោយផ្អែកតាមលិខិតនេះ។ *ហត្ថលេខារបស់ក្រឡាបញ្ជី ឬសារការី* និង *កាលបរិច្ឆេទនៃការ*

[62] កថាខណ្ឌទី២, មាត្រា៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[63] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦
[64] កថាខណ្ឌទី១, មាត្រា៣៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

*ចេញរូបមន្តនៃការអនុវត្ត* ប៉ុណ្ណេះគឺមានលក្ខណៈគ្រប់គ្រាន់ហើយ។[65] លើកលែងតែមានស្ថានភាពពិសេសមួយចំនួន ដែលក្រឡាបញ្ជី ឬសារ-ការីត្រូវសរសេរនូវចំណុច ខ គ និង ឃ ដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចូលទៅក្នុងរូបមន្តនៃការអនុវត្ត។

លើសពីនេះទៅទៀត ក្រឡាបញ្ជី ឬសារការីត្រូវសរសេរនូវចំណុចនីមួយៗដូចដែលមានកំណត់ក្នុងកថាខណ្ឌទី១ មាត្រា៣៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅលើច្បាប់ដើមនៃលិខិតអនុវត្តនោះ។

**៣.១.១.៣.លិខិតបញ្ជាក់អំពីការបញ្ជូន**

មុនពេលដាក់ពាក្យសុំអនុវត្តហ៊ីប៉ូតែក ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។ លើសពីនេះទៅទៀត ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តពិសេស នោះរូបមន្តអនុវត្ត និងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃឯកសារដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ដើម្បីទទួលបានរូបមន្តអនុវត្តពិសេស ក៏ត្រូវបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្តផងដែរ។

ប្រសិនបើលិខិតអនុវត្តគឺជាសាលក្រម ឬសាលដីកាស្ថាពរ នោះឯកសារចម្លងយថាភូតនៃលិខិតអនុវត្តត្រូវបញ្ជូនទៅកូនបំណុលនៃការអនុវត្ត ដោយក្រឡាបញ្ជី។ បន្ទាប់ពីបញ្ជូនរួចរាល់ ក្រឡាបញ្ជីត្រូវចេញលិខិតបញ្ជាក់អំពីការបញ្ជូននោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។ ប្រសិនបើលិខិតយថាភូតនៃកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុ ត្រូវបានប្រើប្រាស់ជាលិខិតអនុវត្ត ការបញ្ជូនលិខិតអនុវត្តក្នុងករណីនេះគឺពុំមានចែងក្នុងក្រមរដ្ឋប្បវេណីទេ ដូច្នេះការបញ្ជូនគឺប្រព្រឹត្តទៅស្របតាមបទដ្ឋានគតិយុត្តផ្សេងៗ និងការអនុវត្តជាក់ស្តែងដែលមានលក្ខណៈសមស្រប។[66] ក្នុងករណីដែលសារការីបានធ្វើការបញ្ជូន នោះសារការីត្រូវចេញលិខិតបញ្ជាក់អំពីការបញ្ជូននោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។

**៣.១.១.៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ**

ម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំឱ្យចេញឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ ទៅរដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ ឬដាក់ទៅរដ្ឋបាលសុរិយោដីថ្នាក់កណ្តាលក៏បាន។ ពាក្យសុំឱ្យចេញសេចក្តីបញ្ជាក់នោះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម៖

-គោលបំណងនៃការសុំឱ្យចេញលិខិតបញ្ជាក់

-ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ

-ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំជានីតិបុគ្គល

---

[65] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

[66] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

-ឈ្មោះសៀវភៅចុះបញ្ជី

-អត្តសញ្ញាណអចលនវត្ថុ

-ចំនួនលិខិតបញ្ជាក់

-កាលបរិច្ឆេទនៃការដាក់ពាក្យសុំ។[67]

អ្នកដាក់ពាក្យសុំត្រូវបង់សោហ៊ុយសេវាផងដែរ។ នៅពេលដែលទទួលបាននូវពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ប្រសិនបើពាក្យសុំនោះបានបំពេញត្រឹមត្រូវ និងអ្នកដាក់ពាក្យសុំបានបង់សោហ៊ុយរួចរាល់ហើយ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបញ្ជាក់ឱ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ ឬយ៉ាងយូរបំផុតមិនឱ្យលើសពីរយៈពេល៣ថ្ងៃគិតចាប់ពីថ្ងៃទទួលបានពាក្យសុំ។[68]

### ៣.១.២.ការសេរពាក្យសុំ

#### ៣.១.២.១.ខ្លឹមសារនៃពាក្យសុំឱ្យអនុវត្តដោយបង្ខំ

ទម្រង់នៃពាក្យសុំឱ្យអនុវត្តដោយបង្ខំ ម្ចាស់បំណុលត្រូវបំពេញនូវចំណុចមួយចំនួនដូចដែលមានកំណត់ក្នុងមាត្រា ៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានដូចជា៖

-សញ្ញាណនៃម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុដែលជាកូនបំណុលនៃការអនុវត្ត កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា និងអ្នកតំណាង

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តសិទ្ធិប្រាតិភោគ

-ហេតុការណ៍ និងទំហំនៃផ្នែកនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើធ្វើការអនុវត្តសិទ្ធិប្រាតិភោគចំពោះផ្នែកមួយនៃសិទ្ធិលើបំណុលដែលត្រូវបានធានា។

#### ៣.១.២.២.ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដោយបង្ខំ

ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដោយបង្ខំ គឺសុទ្ធសឹងជាឯកសារទាំងឡាយ ដែលបានរៀបរាប់នៅចំណុចការរៀបចំដាក់ពាក្យ ដែលឯកសារទាំងនោះមានដូចជា៖

-ឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយរូបមន្តអនុវត្ត (កថាខណ្ឌទី២ មាត្រា៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

[67] ប្រការ១៣៨, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ លេខ៣០កយ.ដនស.ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រក្សត្រទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣

[68] ប្រការ១៣៩, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ លេខ៣០កយ.ដនស.ប្រក/១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រក្សត្រទាក់ទងនឹងក្រមរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣

-លិខិតបញ្ជាក់អំពីការបញ្ជូន (មាត្រា៣៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ (កថាខណ្ឌទី២ មាត្រា៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

-លិខិតបញ្ជាក់អំពីសិទ្ធិតំណាង (កថាខណ្ឌទី២ មាត្រា៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

### ៣.១.៣.ការដាក់ពាក្យសុំ

#### ៣.១.៣.១.តុលាការដែលមានសមត្ថកិច្ច

ម្ចាស់បំណុលនៃការអនុវត្តត្រូវយកពាក្យសុំអនុវត្តដោយបង្ខំ និងឯកសារភ្ជាប់ទៅដាក់នៅសាលាដំបូងដែលមានសមត្ថកិច្ច សាលាដំបូងដែលមានសមត្ថកិច្ចត្រង់នេះ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលអចលនវត្ថុតាំងនៅ។[69] ឧទាហរណ៍ថា អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តស្ថិតនៅខេត្តកំពង់ចាម ដូច្នេះ សាលាដំបូងដែលមានសមត្ថកិច្ចក្នុងករណីនេះគឺសាលាដំបូងខេត្តកំពង់ចាម។ លើសពីនេះទៀត សមត្ថកិច្ចតុលាការនេះគឺជាសមត្ថកិច្ចផ្តាច់មុខ ពោលគឺភាគីមិនមានជម្រើសផ្សេង ឬអាចនិយាយថាគូភាគីមិនអាចព្រមព្រៀងគ្នាជ្រើសរើសតុលាការផ្សេងជាតុលាការមានសមត្ថកិច្ចបានឡើយ។[70]

#### ៣.១.៣.២.ការបង់ពន្ធ និងសោហ៊ុយចំណាយផ្សេងៗ

នៅពេលម្ចាស់បំណុលនៃការអនុវត្តយកពាក្យសុំទៅដាក់នៅសាលាដំបូងដែលមានសមត្ថកិច្ច ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធដាក់ពាក្យសុំ។ ផ្អែកតាមមាត្រា៣៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា *ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល។*

ក្រៅពីពន្ធដាក់ពាក្យសុំ ម្ចាស់បំណុលនៃការអនុវត្តក៏ត្រូវបង់ជាមុននូវសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំផងដែរ។ [71] សោហ៊ុយសម្រាប់ការអនុវត្តនេះគឺជាសោហ៊ុយដែលចាំបាច់ដើម្បីធ្វើឱ្យនីតិវិធីនៃការអនុវត្តអាចដំណើរការទៅបាន សោហ៊ុយនេះត្រូវយកមកប្រើប្រាស់ដូចជា សោហ៊ុយចំណាយនៅពេលដែលក្រឡាបញ្ជីធ្វើការបញ្ជូនសំណុំរឿង ឬឯកសារនានាតាមរយៈប្រៃសណីយ៍ ប្រាក់កម្រៃសម្រាប់អ្នកវាយតម្លៃអចលនវត្ថុ ចំណាយសម្រាប់អ្នកសង្កេតការណ៍នៅពេលអនុវត្ត សោហ៊ុយចំណាយនៅពេលដែលក្រឡាបញ្ជីផ្ទុកផ្តាក់ឱ្យចុះបញ្ជីទៅរដ្ឋបាលសុរិយោដីជាអាទិ៍។ សោហ៊ុយសម្រាប់ការអនុវត្តនេះមិនមានបញ្ញត្តិនៅក្នុងច្បាប់ឡើយ តែតុលាការអនុវត្តជាអ្នកសម្រេចប្រកបដោយឆន្ទានុសិទ្ធិ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃការអនុវត្ត

[69] មាត្រា៤១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[70] មាត្រា៣៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[71] កថាខណ្ឌទី១ មាត្រា៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ឧទាហរណ៍ដូចជាស្ថានភាពនៃអចលនវត្ថុ ទីតាំងដែលត្រូវធ្វើការបញ្ជូន មធ្យោបាយនៃការបញ្ជូនជាដើម។ ម្យ៉ាងទៀត យើងដឹងហើយថាសោហ៊ុយសម្រាប់ការអនុវត្តគឺត្រូវបានប៉ាន់ស្មានដោយតុលាការអនុវត្ត ដូច្នេះការប៉ាន់ស្មាននេះមិនអាចត្រឹមត្រូវទាំងស្រុងនោះទេ វាអាចនៅពេលអនុវត្តទៅមានការខ្វះខាតនូវសោហ៊ុយបន្ថែមសម្រាប់ការអនុវត្ត ដូច្នេះត្រង់នេះច្បាប់ក៏បានអនុញ្ញាតឱ្យតុលាការអនុវត្តអាចបង្គាប់ឱ្យបង់សោហ៊ុយបន្ថែមបានក្នុងករណីដែលសោហ៊ុយដែលបង្គាប់ឱ្យបង់ពីដំបូងនេះមានការខ្វះខាត។[72] ហើយប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់សោហ៊ុយទេ តុលាការអនុវត្តអាចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ឬអាចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំបាន។[73]

តាមពិតទៅ សោហ៊ុយសម្រាប់ការអនុវត្តនេះមិនមែនជាបន្ទុករបស់ម្ចាស់បំណុលនៃការអនុវត្តឡើយ ពោលគឺសោហ៊ុយនេះជាបន្ទុករបស់កូនបំណុលនៃការអនុវត្ត។[74] គ្រាន់តែជាដំបូងម្ចាស់បំណុលនៃការអនុវត្តត្រូវចេញសោហ៊ុយសម្រាប់ការអនុវត្តជាមុនសិន ដើម្បីឱ្យនីតិវិធីនៃការអនុវត្តអាចដំណើរការទៅបាន បន្ទាប់មកម្ចាស់បំណុលនៃការអនុវត្តនឹងទទួលបានសោហ៊ុយនេះពីកូនបំណុលនៃការអនុវត្តមកវិញ ពីប្រាក់ដែលបានមកពីការលក់ដោយបង្ខំនូវអចលនវត្ថុ។

### ៣.១.៤.ការពិនិត្យពាក្យសុំ

កាលដែលពាក្យសុំឱ្យអនុវត្តបានដាក់ទៅតុលាការអនុវត្តដែលមានសមត្ថកិច្ចហើយ។ តុលាការអនុវត្តត្រូវពិនិត្យមើលនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះ ថាតើបានសរសេរត្រឹមត្រូវតាមបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៥០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរឬទេ។ បន្ទាប់មកទៀត តុលាការអនុវត្តត្រូវពិនិត្យមើលនូវលិខិតភ្ជាប់ជាមួយពាក្យសុំឱ្យអនុវត្តដូចដែលបានរៀបរាប់ក្នុងចំណុច(៣.១.២.២.)នៃសារណាបទនេះ ថាតើមានគ្រប់គ្រាន់ដែរឬទេ។ ក្រៅពីនេះ តុលាការអនុវត្តក៏ត្រូវពិនិត្យមើលផងដែរនូវការបង់ពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ និងសោហ៊ុយចាំបាច់សម្រាប់នីតិវិធីអនុវត្ត តាមរយៈបង្កាន់ដៃនៃការបង់ពន្ធដែលភ្ជាប់មកជាមួយ។

#### ៣.១.៤.១.ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ

បើតុលាការអនុវត្តពិនិត្យមើលពាក្យសុំ និងឯកសារភ្ជាប់ទាំងឡាយមានភាពត្រឹមត្រូវទាំងទម្រង់ និងខ្លឹមសារតាមបញ្ញត្តិនៃច្បាប់ជាធរមានហើយ ព្រមទាំងអាចបញ្ជាក់បានថា ម្ចាស់បំណុលនៃការអនុវត្តពិតជាមាន

[72] កថាខណ្ឌទី២ មាត្រា៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[73] កថាខណ្ឌទី៣ មាត្រា៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[74] មាត្រា៣៧៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សិទ្ធិប្រាតិ-ភោគប្រត្យក្សពិតប្រាកដមែន នោះតុលាការអនុវត្តនឹងចេញ**ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ** ដែលនេះគឺជាចំណុចចាប់ផ្តើមនៃនីតិវិធីលក់ដោយបង្ខំ។[75]

បញ្ញត្តិនៃមាត្រា៤១៩នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិតម្រូវឱ្យតុលាការអនុវត្តត្រូវប្រកាសអំពីការរឹបអូសអចលនវត្ថុដើម្បីម្ចាស់បំណុលនៃការអនុវត្ត នៅក្នុងដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ។ ហេតុនេះ ជាឧទាហរណ៍ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំអាចសរសេរថា *"ត្រូវចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ ហើយត្រូវរឹបអូសអចលនវត្ថុ..........ដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ដើម្បីសងបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក/ការបញ្ចាំអចលនវត្ថុចំពោះម្ចាស់បំណុលនៃការអនុវត្ត ដោយផ្អែកលើហ៊ីប៉ូតែក/ការបញ្ចាំអចលនវត្ថុ......។"*[76]

ចៅក្រមត្រូវសរសេរនូវព័ត៌មានទាំងឡាយនៅក្នុងដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំឱ្យបានច្បាស់លាស់ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយលិខិតអនុវត្ត និងឯកសារចម្លងយថាភូតនៃសៀវភៅចុះបញ្ជីអចលនវត្ថុ ជាអាទិ៍ ដូចជា សញ្ញាណនៃគូភាគី សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត សញ្ញាណនៃហ៊ីប៉ូតែក/ការបញ្ចាំអចលនវត្ថុ សញ្ញាណនៃសិទ្ធិលើបំណុល។ល។ ដើម្បីបង្កឱ្យនីតិវិធីនៃការអនុវត្តប្រព្រឹត្តទៅបានដោយរលូន។

នៅពេលចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ តុលាការអនុវត្តត្រូវជូនដំណឹងអំពីដីកានេះទៅម្ចាស់បំណុលនៃការអនុវត្តតាមមធ្យោបាយសមរម្យ។ ហើយក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងដាក់ទៅក្នុងសំណុំរឿងនោះ។[77] ហើយត្រូវបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់នេះទៅកូនបំណុលនៃការអនុវត្ត ប៉ុន្តែនៅក្នុងដំណាក់កាលនេះ គួរតែកុំទាន់អាលបញ្ជូនទៅកូនបំណុលនៃការអនុវត្ត[78] ព្រោះបើបញ្ជូនទៅ កូនបំណុលនៃការអនុវត្តនឹងដឹងអំពីការចាប់ផ្តើមលក់ដោយបង្ខំ ដូច្នេះកូនបំណុលនៃការអនុវត្តអាចនឹងធ្វើអនុប្បទាននូវអចលនវត្ថុនៃការអនុវត្តទៅឱ្យតតិយជនក្នុងគោលបំណងរារាំងដំណើរការនៃការអនុវត្តដោយបង្ខំ។

### ៣.១.៤.២.ដីកាសម្រេចលើកចោលពាក្យសុំឱ្យលក់ដោយបង្ខំ

ប្រសិនបើតុលាការអនុវត្តពិនិត្យទៅឃើញថាពាក្យសុំឱ្យអនុវត្ត ឬឯកសារភ្ជាប់ពុំទាន់មានភាពត្រឹមត្រូវទេ នោះតុលាការអនុវត្តនឹងចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ ប៉ុន្តែប្រសិនបើតុលាការអនុវត្តពិនិត្យឃើញថាភាពខ្វះខាតនោះអាចកែតម្រូវបាន តុលាការអនុវត្តអាចកំណត់អំឡុងពេលសមរម្យ ដើម្បី

[75] កថាខណ្ឌទី១ មាត្រា៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[76] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

[77] កថាខណ្ឌទី២ មាត្រា៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[78] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

ឱ្យម្ចាស់បំណុលនៃការអនុវត្តធ្វើការកែតម្រូវបាន [79] យ៉ាងណាមិញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះអាចប្ដឹងជំទាស់បាន [80] ប៉ុន្តែមានតែម្ចាស់បំណុលនៃការអនុវត្តទេដែលអាចប្ដឹងជំទាស់នឹងដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្តនេះបាន រីឯកូនបំណុលនៃការអនុវត្តមិនអាចប្ដឹងជំទាស់ទេ[81] ព្រោះដីកាសម្រេចនេះមិនប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កូនបំណុលនៃការអនុវត្តឡើយ។

តុលាការត្រូវបញ្ជូនដីកាសម្រេចលើកចោលពាក្យសុំនេះទៅម្ចាស់បំណុលនៃការអនុវត្ត តាមមធ្យោបាយនៃការបញ្ជូនដែលសមរម្យដូចដែលមានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ការជូនដំណឹងនេះគឺដើម្បីឱ្យអ្នកដាក់ពាក្យសុំទទួលបានដំណឹង និងឆាប់រូតរះទៅដាក់ពាក្យប្ដឹងជំទាស់ទៅនឹងការលើកចោលនេះ។ វាគ្មានភាពចាំបាច់ទេក្នុងការជូនដំណឹងទៅកូនបំណុលនៃការអនុវត្ត។ នៅពេលបញ្ជូនរួចរាល់ ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងដាក់ទៅក្នុងសំណុំរឿងនោះ។[82]

## ៣.២.ការរឹបអូស

### ៣.២.១.ការផ្ទុកផ្ដាក់ឱ្យចុះបញ្ជីរឹបអូស

ក្រោយពេលដែលតុលាការអនុវត្តបានចេញដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ក្រឡាបញ្ជីត្រូវរៀបចំលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ បន្ទាប់មកត្រូវបញ្ជូនលិខិតផ្ទុកផ្ដាក់នេះទៅរដ្ឋបាលសុរិយោដីរាជធានី/ខេត្ត ដែលអចលនវត្ថុនោះតាំងនៅ។[83]

តើក្រឡាបញ្ជីត្រូវសរសេរអ្វីខ្លះក្នុងលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស? ហើយត្រូវភ្ជាប់នូវលិខិតអ្វីជាមួយលិខិតផ្ទុកផ្ដាក់នោះ? ចំណុចនេះនឹងមានរៀបរាប់ជាបន្តបន្ទាប់ដូចខាងក្រោម។

#### ៣.២.១.១.ខ្លឹមសារនៃលិខិតផ្ទុកផ្ដាក់

លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគត្រូវសរសេរដូចខាងក្រោម៖

**កម្មវត្ថុ៖** សរសេរអំពីខ្លឹមសារការផ្ទុកផ្ដាក់ចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិលើអចលនវត្ថុ ដោយការអនុវត្តសិទ្ធិប្រាតិភោគ

[79] កថាខណ្ឌទី១ មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[80] កថាខណ្ឌទី៣ មាត្រា៤១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[81] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤១៩

[82] កថាខណ្ឌទី៣ មាត្រា២១៣ និងមាត្រា៣៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[83] ប្រការ៧, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ៥៩ ប្រក.ដ.ន.ស/១១ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១

**ក.អត្តសញ្ញាណនៃអចលនវត្ថុ៖** ត្រូវសរសេរ លេខក្បាលដី ឬលេខប័ណ្ណ និងទីតាំងដី។ ក្រឡាបញ្ជីត្រូវអានដីកាសម្រេចចាប់ផ្ដើមការអនុវត្តដោយបង្ខំ និងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឱ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។

**ខ.ឈ្មោះ និងអាសយដ្ឋានរបស់កម្មសិទ្ធិករនៃអចលនវត្ថុ៖** ក្រឡាបញ្ជីត្រូវអានដីកាសម្រេចចាប់ផ្ដើមការអនុវត្តដោយបង្ខំ និងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឱ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។

**គ.គោលបំណងនៃការចុះបញ្ជី៖** ឧទាហរណ៍គេសរសេរថា "រឹបអូសកម្មសិទ្ធិលើអចលនវត្ថុ ចំណុច ក"។

**ឃ.មូលហេតុ៖** ឧទាហរណ៍ គេសរសេរថា "ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំលេខ១២៣៤ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តកំពត"។

**ង.ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត៖** ក្រឡាបញ្ជីត្រូវអានដីកាសម្រេចចាប់ផ្ដើមការអនុវត្តដោយបង្ខំ និងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឱ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។

**ច.ឈ្មោះ និងអាសយដ្ឋានរបស់កូនបំណុលនៃការអនុវត្ត៖** ក្រឡាបញ្ជីត្រូវអានដីកាសម្រេចចាប់ផ្ដើមការអនុវត្តដោយបង្ខំ និងឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុឱ្យបានច្បាស់លាស់ ហើយត្រូវសរសេរតាមអត្តសញ្ញាណទាំងនេះ។[84]

#### ៣.២.១.២.ឯកសារដែលត្រូវភ្ជាប់ជាមួយលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជី

នៅពេលធ្វើការប្រគល់លិខិតផ្ទុកផ្ដាក់ ក្រឡាបញ្ជីត្រូវផ្ដល់ឯកសារចាំបាច់មួយចំនួនទៅឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីទៅតាមប្រភេទនៃលិខិតផ្ទុកផ្ដាក់។ ប្រភេទនៃលិខិតផ្ទុកផ្ដាក់មានច្រើន ចំពោះការសិក្សានេះគឺសម្ដៅលើលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ ដូច្នេះឯកសារដែលត្រូវភ្ជាប់ជាមួយលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីគឺ ***ឯកសារចម្លងយថាភូតនៃដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ***។[85] ពុំមានភាពចាំបាច់ក្នុងការភ្ជាប់នូវប័ណ្ណកម្មសិទ្ធិនៃអចលនវត្ថុឡើយ។

### ៣.២.២.ការចុះបញ្ជីអំពីការរឹបអូស

នៅពេលរដ្ឋបាលសុរិយោដីរាជធានី-ខេត្ត ទទួលបានលិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្តសិទ្ធិប្រាតិភោគ រដ្ឋបាលសុរិយោដីត្រូវចុះបញ្ជីទៅតាមប្រភេទនៃការរឹបអូស។ ប្រភេទនៃការរឹបអូស

---

[84] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

[85] ប្រការ៧, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ៥៩ ប្រក.ដ.ន.ស/១១ ស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១

ត្រង់នេះមានច្រើន ដូចជាការរឹបអូសកម្មសិទ្ធិ ការរឹបអូសចំណែកកម្មសិទ្ធិអវិភាគ ការរឹបអូសសិទ្ធិជួលអចិន្ត្រៃយ៍ និងការរឹបអូសផលុបភោគជាដើម ប៉ុន្តែដោយសារតែក្នុងការអនុវត្តជាក់ស្តែង យើងច្រើនឃើញតែការរឹបអូសកម្មសិទ្ធិ ដូច្នេះយើងផ្តោតការសិក្សាចំពោះតែការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិតែប៉ុណ្ណោះ។

ចំពោះការចុះបញ្ជីអំពីការរឹបអូសកម្មសិទ្ធិនេះ ត្រូវសរសេរក្នុង "សៀវភៅគោលបញ្ជីដីធ្លី" នៅក្នុងខ្ទង់ (Column) ត្រង់ " បន្ទុកលើអចលនវត្ថុ " ដោយត្រូវសរសេរថា ៖

" ត្រូវបានរឹបអូសកម្មសិទ្ធិតាមដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំលេខ .............ចុះថ្ងៃទី.....ខែ....... ឆ្នាំ........(ផ្អែកលើសិទ្ធិប្រាតិភោគ) របស់តុលាការអនុវត្ត.....លរ.Aj.....(ជាទឹកក្រហម) រួចបោះត្រាលេខាចារឹក និងចុះកាលបរិច្ឆេទនៃការចុះបញ្ជី (ជាទឹកខៀវ ឬខ្មៅ) " ។[86]

### ៣.២.៣.ការបញ្ជូនឯកសារ និងដីកាសម្រេច

#### ៣.២.៣.១.ការបញ្ជូនឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

ក្រោយពីបានចុះបញ្ជីអំពីការរឹបអូសរួចរាល់ហើយ រដ្ឋបាលសុរិយោដីត្រូវបញ្ជូននូវលិខិតផ្ទុកផ្តាក់ដែលបានធ្វើរួចនោះទៅក្រឡាបញ្ជី ដោយមានភ្ជាប់ជាមួយនឹងសេចក្តីបញ្ជាក់ពីប្រធានរដ្ឋបាលសុរិយោដីរាជធានី-ខេត្ត ថា "បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម" លើឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ។[87]

#### ៣.២.៣.២.ការបញ្ជូនដីកាសម្រេចចាប់ផ្តើមលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត

ដូចដែលបានបកស្រាយនៅក្នុងចំណុច (៣.១.៤.១.) រួចមកហើយថា ក្រឡាបញ្ជីត្រូវបញ្ជូនដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត រីឯចំពោះម្ចាស់បំណុលនៃការអនុវត្តវិញ ក្រឡាបញ្ជីគ្រាន់តែធ្វើការជូនដំណឹងអំពីដីកាសម្រេចនេះបានហើយ។ ប៉ុន្តែកាលពីដំណាក់កាលនៃការចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំដោយតុលាការអនុវត្ត យើងខ្ញុំបានបកស្រាយរួចហើយថា គឺពុំគួរបញ្ជូនដីកាសម្រេចនេះទៅកូនបំណុលនៃការអនុវត្តភ្លាមនោះទេ គឺគួរតែរង់ចាំនីតិវិធីនៃការចុះបញ្ជីអំពីការរឹបអូសនៅរដ្ឋបាលសុរិយោដីបានប្រព្រឹត្តទៅរួចរាល់សិន ទើបបញ្ជូនដីកាសម្រេចនេះទៅកូនបំណុលនៃការអនុវត្តជាការប្រសើរជាង ព្រោះខ្លាចកូនបំណុលនៃការអនុវត្តដឹងអំពីនីតិវិធីនៃការលក់ដោយបង្ខំ ហើយក៏ធ្វើអនុប្បទានអចលនវត្ថុដែលជាកម្មវត្ថុនៃការរឹបអូសនោះទៅឱ្យតតិយជន ដែលធ្វើឱ្យរាំងស្ទះដល់ការចុះបញ្ជីអំពីការរឹបអូស។

[86] ចំណុចក ប្រការ២៦, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ៥៩ ប្រក.ដ.ន .ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១

[87] ប្រការ៣៨, ប្រកាសអន្តរក្រសួង រវាង ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ៥៩ ប្រក.ដ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១

ដូច្នេះនៅពេលតុលាការអនុវត្តទទួលបាននូវលិខិតផ្ទុកផ្តាក់ និងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុពីរដ្ឋបាលសុរិយោដីរួចមក តុលាការអនុវត្តត្រូវពិនិត្យមើលឯកសារទាំងនោះ រួចធ្វើការបញ្ជូននូវដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំទៅកូនបំណុលនៃការអនុវត្ត។

**៣.២.៤.អានុភាពនៃការរឹបអូស**

ក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាលើសំណួរ៣ ទី១ថាតើអានុភាពនៃការរឹបអូសនឹងកើតមានឡើងនៅពេលណា? ទី២ថាតើអានុភាពនៃការរឹបអូសអចលនវត្ថុមានទៅលើអ្វីខ្លះ? និងទី៣ ថាតើក្រោយពីការរឹបអូសកូនបំណុលនៃការអនុវត្តអាចបន្តប្រើប្រាស់អចលនវត្ថុនោះទៀតបានដែរឬទេ?ហើយបានក្នុងទំហំប៉ុណ្ណា?

ចំពោះសំណួរទី១ អានុភាពនៃការរឹបអូសគឺកើតមានឡើងនៅពេលដែល ***ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ*** ត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។ ប៉ុន្តែប្រសិនបើការចុះបញ្ជីអំពីការរឹបអូសបានធ្វើឡើងមុនពេលដែលដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត នោះ អានុភាពនៃការរឹបអូសនឹងកើតមានឡើងនៅពេលចុះបញ្ជីអំពីការរឹបអូស។[88]

ចំពោះសំណួរទី២ អានុភាពនៃការរឹបអូសអចលនវត្ថុ នឹងកើតមានទៅលើវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ និងជាផ្នែកមួយនៃអចលនវត្ថុនោះ ព្រមទាំងវត្ថុចំណុះ និងសិទ្ធិចំណុះនៃអចលនវត្ថុនោះ។[89]

ចំពោះសំណួរទី៣វិញ គឺក្រោយពីការរឹបអូស កូនបំណុលនៃការអនុវត្តនៅតែអាចប្រើប្រាស់អចលនវត្ថុនោះបានដដែល តែត្រូវបានបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា៤២១ កថាខណ្ឌទី៣ បានកំណត់អំពីទំហំដែលកូនបំណុលនៃការអនុវត្តអាចប្រើប្រាស់អចលនវត្ថុនោះបាន ពោលគឺកូនបំណុលនៃការអនុវត្តអាចប្រើប្រាស់អចលនវត្ថុនោះបានតាមវិធីប្រើប្រាស់ធម្មតា។ និយាយជារួម ការរឹបអូសពុំបានរារាំងកូនបំណុលនៃការអនុវត្តក្នុងការប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តឡើយ ឧទាហរណ៍បើអចលនវត្ថុនោះជាផ្ទះដែលកូនបំណុលនៃការអនុវត្តធ្វើការស្នាក់នៅ ក្រោយការរឹបអូស កូនបំណុលនៃការអនុវត្តនៅតែអាចបន្តស្នាក់នៅលើផ្ទះនោះបានដដែល។ ប៉ុន្តែការរឹបអូសមានអានុភាពហាមឃាត់កូនបំណុលនៃការអនុវត្តមិនឱ្យធ្វើការចាត់ចែងអចលនវត្ថុនោះទៅឱ្យតតិយជនបានឡើយ ហើយទុកតួនាទីនៃការចាត់ចែងនេះជូនតុលាការអនុវត្ត ដើម្បីប្រមូលប្រាក់មកសងម្ចាស់បំណុលនៃការអនុវត្តជាអាទិភាព។ រីឯចំពោះការអាស្រ័យផលលើអចលនវត្ថុនោះវិញ គឺយើងខ្ញុំបានបកស្រាយរួចមកហើយក្នុងចំណុចអានុភាពនៃហ៊ីប៉ូតែកចំពោះផល។

[88] កថាខណ្ឌទី២ មាត្រា៤២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[89] កថាខណ្ឌទី១ មាត្រា៤២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ៣.៣.ការលក់ដោយបង្ខំ

### ៣.៣.១.ការវាយតម្លៃអចលនវត្ថុ

ការវាយតម្លៃអចលនវត្ថុ មានសារប្រយោជន៍ដើម្បីជារបាយការណ៍ជូនតុលាការអនុវត្តសម្រាប់ធ្វើឯកសារលំអិតអំពីវត្ថុ ហើយឯកសារលំអិតអំពីវត្ថុនេះគឺជាមូលដ្ឋានសម្រាប់អ្នកដែលមានបំណងទិញក្នុងការសម្រេចចិត្តថាតើខ្លួននឹងទិញអចលនវត្ថុនៃការអនុវត្តនោះដែរឬទេ។

តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃអចលនវត្ថុដោយផ្អែកលើការស្រាវជ្រាវអំពីសណ្ឋាននៃអចលនវត្ថុ ទំនាក់ទំនងនៃការកាន់កាប់ និងស្ថានភាពបច្ចុប្បន្នឯទៀត។[90] នៅពេលបំពេញភារកិច្ចស្រាវជ្រាវរបស់ខ្លួន អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬអាចទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន។[91] ចំពោះការចូលទៅកាន់អចលនវត្ថុដែលគ្មានចាក់សោរ គឺមិនចោទជាបញ្ហាសម្រាប់អ្នកវាយតម្លៃទេ ប៉ុន្តែមានពេលខ្លះអចលនវត្ថុនោះត្រូវបានចាក់សោរ ក្នុងករណីនេះ អ្នកវាយតម្លៃមិនអាចបំផ្លាញគ្រឿងបិទនោះដោយខ្លួនឯងបានទេ អ្នកវាយតម្លៃត្រូវសុំជំនួយពីអាជ្ញាសាលា ដោយមានការអនុញ្ញាតពីតុលាការអនុវត្ត អាជ្ញាសាលានោះអាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន។[92] មិនត្រឹមតែក្នុងករណីនៃអចលនវត្ថុដែលបិទទ្វារប៉ុណ្ណោះទេ ប្រសិនបើអ្នកវាយតម្លៃជួបនូវឧបសគ្គផ្សេងៗដែលប្រឆាំង ឬរាំងដល់ដំណើរការនៃការអនុវត្តរបស់ខ្លួន អ្នកវាយតម្លៃនោះក៏អាចស្នើសុំជំនួយពីអាជ្ញាសាលាបានដែរ ប៉ុន្តែដើម្បីសុំជំនួយនេះ អ្នកវាយតម្លៃត្រូវទទួលបានការអនុញ្ញាតពីតុលាការអនុវត្តជាមុនសិន។[93]

មួយវិញទៀត ប្រសិនបើអ្នកវាយតម្លៃធ្វើការចូលទៅទីកន្លែងរស់នៅដើម្បីបំពេញមុខនាទីរបស់ខ្លួន ប្រសិនបើមិនបានជួបនឹងអ្នកចម្បងនៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អ្នកវាយតម្លៃត្រូវចូលទៅក្នុងទីកន្លែងរស់នៅនោះដោយមានវត្តមានរបស់មន្ត្រីឃុំ សង្កាត់ មន្ត្រីនគរបាល ឬអ្នកដទៃទៀតដែលអាចទទួលស្គាល់ថាជាសាក្សីសមរម្យ។[94]

[90] កថាខណ្ឌទី១ មាត្រា៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[91] កថាខណ្ឌទី៣ មាត្រា៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[92] កថាខណ្ឌទី២ និងកថាខណ្ឌទី៤ មាត្រា៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[93] កថាខណ្ឌទី២ មាត្រា៣៣៨ និងកថាខណ្ឌទី២ មាត្រា៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[94] មាត្រា៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បន្ទាប់ពីធ្វើការស្រាវជ្រាវអំពីអចលនវត្ថុរួចរាល់ អ្នកវាយតម្លៃត្រូវរៀបចំនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះដាក់ជូនតុលាការអនុវត្ត។[95]

ក្រៅពីការវាយតម្លៃដោយអ្នកវាយតម្លៃដែលបានបកស្រាយនៅផ្នែកខាងលើនេះ ក្នុងករណីចាំបាច់ដើម្បីធ្វើឯកសារលំអិតអំពីវត្ថុ ឬដែលតុលាការយល់ឃើញមានកង្វះខាតព័ត៌មានក្នុងការធ្វើឯកសារលំអិតអំពីវត្ថុ តុលាការអនុវត្តអាចបង្គាប់ឱ្យអាជ្ញាសាលាស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ ដូចជាសណ្ឋាននៃអចលនវត្ថុ ស្ថានភាពនៃការកាន់កាប់ រចនាសម្ព័ន្ធនៃអគារ(បើមានអគារ ឬបើកម្មវត្ថុនៃការអនុវត្តគឺជាអគារ)ជាអាទិ៍ ហើយធ្វើរបាយការណ៍លទ្ធផលនៃការស្រាវជ្រាវនោះជាលាយលក្ខណ៍អក្សរជូនទៅតុលាការអនុវត្តវិញ។ អាជ្ញាសាលាដែលទទួលការបង្គាប់ពីតុលាការអនុវត្តឱ្យចុះទៅធ្វើការស្រាវជ្រាវអំពីស្ថានភាពនៃអចលនវត្ថុ មានសិទ្ធិអំណាចដូចគ្នាទៅនឹងសិទ្ធិអំណាចរបស់អ្នកវាយតម្លៃដូចដែលបានរៀបរាប់ខាងលើដែរ ពោលគឺអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬអាចទាមទារឱ្យបង្ហាញឯកសារ ចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះបាន។ [96] តាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីត្រង់មាត្រា៤៣៤ និងមាត្រា៣៣៨ កថាខណ្ឌទី១ បានផ្តល់សិទ្ធិអំណាចដល់អាជ្ញាសាលាក្នុងពេលអនុវត្តភារកិច្ចខ្លួន អាចធ្វើការចាត់ចែងចាំបាច់ដើម្បីបើកទ្វារដែលបិទបាន ព្រមទាំងអាចប្រើកម្លាំង ឬសុំជំនួយពីនគរបាល ឬកម្លាំងផ្សេងទៀត ក្នុងករណីដែលជួបប្រទះនឹងការប្រឆាំង។

### ៣.៣.២.ឯកសារលំអិតអំពីវត្ថុ

បន្ទាប់ពីទទួលបានរបាយការណ៍វាយតម្លៃអំពីអ្នកវាយតម្លៃ ឬរបាយការណ៍ស្រាវជ្រាវបន្ថែមពីអាជ្ញាសាលាហើយ(ក្នុងករណីចាំបាច់) តុលាការអនុវត្តត្រូវចាប់ផ្តើមធ្វើឯកសារលំអិតអំពីវត្ថុ។ ឯកសារលំអិតអំពីវត្ថុត្រូវសរសេរដូចខាងក្រោមនេះ ៖

- សញ្ញាណនៃអចលនវត្ថុ
- សិទ្ធិលើអចលនវត្ថុដែលនឹងបន្តអត្ថិភាពក្រោយការលក់ តាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា៤៣១ (សិទ្ធិដែលនឹងបន្តអត្ថិភាព និងសិទ្ធិដែលត្រូវរលត់ក្រោយការលក់) នៃក្រមនីតិវិធីរដ្ឋប្បវេណី និងការអនុវត្តការចាត់ចែងបណ្តោះអាសន្ន ដែលមិនបាត់បង់អានុភាពដោយការលក់។[97]

[95] កថាខណ្ឌទី៤ មាត្រា៤៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[96] កថាខណ្ឌទី៣ និងកថាខណ្ឌទី៤ មាត្រា៤៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[97] កថាខណ្ឌទី១ មាត្រា៤៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការត្រូវទុកឯកសារចម្លងនៃឯកសារលំអិតអំពីវត្ថុនោះ នៅតុលាការអនុវត្ត ជាមួយគ្នានឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃ ដើម្បីផ្តល់ជូនសាធារណៈជនមើល។

### ៣.៣.៣.នីតិវិធីកំណត់តម្លៃលក់អប្បបរមា

ក្រោយពីតុលាការទទួលបានរបាយការណ៍ពីអ្នកវាយតម្លៃ ឬអាជ្ញាសាលា រួចមក តុលាការអនុវត្តត្រូវកំណត់តម្លៃលក់អប្បបរមា ដោយផ្អែកលើរបាយការណ៍វាយតម្លៃនោះ។[98] ជាគោលការណ៍តុលាការអនុវត្តត្រូវកំណត់តម្លៃអប្បបរមាតាមចំនួនទឹកប្រាក់ដែលបានវាយតម្លៃដោយអ្នកវាយតម្លៃ ប៉ុន្តែបើតុលាការអនុវត្តក្រោយពីបានផ្ទៀងផ្ទាត់ជាមួយឯកសារផ្សេងៗទៀត រកឃើញថាការគណនារបស់អ្នកវាយតម្លៃមានកំហុស នោះបើមានភាពចាំបាច់ តុលាការអនុវត្តអាចបង្គាប់ឱ្យអ្នកវាយតម្លៃធ្វើការវាយតម្លៃម្តងទៀត តែបើគ្មានភាពចាំបាច់ក្នុងការវាយតម្លៃម្តងទៀតទេ(អាចនិយាយថាកំហុសនោះមានលក្ខណៈតិចតួច) នោះតុលាការអនុវត្តអាចកំណត់តម្លៃអប្បបរមាខុសពីចំនួនទឹកប្រាក់ដែលវាយតម្លៃដោយអ្នកវាយតម្លៃបាន។[99]

### ៣.៣.៤.ប្រភេទនៃការលក់ដោយបង្ខំចំពោះការលក់អចលនវត្ថុ

ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤៣៦ កថាខណ្ឌទី១ ចែងថា *ការលក់អចលនវត្ថុ ត្រូវអនុវត្តតាមវិធីលក់ឡាយឡុយដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់។* ផ្អែកតាមបញ្ញត្តិនេះ យើងឃើញថាក្នុងការអនុវត្តការលក់ដោយបង្ខំចំពោះអចលនវត្ថុ គឺមានវិធីពីរប្រភេទ ទី១ការលក់ឡាយឡុយដោយស្រោមសំបុត្រ និងទី២ការលក់ឡាយឡុយដោយផ្ទាល់មាត់។ តើវិធីនៃការលក់ឡាយឡុងទាំងពីរប្រភេទនេះមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច? ហើយមានគុណសម្បត្តិខុសគ្នាយ៉ាងដូចម្តេចដែរ?

#### ៣.៣.៤.១.ការលក់ឡាយឡុងដោយស្រោមសំបុត្រ

វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ គឺជាវិធីលក់ដែលតាមរយៈនោះ អ្នកស្នើសុំទិញមកជួបជុំគ្នាតាមកាលបរិច្ឆេទនៃការលក់ និងទីតាំងដែលកំណត់ដោយតុលាការអនុវត្ត ហើយធ្វើសំណើទិញដោយដាក់ឯកសារដេញថ្លៃដែលមានបញ្ជាក់ពីថ្លៃសុំទិញនៅក្នុងនោះ។ បន្ទាប់មក គេនឹងបើកឯកសារដេញថ្លៃទាំងនោះ ហើយប្រកាសអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា នៅលើឆាក។ វិធីលក់នេះមានគុណសម្បត្តិត្រង់ថា នឹងមិនធ្វើឱ្យបុគ្គលដែលចង់ទិញ ដឹងអំពីកម្មវត្ថុ និងថ្លៃដែលបុគ្គលផ្សេងទៀតហ៊ានឱ្យទេ ព្រោះថាអ្នកស្នើសុំទិញម្នាក់ៗ ដាក់សំណើអំពីថ្លៃទិញរបស់ខ្លួន នៅក្នុងឯកសារដែលបិទជិត។ ហេតុនេះ នាំឱ្យគេអាចទប់ស្កាត់ការប្រើល្បិចកល និង

[98] កថាខណ្ឌទី១ មាត្រា៤៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[99] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

ការឃុបឃិតដើម្បីបញ្ចុះតម្លៃលក់បាន។ វិធីនេះក៏អាចឱ្យគេបញ្ឆៀសមិនឱ្យអ្នកស្នើសុំទិញរងការគាបសង្កត់ដោយសារបរិយាកាសកន្លែងលក់ ឬដោយសារអ្នកប្រកួតប្រជែងមិនស្មោះត្រង់។[100]

**៣.៣.៤.២.ការលក់ឡាយឡុងដោយផ្ទាល់មាត់**

ការលក់ឡាយឡុងដោយផ្ទាល់មាត់ គឺជាវិធីលក់ដែលតាមរយៈនោះ អ្នកស្នើសុំទិញ ធ្វើសំណើទិញដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការលក់ ហើយពួកគេដេញថ្លៃឡើង រហូតដល់ពេលគេអាចកំណត់អ្នកដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេបាន។ គុណសម្បត្តិនៃការលក់តាមវិធីនេះ គឺអ្នកស្នើសុំទិញ ដឹងអំពីចំនួនទឹកប្រាក់ដែលដៃគូប្រកួតប្រជែងរបស់ខ្លួនដាក់ស្នើ ហើយដេញថ្លៃឡើងឱ្យខ្ពស់ជាងថ្លៃដែលគេបានស្នើនោះ ដូច្នេះធ្វើឱ្យតម្លៃនៃការលក់កើនឡើងជាបន្តបន្ទាប់ និយាយឱ្យខ្លី គឺការប្រើវិធីនេះអាចធ្វើឱ្យវត្ថុលក់បានថ្លៃ។[101]

**៣.៣.៥.ការបង្គាប់ឱ្យអនុវត្តការលក់**

ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤៣៦ កថាខណ្ឌទី៣ បានបញ្ញត្តិថា *ប្រសិនបើលក់តាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឱ្យអាជ្ញាសាលាអនុវត្តការលក់។* ដូច្នេះតាមបញ្ញត្តិនេះ យើងឃើញថាប្រសិនបើគ្មានកាលៈទេសៈពិសេសដែលតម្រូវឱ្យលុបចោលនីតិវិធីនៃការលក់ដោយបង្ខំទេ តុលាការអនុវត្តត្រូវកំណត់អំពីវិធីនៃការលក់ កាលបរិច្ឆេទនៃការលក់ និងទីកន្លែងនៃការលក់ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ហើយអាជ្ញាសាលាគឺជាអ្នកទទួលបន្ទុកអនុវត្តនីតិវិធីនៃការលក់នេះ។

**៣.៣.៦.ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ដោយបង្ខំ**

បន្ទាប់ពីតុលាការអនុវត្តបានកំណត់អំពីវិធីនៃការលក់ (ដែលអាចជាការលក់ដោយស្រោមសំបុត្រ ឬការលក់ដោយផ្ទាល់មាត់) ទីកន្លែងនៃការលក់ និងកាលបរិច្ឆេទនៃការលក់រួចរាល់ហើយ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់ តម្លៃលក់អប្បបរមា ព្រមទាំងកាលបរិច្ឆេទ និងទីកន្លែងនៃការលក់។ [102] ការប្រកាសជាសាធារណៈនេះគឺដើម្បីឱ្យសាធារណៈជនបានទទួលដឹងអំពីព័ត៌មាននៃការលក់ដោយបង្ខំនូវអចលនវត្ថុ ជាពិសេសគឺសញ្ញាណនៃអចលនវត្ថុ។

**៣.៣.៧.នីតិវិធីនៃការលក់**

ដូចដែលយើងបានដឹងពីចំណុចមុនហើយថា ការលក់ឡាយឡុងអចលនវត្ថុមានពីរ គឺការលក់ឡាយឡុងដោយស្រោមសំបុត្រ និងការលក់ឡាយឡុងដោយផ្ទាល់មាត់។ តែទោះជាក្នុងនីតិវិធីនៃការលក់មួយ

[100] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រ១០៤

[101] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, ទំព័រ១០៤

[102] កថាខណ្ឌទី៤ មាត្រា៤៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ណាក៏ដោយ ក៏ជនដែលបម្រុងនឹងធ្វើសំណើទិញអចលនវត្ថុ ត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ នៃតម្លៃលក់អប្បបរមា។ ប៉ុន្តែបើយល់ថាចាំបាច់ តុលាការអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានា លើសពីចំនួន ១ ភាគ ១០ បាន។[103] ការដាក់ប្រាក់ធានានេះ មានគោលបំណងការពារកុំឱ្យអ្នកស្នើសុំទិញមិនបង់ថ្លៃលក់។[104] ព្រោះបើអ្នកស្នើសុំទិញដែលក្លាយជាអ្នកទិញហើយមិនបង់ថ្លៃលក់ទេ តុលាការអនុវត្តនឹងរឹបអូសប្រាក់ធានានេះ ដើម្បីជាការដាក់ទណ្ឌកម្ម។ តែបើអ្នកទិញ បង់ថ្លៃលក់ គឺត្រូវបង់តែចំណែកដែលនៅសល់ក្រៅពីចំនួននៃប្រាក់ធានានោះប៉ុណ្ណោះ។ រីឯចំពោះបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាវិញ ក្រោយពីពេលបញ្ចប់នីតិវិធីនៃការលក់ហើយ តុលាការអនុវត្តត្រូវសងវិញភ្លាមនូវប្រាក់ធានាដែលពួកគេបានដាក់។[105]

គោលដៅសំខាន់នៃកាលបរិច្ឆេទនៃការលក់ គឺដើម្បីកំណត់រកអ្នកដែលស្នើសុំទិញក្នុងតម្លៃអតិបរមា។ ចំពោះការលក់ដោយផ្ទាល់មាត់ គឺអ្នកដែលឱ្យតម្លៃខ្ពស់ជាងគេបង្អស់ គឺត្រូវបានកំណត់ថាជាអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា។ ចំពោះការលក់ដោយស្រោមសំបុត្រវិញ បន្ទាប់ពីអ្នកស្នើសុំទិញបានដាក់ឯកសារស្នើសុំទិញទៅអាជ្ញាសាលារួចរាល់ហើយ អាជ្ញាសាលានឹងបើកស្រោមសំបុត្រនៅចំពោះមុខអ្នកស្នើសុំទិញទាំងអស់ដែលមានវត្តមាន ហើយកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា។ ប៉ុន្តែដោយសារតែក្នុងនីតិវិធីនេះ អ្នកស្នើសុំទិញទាំងអស់ពុំអាចដឹងពីតម្លៃដែលអ្នកស្នើសុំទិញផ្សេងបានដាក់នោះទេ ដូច្នេះវាអាចកើតមានករណីដែលមានអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាច្រើននាក់ ដូច្នេះអាជ្ញាសាលាត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយឱ្យអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត។ ប្រសិនបើអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាទាំងនោះមិនព្រមធ្វើការដេញថ្លៃម្តងទៀតទេ ឬករណីដែលនៅតែមានអ្នកហ៊ានឱ្យថ្លៃស្មើគ្នាទៀត នោះត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយការចាប់ឆ្នោត។[106]

បន្ទាប់ពីកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាហើយ អាជ្ញាសាលាត្រូវប្រកាសនូវនាម ឬនាមករណ៍របស់អ្នកទិញក្នុងតម្លៃអតិបរមានោះ និងថ្លៃលក់ឡាយឡុង ជាចុងក្រោយអាជ្ញាសាលាត្រូវប្រកាសបញ្ចប់កាលបរិច្ឆេទនៃការលក់ឡាយឡុង។[107]

យើងដឹងហើយថា អាជ្ញាសាលាគឺជាអ្នកប្រារព្ធនូវការលក់ ដូច្នេះដើម្បីធានាឱ្យការលក់ប្រព្រឹត្តទៅបានដោយរលូន ក្រមរដ្ឋប្បវេណីមាត្រា៣៩៦ បានផ្តល់អំណាចដល់អាជ្ញាសាលាក្នុងការរក្សាសណ្តាប់ធ្នាប់នៃទី

[103] កថាខណ្ឌទី១ មាត្រា៤៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[104] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៤៣៧
[105] កថាខណ្ឌទី២ មាត្រា៤៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[106] កថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា៤៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[107] កថាខណ្ឌទី១ មាត្រា៤៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

កន្លែងលក់ ដោយអាជ្ញាសាលាអាចកម្រិតជនទាំងឡាយណាដែលរំខាន ឬធ្វើឱ្យប៉ះពាល់ដល់ការប្រកួតប្រជែងដោយស្មោះត្រង់ មិនឱ្យចូលក្នុងកន្លែងលក់ ឬអាចដេញជនទាំងនោះចេញពីកន្លែងលក់ ឬអាចមិនឱ្យស្នើសុំទិញបានទៀតផង។

ក្រោយពីបានអនុវត្តនូវការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់ ហើយត្រូវដាក់ជូនទៅតុលាការអនុវត្ត ខ្លឹមសារលំអិតដែលអាជ្ញាសាលាត្រូវសរសេរក្នុងកំណត់ហេតុមានកំណត់ក្នុងកថាខណ្ឌទី៤ នៃមាត្រា ៤៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ អាជ្ញាសាលាត្រូវឱ្យអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬអ្នកតំណាងចុះហត្ថលេខាលើកំណត់ហេតុនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់នោះ។

### ៣.៣.៨.អ្នកដែលគ្មានសិទ្ធិចូលរួមទិញអចលនវត្ថុ

ត្រង់នេះយើងមានសំណួរពីរត្រូវលើកឡើង ទី១តើម្ចាស់បំណុលនៃការអនុវត្តអាចទិញអចលនវត្ថុហ៊ីប៉ូតែកបានដែរឬទេ? ចុះកូនបំណុលនៃការអនុវត្តវិញ?

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីគឺពុំមានបញ្ញត្តិណាមួយចែងហាមឃាត់ម្ចាស់បំណុលនៃការអនុវត្តមិនឱ្យទិញអចលនវត្ថុហ៊ីប៉ូតែកឡើយ។ ដូច្នេះម្ចាស់បំណុលហ៊ីប៉ូតែកអាចចូលរួមទិញអចលនវត្ថុបាន។

ចំពោះកូនបំណុលនៃការអនុវត្តវិញ មាត្រា៤៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិយ៉ាងច្បាស់ហាមឃាត់មិនឱ្យធ្វើសំណើទិញឡើយ។ នេះក៏ដោយសារតែនីតិនិពន្ធគិតថា ប្រសិនបើកូនបំណុលនៃការអនុវត្តមានប្រាក់សម្រាប់ទិញអចលនវត្ថុ គួរណាស់តែយកប្រាក់នេះទៅសងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្តវិញប្រសើរជាង ជាជាងការអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំនាំតែស្មុគស្មាញ។ ប៉ុន្តែវាក៏អាចមានករណីដែលកូនបំណុលនៃការអនុវត្ត មិនមែនជាកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានា បើនិយាយឱ្យងាយយល់គឺ កូនបំណុលនៃការអនុវត្តគឺជា**អ្នកធានាដោយវត្ថុ** ក្នុងករណីនេះកូនបំណុលនៃការអនុវត្តអាចស្នើសុំទិញអចលនវត្ថុបាន ព្រោះគេអាចបកស្រាយបានថាកូនបំណុលនៃការអនុវត្តមិនមានកាតព្វកិច្ចសងសិទ្ធិលើបំណុលចំពោះម្ចាស់បំណុលនៃការអនុវត្តឡើយ។[108]

ក្រៅពីនេះ យើងក៏គួរចាប់អារម្មណ៍ផងដែរចំពោះមាត្រា៥២៥ និង៥២៦ នៃក្រមរដ្ឋប្បវេណីដែលបានចែងអំពីបុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន ដែលក្នុងនោះគឺសុទ្ធសឹងតែជាអ្នកមានសមត្ថកិច្ច ឬជាអ្នកដែលមានទំនាក់ទំនងទៅនឹងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជាអាទិ៍ដូចជា ចៅក្រម ព្រះរាជអាជ្ញា មេធាវី ក្រឡាបញ្ជី ឬមន្ត្រីតុលាការ មន្ត្រីរាជការផ្សេងទៀតដែលទទួលបន្ទុកក្នុងរឿងអនុវត្តដោយបង្ខំនេះជាដើម។

[108] SHIMANUKI Masao ជំនាញការជប៉ុន, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

### ៣.៣.៩.ដីកាសម្រេចអនុញ្ញាតឱ្យលក់ ឬដីកាសម្រេចមិនអនុញ្ញាតឱ្យលក់

កាលបរិច្ឆេទនៃការលក់ដែលដឹកនាំដោយអាជ្ញាសាលាគឺមានគោលដៅដើម្បីកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ប៉ុន្តែអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានេះមិនប្រាកដថានឹងអាចក្លាយជាអ្នកទិញបាននោះទេ បន្ទាប់ពីនីតិវិធីនៃការលក់បានបញ្ចប់ហើយ តុលាការអនុវត្តត្រូវផ្ទៀងផ្ទាត់មើលឡើងវិញអំពីនីតិវិធីនៃការអនុវត្តតាំងពីដំណាក់កាលនៃការចេញដីកាសម្រេចចាប់ផ្ដើមលក់ រហូតដល់ការបញ្ចប់ការលក់ ដើម្បីឈានទៅដល់ការកំណត់អំពីអ្នកទិញ។ ក្នុងគោលដៅដើម្បីកំណត់នូវវិការៈដែលឈានទៅដល់ការសម្រេចមិនអនុញ្ញាតឱ្យលក់ឱ្យបានច្បាស់លាស់ ក្រមនីតិវិធីរដ្ឋប្បវេណីត្រង់មាត្រា ៤៤២ កថាខណ្ឌទី២ បានបញ្ញត្តិអំពីវិការៈទាំងនេះ ដូច្នេះប្រសិនបើតុលាការអនុវត្តពិនិត្យទៅឃើញថាមានហេតុដូចដែលបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា ៤៤២ នេះកើតឡើង តុលាការអនុវត្តត្រូវចេញដីកាសម្រេចមិនអនុញ្ញាតឱ្យលក់។តែបើតុលាការអនុវត្តពិនិត្យលើនីតិវិធីទៅឃើញថាត្រឹមត្រូវតាមច្បាប់ហើយ ជាពិសេសគឺគ្មានវិការៈដូចដែលកំណត់ក្នុងមាត្រា៤៤២ ទេ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យលក់ នៅពេលនោះអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមានឹងក្លាយជាអ្នកទិញពិតប្រាកដហើយ។ មួយវិញទៀតតុលាការត្រូវកំណត់កាលបរិច្ឆេទចេញដីកាសម្រេចការលក់ជាមុន រួចជូនដំណឹងទៅជនដែលពាក់ព័ន្ធផលប្រយោជន៍ ហើយនៅកាលបរិច្ឆេទនោះ ជនដែលពាក់ព័ន្ធផលប្រយោជន៍អាចថ្លែងយោបល់អំពីហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា ៤៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបាន។[109]

### ៣.៣.១០.ការបង់ថ្លៃលក់

នៅពេលដែលដីកាសម្រេចអនុញ្ញាតការលក់ចូលជាស្ថាពរ តុលាការអនុវត្តត្រូវកំណត់ពេលនៃការបង់ថ្លៃលក់ រួចជូនដំណឹងទៅអ្នកទិញ ពេលកំណត់នេះត្រូវស្ថិតនៅក្នុងអំឡុងពេល១ខែគិតចាប់ពីថ្ងៃចេញដីកាសម្រេចអនុញ្ញាតឱ្យលក់បានចូលជាស្ថាពរ។ អ្នកទិញត្រូវបង់ថ្លៃលក់ឱ្យទាន់ពេលកំណត់នោះ ហើយអ្នកទិញត្រូវបង់ថ្លៃលក់ដែលជាប្រាក់នៅសល់បន្ទាប់ពីដកប្រាក់ធានាចេញពីចំនួនទឹកប្រាក់នៃសំណើ។ [110] បើអ្នកទិញមិនបង់ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឱ្យលក់នឹងបាត់បង់អានុភាព តុលាការអនុវត្តត្រូវលក់ដោយបង្ខំសាជាថ្មី ក្នុងករណីនេះផងដែរ អ្នកទិញពីមុននោះនឹងមិនអាចទាមទារប្រាក់ធានារបស់ខ្លួនពីតុលាការអនុវត្តវិញបានទេ ហើយក៏គ្មានសិទ្ធិធ្វើសំណើទិញក្នុងនីតិវិធីនៃការលក់ថ្មីនេះដែរ។[111]

---

[109] មាត្រា៤៤០ និងមាត្រា៤៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[110] កថាខណ្ឌទី២ និងកថាខណ្ឌទី២ នៃ មាត្រា៤៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[111] មាត្រា៤៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ៣.៤.ការប្រមូលសិទ្ធិលើបំណុលដោយម្ចាស់បំណុលនៃការអនុវត្ត

នេះគឺជាដំណាក់កាលចុងក្រោយបំផុតហើយនៃនីតិវិធីនៃការអនុវត្ត ប៉ុន្តែតាមពិតទៅគឺនៅមានដំណាក់-កាលនៃការបែងចែកចំណែកមួយទៀត ក្នុងករណីដែលមានម្ចាស់បំណុលច្រើននាក់ ប៉ុន្តែដូចដែលយើងខ្ញុំបានកំណត់វិសាលភាពនៃការសិក្សា គឺយើងផ្តោតការសិក្សាក្នុងករណីដែលមានម្ចាស់បំណុលតែម្នាក់ ដូច្នេះនីតិវិធីគឺបញ្ចប់ត្រឹមនេះ។ ម្ចាស់បំណុលនៃការអនុវត្តអាចទទួលបានការសងជាអាទិភាពត្រឹមទំហំសិទ្ធិលើបំណុលដែលធានាដោយច្បាប់ ដូចដែលបានបកស្រាយក្នុងចំណុចមុនៗរួចហើយ។

# សេចក្ដីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ មានអាយុកាលចំណាស់ណាស់ទៅហើយក្នុងនីតិរដ្ឋប្បវេណីខ្មែរ ប៉ុន្តែនៅតែមានការយល់ច្រឡំខ្លះៗពីសំណាក់មជ្ឈដ្ឋានសាធារណៈជនទូទៅ ដូច្នេះឆ្លងតាមការសិក្សាដ៏ម៉ត់ចត់របស់យើងខ្ញុំ បានធ្វើការស្រាយនូវការច្រលំនេះ ដោយបញ្ជាក់ជូននូវលក្ខណៈដូច និងលក្ខណៈខុសគ្នាដូចខាងក្រោមនេះ។

ចំពោះលក្ខណៈដូច ជាបឋមយើងឃើញថាកម្មវត្ថុនៃការបង្កើតហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុគឺសុទ្ធសឹងតែជាអចលនវត្ថុដូចគ្នា ហើយដែលបានចុះបញ្ជីត្រឹមត្រូវនៅរដ្ឋបាលសុរិយោដី ពោលគឺជាអចលនវត្ថុដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ។ ភាពដូចគ្នាទី២ គឺអំពីលក្ខខណ្ឌតតាំង ពោលគឺទាំងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ ត្រូវបង្កើតឡើងក្នុងទម្រង់ជាលិខិតយថាភូត និងត្រូវយកទៅចុះបញ្ជីនៅរដ្ឋបាលសុរិយោដីថ្នាក់រាជធានី-ខេត្ត ទើបអាចអះអាងអំពីសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះចំពោះតតិយជនបាន។ ភាពដូចគ្នាទី៣ គឺទំហំអានុភាពនៃហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុគឺដូចគ្នា ពោលគឺការបង្កើតហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុលើដីមួយ វានឹងមានអានុភាពចំពោះវត្ថុទាំងឡាយដែលភ្ជាប់នឹងដីនោះ ហើយដែលជាផ្នែកមួយនៃដីនោះ ព្រមទាំងអគារផងដែរ ហើយទោះបីជាវត្ថុ ឬអគារនោះ ត្រូវបានភ្ជាប់ ឬសាងសង់ឡើងក្រោយការបង្កើតហ៊ីប៉ូតែកក៏ដោយ បើអគារនោះគឺជាកម្មសិទ្ធិរបស់អ្នកបង្កើតហ៊ីប៉ូតែក ឬការបញ្ចាំ នោះហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុក៏នឹងបង្កើតអានុភាពលើវត្ថុដែលភ្ជាប់លើដី និងអគារនោះផងដែរ។ ភាពដូចគ្នាទី៤ គឺទាក់ទងទៅនឹងទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ពោលគឺប្រសិនបើក្នុងការបង្កើតហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុនោះ មានការព្រមព្រៀងគ្នាអំពីការប្រាក់ ធនលាភផ្សេងទៀត ឬសំណងនៃការខូចខាត នោះហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុមានអានុភាពចំពោះតែការប្រាក់ ធនលាភផ្សេងទៀត ឬសំណងនៃការខូចខាតដែលដល់ពេលកំណត់សងពីរឆ្នាំចុងក្រោយប៉ុណ្ណោះ លើកលែងតែធនលាភដែលបានចុះបញ្ជីពិសេស។ ភាពដូចគ្នាទី៥ យើងដឹងហើយថាតតិយជនអាចយកនូវអចលនវត្ថុរបស់ខ្លួនមកដាក់ហ៊ីប៉ូតែក ឬបញ្ចាំដើម្បីធានាបំណុលអ្នកដទៃបាន ការណ៍នេះគេហៅតតិយជននោះថាជា អ្នកធានាដោយវត្ថុ ដូច្នេះក្នុងករណីដែលអ្នកធានាដោយវត្ថុបានចេញសងនូវសិទ្ធិលើបំណុលជំនួសកូនបំណុល ឬបានរងការខូចខាតដោយការរឹបអូសអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនពីសំណាក់តុលាការអនុវត្តដើម្បីយកទៅលក់ដោយបង្ខំ នោះអ្នកធានាដោយវត្ថុអាចទាមទារឱ្យកូនបំណុលសងសំណងខ្លួនវិញបាន។ ភាពដូចគ្នាទី៦ គឺឧបាទេសកម្មលើវត្ថុបានន័យថាប្រសិនបើអចលនវត្ថុដែលបានដាក់ហ៊ីប៉ូតែក ឬបញ្ចាំត្រូវបានខូចខាតដោយកំហុសនៃតតិយជន ឬអ្នកបង្កើតហ៊ីប៉ូតែក ឬសិទ្ធិលើការបញ្ចាំបានលក់នូវអចលនវត្ថុនោះឱ្យទៅតតិយជន នោះម្ចាស់បំណុលហ៊ីប៉ូតែក ឬ

ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុ អាចអនុវត្តសិទ្ធិរបស់ខ្លួនបានចំពោះប្រាក់ ឬវត្ថុដែលជាតាវកាលិកតបនៃការលក់ ឬសំណងព្យសនៈកម្មនោះបាន មុនពេលដែលវាត្រូវបានប្រគល់ទៅឱ្យអ្នកបង្កើតហ៊ីប៉ូតែក ឬសិទ្ធិការបញ្ចាំអចលនវត្ថុ។ ភាពដូចគ្នាទី៧គឺ ទាំងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ ម្ចាស់សិទ្ធិហ៊ីប៉ូតែក ឬការបញ្ចាំអចលនវត្ថុសុទ្ធតែអាចយកទៅដាក់ជាប្រាតិភោគបន្តដើម្បីធានាបំណុលរបស់ខ្លួនបានផងដែរ។ បន្ទាប់មក ភាពដូចគ្នាទី៨ គឺការរលត់ដែលជាចំណុចបញ្ចប់នៃសិទ្ធិ ទាក់ទងទៅនឹងបញ្ហានេះ ទាំងហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុគឺនឹងត្រូវរលត់ជាទូទៅនៅពេលដែលកូនបំណុលបានសងបំណុលអស់ទាំងស្រុងទៅឱ្យម្ចាស់បំណុល។ វាក៏អាចរលត់ទៅបានផងដែរ ក្នុងករណីដែលតតិយជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយការទិញបានសងនូវថ្លៃលក់ទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ឬម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុតាមការទាមទាររបស់ម្ចាស់សិទ្ធិនោះ។ មួយទៀតប្រសិនបើអ្នកធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដោយអាជ្ញាយុកាល បានធ្វើលទ្ធកម្មដោយសុចរិត នោះក៏ធ្វើឱ្យហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុត្រូវបានរលត់ផងដែរ ព្រោះលទ្ធកម្មដោយអាជ្ញាយុកាលជាលទ្ធកម្មតាំងពីដំបូង ធ្វើឱ្យលទ្ធកម្មនោះគ្មានជាប់បន្ទុកអ្វីទាំងអស់ ដែលខុសពីលទ្ធកម្មបន្ត ដូចជាការទិញ-លក់ ជាដើម។ ចំណុចចុងក្រោយបំផុតនៃភាពដូចគ្នានោះគឺ ក្នុងករណីដែលដល់កាលបរិច្ឆេទកំណត់សងនៃសិទ្ធិលើបំណុលហើយ កូនបំណុលអលទ្ធភាពសងបំណុល ឬសងតែមិនបានពេញលេញ ម្ចាស់បំណុលហ៊ីប៉ូតែក ឬម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចធ្វើការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដោយខ្លួនឯងបានទេ ពោលគឺត្រូវដាក់ពាក្យសុំទៅតុលាការអនុវត្តដើម្បីរឹបអូសនូវអចលនវត្ថុនោះទៅលក់ដោយបង្ខំ ហើយនីតិវិធីនៃការលក់ដោយបង្ខំនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរនេះគឺដូចគ្នា ពោលគឺជានីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។ ទាំងនេះសុទ្ធសឹងតែជាភាពដូចគ្នានៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងពីរប្រភេទនេះ។

រីឯភាពខុសគ្នាវិញ ជាដំបូងយើងឃើញថាករណីហ៊ីប៉ូតែក អ្នកបង្កើតហ៊ីប៉ូតែកពុំចាំបាច់ផ្ទេរនូវការកាន់កាប់អចលនវត្ថុទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែកឡើយ ពោលគឺអ្នកបង្កើតហ៊ីប៉ូតែកនៅតែអាចប្រើប្រាស់ អាស្រ័យផលពីអចលនវត្ថុនោះបានដូចធម្មតា ចំណែកឯការបញ្ចាំអចលនវត្ថុវិញ ការផ្ទេរការកាន់កាប់លើអចលនវត្ថុទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំគឺជាការចាំបាច់បំផុត ច្បាប់មិនអនុញ្ញាតឱ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុធ្វើការកាន់កាប់អចលនវត្ថុនោះដោយផ្ទាល់បានទេ ហើយម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុក៏អាចប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះបានផងដែរ តែត្រូវគោរពតាមវិធីនៃការប្រើប្រាស់ធម្មតា។ ចំណុចខុសគ្នាទី២ គឺទាក់ទងទៅនឹងបន្ទុកសោហ៊ុយនៃការគ្រប់គ្រងអចលវត្ថុ ក្នុងករណីហ៊ីប៉ូតែក ដោយសារតែអ្នកបង្កើតហ៊ីប៉ូតែកអាចបន្តប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះបាន ដូច្នេះអ្នកបង្កើតហ៊ីប៉ូតែកគឺជាអ្នករ៉ាប់រងនូវបន្ទុក

សោហ៊ុយនៃការគ្រប់គ្រងដោយខ្លួនឯង ផ្ទុយមកវិញ ក្នុងករណីនៃការបញ្ចាំអចលនវត្ថុ ជាគោលការណ៍ម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុគឺជាអ្នកទទួលបន្ទុកលើសោហ៊ុយនៃការគ្រប់គ្រងវត្ថុ ដោយសំអាងថាម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិលើការបញ្ចាំបានព្រមព្រៀងគ្នាជាមួយកូនបំណុលឱ្យកូនបំណុលជាអ្នកទទួលបន្ទុកលើសោហ៊ុយនៃការគ្រប់គ្រង ច្បាប់ក៏ទទួលស្គាល់នូវនីត្យានុកូលភាពនៃការព្រមព្រៀងបែបនេះផងដែរ។ ចំណុចខុសគ្នាទី៣ គឺទាក់ទងទៅនឹងការប្រាក់ ក្នុងករណីហ៊ីប៉ូតែក ម្ចាស់បំណុលហ៊ីប៉ូតែកអាចយកការប្រាក់ពីកូនបំណុលបាន ប៉ុន្តែក្នុងករណីការបញ្ចាំអចលនវត្ថុ តាមគោលការណ៍ច្បាប់ទូទៅគឺម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចទាមទារការប្រាក់ពីកូនបំណុលបានឡើយ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ការហាមជាទូទៅមិនឱ្យយកការប្រាក់នេះគឺសំអាងថា ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ដែលអាចចាត់ទុកថាជាថ្នូរទៅនឹងការប្រាក់ហើយ។ ចំណុចខុសគ្នាទី៤ គឺហ៊ីប៉ូតែក កូនបំណុលអាចយកអចលនវត្ថុតែមួយទៅបង្កើតហ៊ីប៉ូតែកច្រើនចំពោះម្ចាស់បំណុលផ្សេងៗគ្នាក្នុងពេលតែមួយបាន ក្នុងករណីបែបនេះ លំដាប់នៃសិទ្ធិបុរិមាក្នុងការទទួលបានសំណងនៅពេលចែកចំណែក គឺអាស្រ័យទៅលើលំដាប់នៃការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៃរដ្ឋបាលសុរិយោដី ខុសដាច់ស្រលះពីនេះ អចលនវត្ថុមួយអាចយកទៅដាក់បញ្ចាំបានចំពោះតែម្ចាស់បំណុលម្នាក់ប៉ុណ្ណោះ ព្រោះការបញ្ចាំគឺតម្រូវឱ្យមានការផ្ទេរការកាន់កាប់ទៅឱ្យម្ចាស់សិទ្ធិលើការបញ្ចាំជាដាច់ខាត បើមិនផ្ទេរការកាន់កាប់មិនចាត់ទុកជាការបញ្ចាំទេ។ ចំណុចខុសគ្នាចុងក្រោយគឺទាក់ទងទៅនឹងកំឡុងពេលដែលសិទ្ធិប្រាតិភោគមានអត្ថិភាព ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ មិនបានកំណត់អំពីអំឡុងពេលដែលមានអត្ថិភាពសម្រាប់ការបង្កើតហ៊ីប៉ូតែកឡើយ ពោលគឺចង់បង្កើតក្នុងថិរវេលាយូរប៉ុណ្ណាក៏បាន ខុសពីនេះក្នុងករណីការបញ្ចាំអចលនវត្ថុ ច្បាប់បានបញ្ញត្តិអំពីកំឡុងពេលដែលមានអត្ថិភាព ពោលគឺកិច្ចសន្យាបញ្ចាំអចលនវត្ថុអាចធ្វើឡើងសម្រាប់តែអំឡុងពេលអតិបរមា៥ឆ្នាំប៉ុណ្ណោះ ប៉ុន្តែនៅពេលបញ្ចប់ គូភាគីអាចបន្តកិច្ចសន្យាសាជាថ្មីបាន តែការបន្តថ្មីនេះក៏មិនឱ្យហួសពីថិរវេលា៥ឆ្នាំដែរ គិតចាប់ពីពេលបន្ត។

ក្រៅពីនេះ ទាំងហ៊ីប៉ូតែក និងសិទ្ធិលើការបញ្ចាំអចលនវត្ថុគឺសុទ្ធសឹងតែមានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន។ គុណសម្បត្តិនៃហ៊ីប៉ូតែក គឺអនុញ្ញាតឱ្យកូនបំណុលអាចប្រើប្រាស់អចលនវត្ថុខ្លួនឱ្យអស់នូវតម្លៃសេដ្ឋកិច្ចពោលគឺ កូនបំណុលអាចស្នាក់នៅ និងអាស្រ័យផលលើអចលនវត្ថុជាកម្មវត្ថុនៃហ៊ីប៉ូតែកបាន ជាអាទិ៍ដូចជាអាចបង្កើតជាចំការលើដីនោះ អាចបើកអាជីវកម្មក្នុងអគារ ឬជួលអចលនវត្ថុនោះទៅឱ្យតតិយជន ដែលធ្វើកូនបំណុលទទួលបានចំណូល ការទទួលបានចំណូលតាមរយៈការប្រើប្រាស់នេះ គឺមានប្រយោជន៍សម្រាប់កូនបំណុលផ្ទាល់ដោយអាចផ្គត់ផ្គង់នូវជីវភាពប្រចាំថ្ងៃផ្ទាល់ខ្លួន ហើយក៏មានប្រយោជន៍ចំពោះម្ចាស់បំណុលដែរ

ពោលគឺប្រសិនបើកូនបំណុលមានចំណូលជីវភាពស្ថិតស្ថេរ ម្ចាស់បំណុលនឹងអស់បារម្ភពីលទ្ធភាពនៃការសងបំណុលខ្លួនផងដែរ ប្រយោជន៍មួយទៀតគឺចំពោះសង្គមជាតិ វាធ្វើឱ្យមានចរន្តសេដ្ឋកិច្ច ការបង់ពន្ធជូនរដ្ឋជាដើម។ លើសពីនេះទៅទៀត ច្បាប់ក៏បានបើកផ្លូវទៅឱ្យកូនបំណុលអាចយកអចលនវត្ថុតែមួយទៅបង្កើតហ៊ីប៉ូតែកច្រើនចំពោះម្ចាស់បំណុលផ្សេងៗគ្នាក្នុងពេលតែមួយបានផងដែរ ដែលនេះជាប្រយោជន៍ដ៏ធំធេងចំពោះកូនបំណុល។ រីឯគុណវិបត្តិវិញ ដោយសារតែច្បាប់បានអនុញ្ញាតឱ្យបង្កើតហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយដូច្នេះវាបានបង្កើតនូវទំនាក់ទំនងគតិយុត្តដ៏ស្មុគស្មាញមួយ ជាពិសេសនៅពេលចែកចំណែកក្នុងករណីនៃការអនុវត្តហ៊ីប៉ូតែក ដែលអាចបង្កទៅជាជម្លោះផ្សេងៗផងដែរ ប៉ុន្តែយើងខ្ញុំគិតថានេះមិនមែនជាបញ្ហាធំដុំពេកនោះទេព្រោះបច្ចុប្បន្នកម្ពុជាមានប្រព័ន្ធគតិយុត្តដ៏ប្រសើរមួយទាក់ទងនឹងការអនុវត្តនេះ ដែលមានចែងទាំងក្នុងច្បាប់សារធាតុ និងច្បាប់នីតិវិធី។ គុណវិបត្តិមួយទៀត គឺវាធ្វើឱ្យម្ចាស់បំណុលនីមួយៗពុំសូវមានការទុកចិត្តនោះទេដោយហេតុតែអាចបង្កើតហ៊ីប៉ូតែកច្រើនលើអចលនវត្ថុតែមួយ។

ចំពោះគុណសម្បត្តិនៃការបញ្ចាំអចលនវត្ថុវិញ គឺវាធ្វើឱ្យមានលក្ខណៈប្រាកដប្រជាមួយនៃទំនាក់ទំនងគតិយុត្ត ព្រោះអចលនវត្ថុមួយអាចដាក់បញ្ចាំចំពោះម្ចាស់បំណុលបានតែមួយប៉ុណ្ណោះ ហើយវាក៏ជួយសម្រួលដល់នីតិវិធីនៃការអនុវត្តឱ្យមានភាពងាយស្រួលជាងហ៊ីប៉ូតែកផងដែរ លើសពីនេះវាក៏ធ្វើឱ្យម្ចាស់បំណុលមិនសូវបារម្ភពីការប្រមូលសិទ្ធិលើបំណុលរបស់ខ្លួនមកវិញដែរ ព្រោះម្ចាស់សិទ្ធិលើការបញ្ចាំអចលនវត្ថុជាអ្នកកាន់កាប់អចលនវត្ថុនោះផ្ទាល់ ជាងនេះទៅទៀតម្ចាស់បំណុលក៏មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុជាកម្មវត្ថុនៃការបញ្ចាំបានទៀតផង។ រីឯគុណវិបត្តិវិញ គឺកូនបំណុលពុំអាចប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុរបស់ខ្លួនបានទៀតទេ ដែលធ្វើឱ្យកូនបំណុលបាត់បង់ឱកាសក្នុងការទាញចំណូលពីអចលនវត្ថុនោះ។ ហើយកូនបំណុលក៏មិនអាចបង្កើតសិទ្ធិលើការបញ្ចាំច្រើនលើអចលនវត្ថុតែមួយក្នុងពេលតែមួយបានដែរ។

ជាចុងក្រោយ ទោះបីជា ហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ មានគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួនក៏ដោយ ក៏យើងអាចសន្និដ្ឋានបានដែរថា ហ៊ីប៉ូតែក ហាក់មានអំណោយផលល្អចំពោះកូនបំណុលជាង ការបញ្ចាំអចលនវត្ថុ។

៚៚៚🕮៛៛៛

# អនុសាសន៍

# អនុសាសន៍

ដោយផ្អែកលើសេចក្តីសន្និដ្ឋានខាងលើ យើងខ្ញុំសូមផ្តល់ជាមតិយោបល់ថា ក្នុងករណីដែលបងប្អូនប្រជាពលរដ្ឋយើងមានបញ្ហាខ្វះខាតក្នុងជីវភាព ឬត្រូវការដើមទុនបន្ថែមដើម្បីបើក ឬពង្រីកអាជីវកម្មរបស់ខ្លួនជាអាទិ៍នោះ ហើយចង់យកអចលនវត្ថុរបស់ខ្លួនទៅដាក់ជាប្រាតិភោគដើម្បីខ្ចីបំណុល យកមកដោះស្រាយបញ្ហាទាំងនេះ ក្នុងចំណោមប្រតិបត្តិការធានាកាតព្វកិច្ចទាំងពីរប្រភេទ គឺហ៊ីប៉ូតែក និងការបញ្ចាំអចលនវត្ថុ បងប្អូនប្រជាពលរដ្ឋគួរតែជ្រើសរើសយកប្រតិបត្តិការហ៊ីប៉ូតែកជាការប្រសើរជាង ព្រោះហ៊ីប៉ូតែកពិតជាបានផ្តល់អត្ថប្រយោជន៍ច្រើនជាងដល់កូនបំណុល ជាអាទិ៍ដូចជាអ្នកបង្កើតហ៊ីប៉ូតែកមិនចាំបាច់ផ្ទេរការកាន់កាប់អចលនវត្ថុទៅឱ្យម្ចាស់បំណុលហ៊ីប៉ូតែក ឡើយ អ្នកបង្កើតហ៊ីប៉ូតែកនៅតែអាចប្រើប្រាស់ ស្នាក់អាស្រ័យ ព្រមទាំងទាញផលប្រយោជន៍សេដ្ឋកិច្ចគ្រប់បែបយ៉ាងពីអចលនវត្ថុនោះបាន ដែលអាចជួយសម្រាលបន្ទុកជីវភាពបងប្អូន ក៏ដូចជាធានាលទ្ធភាពសងបំណុលផងដែរ។ ជាងនេះទៅទៀត កូនបំណុលអាចបង្កើតហ៊ីប៉ូតែកបានច្រើនលើអចលនវត្ថុតែមួយចំពោះម្ចាស់បំណុលផ្សេងៗគ្នាក្នុងពេលតែមួយបាន ពោលគឺប្រសិនបើបងប្អូនខ្ចីបំណុលដោយដាក់ហ៊ីប៉ូតែកម្តងហើយ ប៉ុន្តែនៅតែត្រូវការមូលធនបន្ថែមទៀត ហើយអចលនវត្ថុរបស់បងប្អូនមានតម្លៃខ្ពស់ជាងតម្លៃនៃសិទ្ធិលើបំណុលដែលបានខ្ចីលើកទីមួយ នោះបងប្អូនអាចយកអចលនវត្ថុដដែលនោះទៅដាក់ហ៊ីប៉ូតែកម្តងទៀត ដើម្បីខ្ចីប្រាក់បន្ថែមមកដោះស្រាយបញ្ហាដែលប្រឈម។ ហើយអត្ថប្រយោជន៍ដូចដែលបានរៀបរាប់ឡើងខាងលើនេះ គឺពុំមានទេក្នុងប្រតិបត្តិការបញ្ចាំ។

លើសពីនេះទៅទៀត យើងឃើញថាធនាគារ ដែលបច្ចុប្បន្នគឺជាទីដ៏ពេញនិយមនៃការបង្កើតហ៊ីប៉ូតែករបស់ប្រជាពលរដ្ឋខ្មែរយើងនោះ នៅពេលបង្កើតហ៊ីប៉ូតែក គឺធនាគារខ្លះតម្រូវឱ្យចុះខសន្យាពិសេស ដោយទាមទារឱ្យកូនបំណុលដាក់តម្កល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។ យើងឃើញថាតាមរយៈក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧ គឺពុំមានបញ្ញត្តិណាមួយតម្រូវឱ្យដាក់តម្កល់ប័ណ្ណកម្មសិទ្ធិនោះទេ ម្យ៉ាងទៀតបើពិចារណាទៅយើងអាចគិតថាធនាគារធ្វើបែបនេះគឺដើម្បីធានាសុវត្ថិភាពនៃអចលនវត្ថុ ក៏ដូចជាធានាការប្រមូលសិទ្ធិលើបំណុលរបស់ខ្លួន ប៉ុន្តែបើពិចារណាពីផ្លូវច្បាប់វិញ ឱ្យតែហ៊ីប៉ូតែកបង្កើតឡើងដោយគោរពតាមលក្ខខណ្ឌតតាំងចំពោះតតិយជន ពោលគឺមានលិខិតយថាភូត និងចុះបញ្ជី ហ៊ីប៉ូតែកនោះនឹងអាចអះអាងចំពោះគ្រប់តតិយជនបាន ពោលគឺទោះបីជាកូនបំណុលលក់អចលនវត្ថុរបស់ខ្លួនទៅឱ្យតតិយជនក៏ដោយ ឬក៏មានដាក់ជាប្រាតិភោគខ្ចីបំណុលបន្ថែមទៀតក៏ដោយ ក៏មិនជះឥទ្ធិពលអ្វីដល់ម្ចាស់បំណុលហ៊ីប៉ូតែកនោះដែរ តុលាការអនុវត្តមានសិទ្ធិរឹបអូសអចលនវត្ថុលក់ឡាយឡុងដើម្បីសងជាបុរិមាទៅម្ចាស់បំណុលហ៊ីប៉ូតែកដើមបាន។ ម្យ៉ាងវិញទៀត ការតម្កល់ប័ណ្ណកម្មសិទ្ធិទុកបែបនេះ ជាការធ្វើឱ្យប៉ះពាល់នូវផលប្រយោជន៍តាមផ្លូវច្បាប់របស់

កូនបំណុល ដូចជាកូនបំណុលមិនអាចយកអចលនវត្ថុរបស់ខ្លួនទៅដាក់ធានាខ្ចីបំណុលបន្តទៀតទេ (ព្រោះម្ចាស់បំណុលថ្មីក៏តម្រូវឱ្យតម្កល់ប័ណ្ណកម្មសិទ្ធិដូចគ្នា) ហើយកូនបំណុលក៏មិនអាចធ្វើអនុប្បទាននូវអចលនវត្ថុខ្លួនទៅឱ្យតតិយជនផងដែរ។ សរុបជារួមមក ដោយផ្អែកទៅលើអំណះអំណាងដែលបានលើកឡើងមកនេះ យើងខ្ញុំសំណូមពរឱ្យធនាគារ ក៏ដូចជាម្ចាស់បំណុលដទៃទៀត ក្នុងការបង្កើតហ៊ីប៉ូតែក សូមកុំបង្កើតខសន្យាពិសេសស្តីពីការតម្កល់ប័ណ្ណកម្មសិទ្ធិនេះអី។

ជាសំណូមពរចុងក្រោយ គឺអំពីនីតិវិធីនៃការអនុវត្ត យើងឃើញថានីតិវិធីនេះគឺមានលក្ខណៈស្មុគស្មាញ និងវែងឆ្ងាយ រីឯនិស្សិតដែលរៀននៅសាកលវិទ្យាល័យក្នុងមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីវិញ ដោយសារតែចំនួនម៉ោងសិក្សាមានកំណត់ ហើយនីតិវិធីរដ្ឋប្បវេណីមានច្រើន ដូច្នេះយើងខ្ញុំពុំបានសិក្សាក្បោះក្បាយអំពីនីតិវិធីនៃការអនុវត្តនោះទេ ម្យ៉ាងវិញទៀត បើនិយាយពីប្រជាពលរដ្ឋទូទៅវិញ គឺរឹតតែមិនយល់អំពីនីតិវិធីនេះទៅទៀត។ កន្លងមកយើងឃើញក្រសួងយុត្តិធម៌ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងវិស័យយុត្តិធម៌ បាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញសហការជាមួយដៃគូពាក់ព័ន្ធធ្វើការរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ជាច្រើន ជាក់ស្តែងអំពីសិក្ខាសាលានីតិវិធីនៃការអនុវត្តនេះក៏មានដែរ ប៉ុន្តែយើងខ្ញុំនៅតែទទូចសុំឱ្យក្រសួងមេត្តាជួយរៀបចំសិក្ខាសាលា ឬតាមរយៈមធ្យោបាយផ្សព្វផ្សាយដទៃទៀត ដើម្បីបញ្ជ្រាបនីតិវិធីនៃការអនុវត្តនេះទៅកាន់និស្សិត និងប្រជាពលរដ្ឋទូទៅ ក្នុងគោលដៅដើម្បីឱ្យនិស្សិតបានយល់ជ្រាបកាន់តែច្បាស់អំពីនីតិវិធី ក៏ដូចជាដើម្បីឱ្យប្រជាពលរដ្ឋទូទៅអាចយល់អំពីសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួនក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ។

៚៚៚📖៙៙៙

# ឯកសារយោង

# ឯកសារយោង

- ❖ **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ៖**
  - ➢ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
  - ➢ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
  - ➢ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
  - ➢ ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩២០
  - ➢ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១
  - ➢ ច្បាប់ភូមិបាល ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ១០០ ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋ នៃ រដ្ឋកម្ពុជា
  - ➢ ច្បាប់ភូមិបាល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
  - ➢ ប្រកាសអន្តរក្រសួង រវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ លេខ ១៥៩ប្រក/ជនស/មថ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ប្រក/ជនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ-សង្កាត់ក្នុងការចុះបញ្ជីដីធ្លី
  - ➢ ប្រកាសអន្តរក្រសួង រវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ ៣០ កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
  - ➢ ប្រកាសអន្តរក្រសួង រវាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ លេខ៥៩ ប្រក.ជ.ន.ស/១១ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី

## ❖ ស្នាដៃអ្នកនិពន្ធ និងស្រាវជ្រាវ

- ម៉ៅ សិលា, ជំនួយស្មារតី៖ និយមន័យ និងការចុះបញ្ជីហ៊ីប៉ូតែកនៅកម្ពុជា, ការផ្សព្វផ្សាយរបស់សមាគមសាលាត្រាជូ, ខែមករា ឆ្នាំ២០១៨
- អ៊ីវ ប៉ូលី, មេរៀនសង្ខេបនីតិរដ្ឋប្បវេណី, ឆ្នាំ២០១១
- SHIMANUKI Masao ជំនាញការ JICA, នីតិវិធីនៃការអនុវត្តហ៊ីប៉ូតែក, ឆ្នាំ២០១៦

## ❖ ឯកសារយោងផ្សេងទៀត៖

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤៖ គន្ថីទី៦ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី រៀបចំដោយក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១១
- សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១-៣, រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, កែសម្រួលលើការបោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែមីនា ឆ្នាំ២០១៧
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ, រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា
- មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១, រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌, បោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៥
- កម្រងគំរូពាក្យសុំ និងគំរូចុះបញ្ជី ផ្អែកលើប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី រៀបចំដោយក្រុមការងារអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមការងារប្រឹក្សាយោបល់របស់ប្រទេសជប៉ុន ជំនាញរបស់ទីភ្នាក់ងារសហប្រតិបត្តិអន្តរជាតិនៃប្រទេសជប៉ុន(JICA), បោះពុម្ពលើកទី១, រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៣

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឧបសម្ព័ន្ធ | លេខឧបសម្ព័ន្ធ |
|---|---|---|
| | **ផ្នែកហ៊ីប៉ូតែក** | |
| ១. | ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី១** |
| | របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែក | |
| ២. | ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែករួម | **ឧបសម្ព័ន្ធទី២** |
| | របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែករួម | |
| | តារាងប្រាតិភោគរួម | |
| ៣. | ពាក្យសុំចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត | **ឧបសម្ព័ន្ធទី៣** |
| | របៀបចុះបញ្ជី អំពីការបង្កើតហ៊ីប៉ូតែកបន្ត | |
| ៤. | ពាក្យសុំចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី៤** |
| | របៀបចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក | |
| ៥. | ពាក្យសុំចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម | **ឧបសម្ព័ន្ធទី៥** |
| | របៀបចុះបញ្ជី អំពីឧបាទេសកម្មហ៊ីប៉ូតែករួម | |
| | តារាងប្រាតិភោគរួម | |
| ៦. | ពាក្យសុំចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី៦** |
| | ពាក្យសុំចុះបញ្ជី អំពីការបោះបង់ហ៊ីប៉ូតែក | |
| | របៀបចុះបញ្ជី អំពីអនុប្បទានហ៊ីប៉ូតែក ឬការបោះបង់ហ៊ីប៉ូតែក | |
| ៧. | ពាក្យសុំចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី៧** |
| | ពាក្យសុំចុះបញ្ជី អំពីការបោះបង់លំដាប់ហ៊ីប៉ូតែក | |
| | របៀបចុះបញ្ជី អំពីអនុប្បទានលំដាប់ហ៊ីប៉ូតែក ឬការបោះបង់លំដាប់ហ៊ីប៉ូតែក | |
| ៨. | ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី៨** |
| | របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរលំដាប់ហ៊ីប៉ូតែក | |
| ៩. | ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី៩** |
| | របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវហ៊ីប៉ូតែក | |
| ១០. | ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក | **ឧបសម្ព័ន្ធទី១០** |
| | របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីហ៊ីប៉ូតែក | |
| | **ផ្នែកការបញ្ចាំអចលនវត្ថុ** | |
| ១១. | ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ | **ឧបសម្ព័ន្ធទី១១** |

| | | |
|---|---|---|
| | របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំ | |
| ១២. | ពាក្យសុំចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ | **ឧបសម្ព័ន្ធទី១២** |
| | របៀបចុះបញ្ជី អំពីការផ្ទេរសិទ្ធិលើការបញ្ចាំ | |
| ១៣. | ពាក្យសុំចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត | **ឧបសម្ព័ន្ធទី១៣** |
| | របៀបចុះបញ្ជី អំពីការបង្កើតសិទ្ធិលើការបញ្ចាំបន្ត | |
| ១៤. | ពាក្យសុំចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវសិទ្ធិលើការបញ្ចាំ | **ឧបសម្ព័ន្ធទី១៤** |
| | របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវសិទ្ធិលើការបញ្ចាំ (ចុះបញ្ជីចម្បង) | |
| | របៀបចុះបញ្ជី អំពីការផ្លាស់ប្តូរ ឬការកែតម្រូវសិទ្ធិលើការបញ្ចាំ (ចុះបញ្ជីបន្ថែម) | |
| ១៥. | ពាក្យសុំចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ | **ឧបសម្ព័ន្ធទី១៥** |
| | របៀបចុះបញ្ជី អំពីការលុបការចុះបញ្ជី អំពីសិទ្ធិលើការបញ្ចាំ | |
| **ផ្នែកនីតិវិធីនៃការអនុវត្តដោយបង្ខំ** | | |
| ១៦. | ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ | **ឧបសម្ព័ន្ធទី១៦** |
| ១៧. | ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត | **ឧបសម្ព័ន្ធទី១៧** |
| ១៨. | រូបមន្តអនុវត្ត | **ឧបសម្ព័ន្ធទី១៨** |
| ១៩. | ពាក្យសុំអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ | **ឧបសម្ព័ន្ធទី១៩** |
| ២០. | ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ | **ឧបសម្ព័ន្ធទី២០** |
| ២១. | លិខិតផ្តុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុដោយការអនុវត្ត សិទ្ធិប្រាតិភោគ | **ឧបសម្ព័ន្ធទី២១** |
| ២២. | របាយការណ៍បញ្ជូន | **ឧបសម្ព័ន្ធទី២២** |
| ២៣. | ដីកាបង្គាប់ឱ្យស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ | **ឧបសម្ព័ន្ធទី២៣** |
| ២៤. | របាយការណ៍ស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃអចលនវត្ថុ | **ឧបសម្ព័ន្ធទី២៤** |
| ២៥. | ដីកាបង្គាប់ឱ្យវាយតម្លៃ | **ឧបសម្ព័ន្ធទី២៥** |
| ២៦. | របាយការណ៍ស្តីពីការវាយតម្លៃ | **ឧបសម្ព័ន្ធទី២៦** |
| ២៧. | ដីកាសម្រេចកំណត់តម្លៃលក់អប្បបរមា | **ឧបសម្ព័ន្ធទី២៧** |
| ២៨. | ឯកសារលំអិតអំពីវត្ថុ | **ឧបសម្ព័ន្ធទី២៨** |
| ២៩. | ដីកាសម្រេចឱ្យអនុវត្តការលក់ | **ឧបសម្ព័ន្ធទី២៩** |
| ៣០. | លិខិតជូនដំណឹង | **ឧបសម្ព័ន្ធទី៣០** |
| ៣១. | ការផ្សាយជាសាធារណៈអំពីការលក់ឡាយឡុងដោយស្រោមសំបុត្រ | **ឧបសម្ព័ន្ធទី៣១** |
| ៣២. | ពាក្យសុំផ្តល់សំណើទិញ | **ឧបសម្ព័ន្ធទី៣២** |
| ៣៣. | កំណត់ហេតុស្តីពីការលក់ឡាយឡុង | **ឧបសម្ព័ន្ធទី៣៣** |

# ឧបសម្ព័ន្ធ
# ផ្នែកហ៊ីប៉ូតែក

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក

